API
BUILDING CAPACITY FOR CHANGE

វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ
ADVOCACY AND POLICY INSTITUTE



# ២០២៣

# របាយការណ៍ ប្រចាំឆ្នាំ

*FUNDING AND IMPLEMENTING PARTNERS*

វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ

# តារាងមាតិកា


សារពីក្រុមប្រឹក្សាភិបាល API និងគណៈកម្មាធិការប្រតិបត្តិ ៥

**លទ្ធផលទី១** ដើម្បីជះឥទ្ធិពលលើគោលនយោបាយនិងការអនុវត្តដើម្បីលើកកម្ពស់សិទ្ធិនិងដោះស្រាយតម្រូវការរបស់ប្រជាពលរដ្ឋជាពិសេសយុវជនក្រុមស្ត្រីនិងកុមារដែលជួបការលំបាកនិងធានាបាននូវលំហប្រជាធិបតេយ្យសម្រាប់អនុវត្តសិទ្ធិរបស់ពួកគេ ១០

គម្រោងទី១ សំឡេង និងសកម្មភាពរបស់ប្រជាពលរដ្ឋសម្រាប់ការអភិវឌ្ឍប្រកបដោយ និរន្តរភាពនៅកម្ពុជា ១០

គម្រោងទី២ យុវជនជជែកដេញដោលអំពីសេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន ១២

**លទ្ធផលទី២** ដើម្បីលើកកម្ពស់ភាពអង់អាចរបស់ប្រជាពលរដ្ឋជាពិសេសយុវជនក្រុមស្ត្រីនិងក្រុមដែលងាយរងគ្រោះចង់ឱ្យរដ្ឋាភិបាលមានគណនេយ្យភាពចំពោះការសម្រេចចិត្តនិងសកម្មភាពឆ្លើយតបដើម្បីកែលម្អសេវាកម្មសាធារណៈនិងការអនុវត្តគោលយោបាយនៅថ្នាក់ក្រោមជាតិ ១៧

គម្រោងទី៣ សំឡេង និងសកម្មភាពរបស់ប្រជាពលរដ្ឋសម្រាប់ការអភិវឌ្ឍប្រកបដោយ និរន្តរភាពនៅកម្ពុជា ដំណាក់កាលទី១ បានបញ្ចប់នៅឆ្នាំ២០២២ និងបន្តដំណាក់ កាលទី២ ពីឆ្នាំ២០២៣ ដល់ឆ្នាំ២០២៥ ១៧

គម្រោងទី៤ ការពង្រឹងការចូលរួមរបស់យុវជនក្នុងការរៀបចំផែនការមូលដ្ឋាន និងផែនការថវិកា។ ២៣

គម្រោងទី៥ គម្រោងច្រកចេញចូលតែមួយសម្រាប់ពលរដ្ឋ ២៤

គម្រោងទី៦ កម្មវិធីធ្វើឱ្យប្រសើរឡើងដល់ការផ្តល់សេវាជូនប្រជាពលរដ្ឋនៅក្នុងប្រទេសកម្ពុជា ២៦

គម្រោងទី៧ ការសម្រុះសម្រួល និងការយល់ព្រម ឆេងឌីហ្គេមអាកាដឺមី សម្រាប់ការកៀរគរការគាំទ្រមតិនៅកម្ពុជា ២៨

គម្រោងទី៨ ជំនួយសង្គ្រោះបន្ទាន់ដល់គ្រួសារដែលងាយរងគ្រោះបំផុតអំឡុង ពេលកូវីដ-១៩ ៣០

គម្រោងទី៩ សំឡេង និងសកម្មភាពរបស់ជនពិការក្នុងគណនេយ្យភាពសង្គម ៣០

គម្រោងទី១០ ការចូលរួមរបស់ប្រជាពលរដ្ឋសម្រាប់កិច្ចការពារសង្គមតាមរយៈយន្តការគណនេយ្យភាពសង្គម ៣០

| | | |
|---|---|---|
| គម្រោងទី១១ | គាំទ្រការចូលរួមរបស់ប្រជាពលរដ្ឋប្រកបដោយអត្ថន័យតាមរយៈការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលដើម្បីធ្វើឱ្យប្រសើរឡើងនូវគណនេយ្យភាពសង្គម | ៣០ |
| គម្រោងទី១២ | គម្រោងការច្នៃប្រឌិតថ្មីសម្រាប់គណនេយ្យភាពសង្គមនៅប្រទេសកម្ពុជា | ៣៤ |
| គម្រោងទី១៣ | សំឡេង និងសកម្មភាពរបស់មេដឹកនាំ និងសហគ្រិនស្ត្រីវ័យក្មេង | ៤៣ |
| គម្រោងទី១៤ | ការលើកកម្ពស់សមត្ថភាព និងប្រតិបត្តិការស្ថាប័នរបស់សមាគមថ្នាក់ខេត្តនៃក្រុមប្រឹក្សាមូលដ្ឋាន | ៤៤ |
| **លទ្ធផលទី៣** | **ធ្វើឱ្យប្រសើរឡើងនូវការប្រើប្រាស់និងការបង្ហាញព័ត៌មានសាធារណៈអំពីបញ្ហាសំខាន់ៗ** | ៤៥ |
| គម្រោងទី១៥ | គម្រោងសិទ្ធិទទួលព័ត៌មានសម្រាប់ទាំងអស់គ្នាការលើកកម្ពស់លទ្ធភាពទទួលបានព័ត៌មាននៅកម្ពុជា | ៤៥ |
| គម្រោងទី១៦ | គម្រោងត្រួតពិនិត្យ និងសកម្មភាពអ៊ីនធឺណិត | ៥៤ |
| គម្រោងទី១៧ | ឆ្ពោះទៅរកតម្លាភាពលទ្ធកម្មសាធារណៈ (PPT) | ៥៧ |
| គម្រោងទី១៨ | សំឡេងពលរដ្ឋដើម្បីសេវាគាំពារសង្គមកាន់តែប្រសើរឡើង តាមរយៈការអនុវត្តផែនការគណនេយ្យភាពសង្គម I-SAF | ៥៨ |
| គម្រោងទី១៩ | កម្មវិធីពង្រឹងស្ត្រី និងយុវជនក្នុងភាពជាអ្នកដឹកនាំ | ៦៧ |
| គម្រោងទី២០ | គម្រោង សំឡេង និងសកម្មភាពរបស់ប្រជាពលរដ្ឋសម្រាប់ការអភិវឌ្ឍប្រកបដោយនិរន្តរភាពនៅកម្ពុជា | ៧០ |
| **លទ្ធផលទី៤** | **អង្គការ API កំពុងតែបង្កើនសមត្ថភាព និងនិរន្តរភាពនៃស្ថាប័នរបស់ខ្លួនតាមរយៈការរៃអង្គាសថវិកាដោយជោគជ័យ ដើម្បីសម្រេចបានគោលដៅឆ្នាំ ២០២៣** | ៧៤ |

**បញ្ជីគម្រោងក្នុងឆ្នាំ ២០២៤ និងរចនាសម្ព័ន្ធបុគ្គលិកអង្គការ API ឆ្នាំ ២០២៤** ៧៥

## សារពីក្រុមប្រឹក្សាភិបាល API និងគណៈកម្មាធិការប្រតិបត្តិ

ក្នុងនាមអង្គការវិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ (API) យើងជាសមាជិកក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការប្រតិបត្តិបានបញ្ជាក់ថាយើងបានបញ្ចប់ដោយជោគជ័យនូវការអនុវត្តយុទ្ធសាស្ត្រឆ្នាំ2019 – 2023 របស់អង្គការ API ក្នុងគោលបំណងចូលរួមចំណែកក្នុងការសម្រេចបាននូវ ចក្ខុវិស័យ របស់អង្គការ៖ ថាប្រទេសកម្ពុជាមានសុខដុមរមនា និរន្តរភាពលទ្ធិប្រជាធិបតេយ្យ ស្ថិរភាពនយោបាយ និងសេដ្ឋកិច្ច តាមរយៈការកាត់បន្ថយភាពក្រីក្រ និងការពារសិទ្ធិមនុស្ស។ គោលដៅនេះត្រូវបានបន្ត បើទោះបីជាប្រទេសកម្ពុជាបានធ្វើការបោះឆ្នោតជាតិឆ្នាំ2023 ដោយគ្មានគណបក្សប្រឆាំងពិតប្រាកដក៏ដោយ ហើយពិភពលោកកំពុងប្រឈមមុខនឹងបញ្ហាប្រឈមយ៉ាងខ្លាំងក្នុងការស្តារសេដ្ឋកិច្ចរបស់ខ្លួនឡើងវិញបន្ទាប់ពីមានការរាតត្បាតជំងឺកូវីដ-១៩ ក្នុងពេលជាមួយគ្នានេះការស៊ូទ្រាំសង្គ្រាមនៅហ្គាហ្សា និងនៅអ៊ុយក្រែនដែលទាំងអស់នេះបានបង្កផលប៉ះពាល់អវិជ្ជមានលើសេដ្ឋកិច្ចពិភពលោក ភូមិសាស្ត្រនយោបាយ លទ្ធិប្រជាធិបតេយ្យ សិទ្ធិមនុស្ស និងសណ្តាប់ធ្នាប់ពិភពលោក និងអន្តរជាតិ ជាមួយនឹងការធ្លាក់ចុះដែលមិនអាចជៀសវាងបានទៅលើបេសកកម្ម និងចក្ខុវិស័យរបស់ API ផងដែរ។

យើងសូមថ្លែងអំណរគុណយ៉ាងស្មោះស្ម័គ្រចំពោះការផ្តល់មូលនិធិ ការអនុវត្ត និងដៃគូបណ្តាញទាំងអស់របស់អង្គការ API ក៏ដូចជាអ្នកទទួលផល និងមិត្តភក្តិ ដែលបានចូលរួម និងគាំទ្របេសកកម្ម និងសកម្មភាពរបស់យើងក្នុងឆ្នាំ2023។ សម្រាប់ឆ្នាំនេះដៃគូផ្តល់មូលនិធិរបស់យើងគឺ៖ សហភាពអឺរ៉ុប (EU) ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID) ក្រសួងការបរទេសសហរដ្ឋអាមេរិក (DoS) ក្រសួងការបរទេសហូឡង់ តាមរយៈការផ្តល់ជំនួយតតសំណាងរបស់វ៉យ (Voice) អង្គការ ប្រ៊េដ ហ្វ័រ ឌឺ វើល(BfdW) អង្គការឃែរអន្តរជាតិនៅកម្ពុជា (CARE) ជំនួយព្រះវិហារដាណឺម៉ាក (DCA) វិទ្យាស្ថានគ្រប់គ្រង បូព៌ា-បស្ចឹម (EWMI) អង្គការសុខភាព គ្រួសារអន្តរជាតិ 360 (FHI360) អង្គការអុកស្វាមនៅកម្ពុជា (OXFAM) អង្គការផេកកម្ពុជា (PACT) អង្គការតម្លាភាពកម្ពុជា (TIC) និង Wilde Ganzen Foundation (WG)។ ដៃគូអនុវត្តគឺ៖ អេពិកអាត (Epic Arts) អ៊ិនស្ទីត (InSTEDD) សមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ (IDEA) សមាគមមនុស្សចាស់ (OAA) សមាគមតន្ត្រីសំនៀងជនពិការ (MAPD) មជ្ឈមណ្ឌលជីវិតរស់នៅដោយឯករាជ្យនៃជនពិការភ្នំពេញ (PPCIL) និងសមាជិកនៃសម្ព័ន្ធភាពដៃគូដើម្បីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ (CPDD) ក្រុមការងារសិទ្ធិទទួលព័ត៌មាន (A2IWG) និងក្រុមការងារថវិកា (BWG) គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC) វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា (NGOF) ក្រុមការងារប្រឆាំងអំពើពុករលួយ (ACWG) ក្រុមការងារសិទ្ធិឌីជីថល (DRWG) បណ្តាញគាំពារសង្គមសម្រាប់ទាំងអស់ (SP4All) គណៈកម្មាធិការបច្ចេកទេសនៃក្រុមការងារគណនេយ្យភាពសង្គម(ISAF-PSC) និងផ្សេងៗទៀត។

យើងក៏សូមថ្លែងអំណរគុណចំពោះកិច្ចសហការដ៏ល្អរបស់យើងជាមួយ អង្គការសហគមន៍មូលដ្ឋាន (CBOs) ប្រព័ន្ធផ្សព្វផ្សាយ និងស្ថាប័នរាជរដ្ឋាភិបាល និងសមាគមអាជ្ញាធរមូលដ្ឋាន៖ សមាគម ក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន និងអាជ្ញាធរមូលដ្ឋានខេត្តបន្ទាយមានជ័យ បាត់ដំបង ពោធិ៍សាត់ កំពង់ឆ្នាំង កំពង់ស្ពឺ កណ្តាល តាកែវ កែប ព្រះសីហនុ កោះកុង សៀមរាប កំពង់ធំ ក្រចេះ ស្ទឹងត្រែង រតនគិរី មណ្ឌលគិរី និងរាជធានីភ្នំពេញ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) ក្រសួងមហាផ្ទៃ (MoI) ក្រសួងអប់រំ យុវជន និងកីឡា ( MoEYS ) ក្រសួងសុខាភិបាល (MoH) ក្រសួងព័ត៌មាន (MoInfo.) ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (MoEF) ក្រសួងទេសចរណ៍ (MoT) ក្រសួងពាណិជ្ជកម្ម (MoC) ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (MLMUPC) ក្រសួងកិច្ចការនារី (MoWA) និង អាជ្ញាធរមូលដ្ឋាន និងស្ថាប័នផ្តល់សេវានានា ក្នុងការរួមចំណែកក្នុងការសម្រេចបាននូវផែនការយុទ្ធសាស្ត្រ (២០១៩ - ២០២៣) របស់យើង ក្នុងគោលដៅលើកកម្ពស់សិទ្ធិ និងសំឡេងប្រជាពលរដ្ឋសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពនៅកម្ពុជា ដោយផ្តោតលើស្ត្រី យុវជន និងក្រុមដែលជួបការលំបាក ប្រជាពលរដ្ឋក្រីក្រ ជនមានពិការភាព ជនជាតិដើមភាគតិច និងកុមារក្រៅសាលា ដើម្បីឈានទៅរកការសម្រេចបានគោលដៅនេះ អង្គការ API បន្តខិតខំធ្វើឱ្យបសើរឡើងនូវសិទ្ធិទទួលបានព័ត៌មាន តម្លាភាពបន្ថែមទៀត ការកែលម្អសេវាសាធារណៈ និងអភិបាលកិច្ចមូលដ្ឋាននៅកម្ពុជា។

ជាចុងក្រោយ គណៈកម្មាធិការប្រតិបត្តិសូមថ្លែងអំណរគុណដល់សមាជិកក្រុមប្រឹក្សាភិបាលនៃអង្គការ API ទាំងអស់៖ លោក សឿង ច័ន្ទតារា លោកស្រី Kasumi Nakagawa លោក Michael Engquist លោកស្រី ញាន ភួងម៉ាលី និងលោក ចាន់ ប៊ុនធឿន និងទីប្រឹក្សាយើង (លោក Lars Krause) និងអ្នកស្ម័គ្រចិត្តទាំងអស់ដែលបានចំណាយពេលវេលា និងការខិតខំប្រឹងប្រែងក្នុងការបំពេញភារកិច្ចយ៉ាងល្អ ដោយធ្វើការរួមចំណែកដ៏មានតម្លៃដល់ការរីកចម្រើននៃអង្គការ API និងមានការជោគជ័យ

ជាច្រើន។ ពិសេសសូមថ្លែងអំណរគុណយ៉ាងជ្រៀរជ្រៅទៅកាន់បុគ្គលិក អ្នកស្ម័គ្រចិត្ត និងអ្នកពាក់ព័ន្ធទាំងអស់ ថ្នាក់ដឹកនាំ និងសមាជិកសហគមន៍ ក្នុងតំបន់គោលដៅរបស់យើង ព្រមទាំងមន្ត្រីរដ្ឋាភិបាលគ្រប់លំដាប់ថ្នាក់ ដែលបានខិតខំប្រឹងប្រែង និងរួមចំណែកដល់ការជោគជ័យរបស់យើង។


*CHANDARA SOEURNG*
Chair of Board


*PHOUNGMALY NHEAN*
Board Member


*KASUMI NAKAGAWA*
Board Member


*BUNTHOEUN THANN*
Treasurer


*MICHAEL ENGQUIST*
Board Member

រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែមករា ឆ្នាំ២០២៤

ក្នុងនាមគណៈកម្មាធិការប្រតិបត្តិរបស់អង្គការ API

**លោក ឡាំ សុជាតិ**
នាយកប្រតិបត្តិ
អង្គការវិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ

ក្នុងនាមក្រុមប្រឹក្សាភិបាលរបស់អង្គការ API

**លោក សឿង ច័ន្ទតារា**
ប្រធានក្រុមប្រឹក្សាភិបាល
អង្គការវិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ

# Acronyms

| | |
|---|---|
| **A2I** | Access to Information |
| **A2IWG** | Access to Information Working Group |
| **A4A** | Access for All |
| **ADB** | Asian Development Bank |
| **ADHOC** | Cambodian Human Rights and Development Association |
| **AIDS** | Acquired Immunodeficiency Syndrome |
| **API** | Advocacy and Policy Institute |
| **BfdW** | Bread for the World |
| **BWG** | Budget Working Group |
| **CAF** | Community Accountability Facilitator |
| **CamboJA** | Cambodia Journalist Alliance Association |
| **CBO** | Community-Based Organization |
| **CC** | Commune Council |
| **CCC** | Committee for Cooperation in Cambodia |
| **CCiM** | Cambodian Center for Independent Media |
| **CF** | Community Forestry |
| **CIP** | Commune Investment Plan |
| **CLEC** | Community Legal Education Center |
| **Co-hosted** | Core Hosted |
| **CPA** | Community Protected Area |
| **CPDD** | Coalition for Partnership in Democratic Development |
| **CPP** | Cambodian People's Party |
| **CS** | Council Sangkat |
| **CSC** | Community Score Card |
| **CSO** | Civil Society Organization |
| **CtGA** | Change the Game Academy |
| **D&D** | Decentralization and Deconcentration |
| **D/M** | District/Municipal |
| **DCA** | DanChurchAid |
| **DCSC** | Digitized Community Score Card |
| **DFR** | Department of Functions and Resources |
| **DIP** | District Investment Plan |
| **DMK** | District, Municipality, Khan |
| **DNS** | Domain Name System |
| **DoS** | Department of State |
| **DP** | Development Partner |
| **DR** | Digital Rights |
| **DRAPA** | Digital Right Asia Pacific Assembly |

| | |
|---|---|
| **DRWG** | Digital Rights Working Group |
| **ELC** | Economic Land Concession |
| **ESIA** | Environmental and Social Impact Assessment |
| **EU** | European Union |
| **EWMI** | East-West Management Institute |
| **FHI-360** | Family Health International 360 |
| **GFA** | GFA Consulting Group |
| **GIZ** | Deutsche Gesellschaft für Internationale Zusammenarbeit |
| **HIV** | Human Immunodeficiency Virus |
| **I4C** | Information for Citizen |
| **ICS** | ISAC Community Scorecards |
| **ID** | Identity |
| **IDEA** | Independent Democracy of Informal Economy Association |
| **iMAP** | Internet Monitoring Action Project |
| **INGO** | International non-governmental organisation |
| **InSTEDD** | Innovative Support to Emergencies Diseases and Disasters |
| **IP** | Investment Program |
| **Ips** | Indigenous people |
| **ISAC** | Innovation for Social Accountability in Cambodia |
| **ISAF** | The Implementation of the Social Accountatbility Framework |
| **ISAF PSC** | Technical Working Groups and Steering Committee of Social Accountability |
| **ISAF TWG** | Social Accountability Working Group |
| **ISD** | Improved Service Delivery |
| **IVR** | Interactive Voice Response |
| **JAAP** | Joint Accountability Action Plan |
| **JAAPC** | Joint Accountability Action Plan Committee |
| **KESS** | KESS Innovation PLC |
| **KH** | Khmer |
| **MAPD** | Musical Association for People with Disabilities |
| **MEL** | Monitoring, Evaluation and Learning |
| **MoEF** | Ministry of Economy and Finance |
| **MoEYS** | Ministry of Education Youth and Sport |
| **MoH** | Ministry of Health |
| **MoI** | Ministry of Interior |
| **MS** | Mobilizing Support |
| **NCDD** | The National Committee for Sub-National Democratic Development |
| **NCDDS** | National Committee for Sub-National Democratic Development Secretariat |
| **NGO** | Non-Governmental Organisation |
| **NP-2** | National Program for Sub-national Democratic Development Phase 2 |
| **OAA** | Old Age Associations |

| | |
|---|---|
| **ODC** | Open Development Cambodia |
| **OONI** | Open Observatory of Network Interference |
| **OW4C** | One Window for Citizens Project |
| **OWSO** | One Window Service Office |
| **OWSU** | One Window Service Unit |
| **PALCs** | Provincial Associations of Local Council |
| **PFM** | Public Financial Management |
| **PPCIL** | Phnom Penh Center for Independent Living |
| **PPIF** | Phnon Penh Internet Forum |
| **PWD** | People with Disability |
| **RFA** | Radio Free Asia |
| **RFI** | Radio French Internation |
| **RGC** | Royal Government of Cambodia |
| **SDG** | Sustainable Development Goal |
| **SNA** | Sub-National Administration |
| **SP** | Strategic Plan |
| **SP4All** | Social Protection for All Working Groups |
| **TELOS** | Technical, Economic, Logistic, Organizational, and Sustainable analysis |
| **TOR** | Term of Reference |
| **ToT** | Training of Trainer |
| **UK** | United Kingdom |
| **UK Embassy** | United Kingdom EmbassyUnited Kingdom EmbassyUnited Kingdom Embassy United Kingdom Embassy |
| **UN** | United Nation |
| **UNOCHR** | United Nation Office of the Commissioner of Human Right |
| **UPR** | Universal Periodic Review |
| **US Dos** | United States Department of State |
| **USAID** | United States Agency for International Development |
| **USD** | United States dollar |
| **USG** | United State Government |
| **Vlog** | Video log |
| **VOA** | Voice of America |
| **VOD** | Voice of Democratic |
| **VPN** | Virtual Private Network |
| **WG** | Working Group |

ជាមួយនឹងផែនការយុទ្ធសាស្ត្រទី4 (SP) របស់អង្គការ API សម្រាប់ឆ្នាំ2019 ដល់ឆ្នាំ2023 អង្គការ API បានបន្តគោលដៅលើកកម្ពស់សិទ្ធិ និងសំឡេងប្រជាពលរដ្ឋសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពនៅកម្ពុជា ដោយផ្តោតលើស្ត្រី យុវជន និងក្រុមដែលជួបការលំបាក ប្រជាពលរដ្ឋក្រីក្រ ជនមានពិការភាព ជនជាតិដើមភាគតិច និងកុមារក្រៅសាលា នេះគឺជាឆ្នាំចុងក្រោយនៃការអនុវត្តផែនការយុទ្ធសាស្ត្រ 2019 - 2023 ហើយអង្គការ API បានសម្រេចលទ្ធផលជាយុទ្ធសាស្ត្រចំនួនបួនដែលបានរាយខាងក្រោម៖

## លទ្ធផលទី១

**ដើម្បីជះឥទ្ធិពលលើគោលនយោបាយ និងការអនុវត្តដើម្បីលើកកម្ពស់ សិទ្ធិ និងដោះស្រាយតម្រូវការរបស់ប្រជាពលរដ្ឋ ជាពិសេស យុវជន ក្រុមស្ត្រី និងកុមារដែលជួបការលំបាកនិងធានាបាននូវលំហប្រជាធិបតេយ្យសម្រាប់អនុវត្តសិទ្ធិរបស់ពួកគេ**

### គម្រោងទី១

**សំឡេង និងសកម្មភាពរបស់ប្រជាពលរដ្ឋសម្រាប់ការអភិវឌ្ឍប្រកបដោយ និរន្តរភាពនៅកម្ពុជា**
(គាំទ្រថវិកាដោយ៖ ជំនួយព្រះវិហារដាណឺម៉ាក និងអង្គការប្រ៊េដ ហ្វ៊ រ ឌឺវើល)

**គោលបំណងនៃផែនការយុទ្ធសាស្ត្រអង្គការ API ឆ្នាំ២០១៩-២០២៣៖** ដើម្បីបំពេញសិទ្ធិ និងលើកកម្ពស់ នូវសម្លេងរបស់ប្រជាពលរដ្ឋសម្រាប់ការអភិវឌ្ឍប្រកបដោយនិរន្តរភាពនៅកម្ពុជា។

**គោលបំណងនៃគម្រោង៖** ដើម្បីបំពេញសិទ្ធិ និងលើកកម្ពស់សំឡេង និងសកម្មភាពរបស់ប្រជាពលរដ្ឋ ដើម្បីការអភិវឌ្ឍប្រកបដោយនិរន្តរភាពនៅកម្ពុជា។

**គាំទ្រថវិកាដោយ៖** ៦៤៩,៣០០ អឺរ៉ូ ដោយជំនួយព្រះវិហារដាណឺម៉ាក (DCA) និងអង្គការ ប្រ៊េដ ហ្វ័រ វើល (BfdW)

**តំបន់គោលដៅ៖** ចំនួន ៤០ ក្រុង ស្រុក ខណ្ឌ ក្នុងនោះរួមមាន ខេត្តបន្ទាយមានជ័យ ខេត្តកំពង់ស្ពឺ ខេត្តកំពង់ធំ ខេត្តកណ្តាល ខេត្តកែប ខេត្តក្រចេះ ខេត្តពោធិ៍សាត់ ខេត្តតាកែវ និងរាជធានីភ្នំពេញ។





### លទ្ធផល៖

***គម្រោងទី១៖*** មានឥទ្ធិពលលើច្បាប់ និងគោលនយោបាយនៅថ្នាក់ជាតិ និងការអនុវត្តរបស់ពួកគេដើម្បី ឆ្លើយតបទៅនឹងសិទ្ធិ និងតម្រូវការរបស់ប្រជាពលរដ្ឋ អង្គការ API បានដឹកនាំ និងចូលរួមនៅក្នុងក្រុមការងារ និងបណ្តាញអង្គការសង្គមស៊ីវិលចំនួន ០៩។

១ ក្រុមការងារសិទ្ធិទទួលព័ត៌មាន (A2IWG) បានផ្តល់ធាតុចូលស្តីពីសិទ្ធិទទួលព័ត៌មាន។

២ អង្គការសម្ព័ន្ធដើម្បីភាពជាដៃគូក្នុងការអភិវឌ្ឍបែបប្រជាធិបតេយ្យ (CPDD) ជាអ្វីដែលយើងបានធ្វើការតស៊ូមតិដើម្បីឱ្យមានការបង្កើនថវិកាថ្នាក់ក្រោមជាតិលើការអភិវឌ្ឍសេវាសង្គមដោយជោគជ័យ។

៣ ក្រុមការងារថវិកា (BWG) បានធ្វើការតស៊ូមតិលើច្បាប់ថវិកាជាតិ និងច្បាប់លទ្ធកម្មសាធារណៈ។

៤ កិច្ចការពារសង្គមសម្រាប់ទាំងអស់គ្នា (SP4All) ជាអ្វីដែលយើងបានធ្វើការតស៊ូមតិដោយជោគជ័យ លើកិច្ចគាំពារសង្គមសម្រាប់និយោជិកក្រៅប្រព័ន្ធ និងអ្នកលក់ដូរតាមដងផ្លូវ។

៥ ក្រុមការងារគណនេយ្យភាពសង្គម (ISAF-TWG) ជាអ្វីដែលយើងបានធ្វើការតស៊ូមតិលើការដាក់ បញ្ចូលផ្នែកសង្គម និងបរិយាបន្នពិការភាព កិច្ចគាំពារសង្គមនៅក្នុងក្របខ័ណ្ឌ ISAF ដែលបាន សាកល្បងដោយជោគជ័យនៅក្នុងក្របខ័ណ្ឌ ISAF ។

៦ ក្រុមការងារសិទ្ធិលើប្រព័ន្ធឌីជីថល (DRWG) ជាផ្នែកមួយដែលយើងបានធ្វើការតស៊ូមតិដើម្បី សេរីភាពលើប្រព័ន្ធផ្សព្វផ្សាយ និងអ៊ីនធឺណិត និងសេរីភាពនៃការបញ្ចេញមតិដោយបានផលិតជា របាយការណ៍ត្រួតពិនិត្យនូវការរឹតត្បិតលើប្រព័ន្ធអ៊ីនធឺណិត និងរៀបចំវេទិកាអ៊ីនធឺណិតជាមួយអង្គការ សង្គមស៊ីវិល និងប្រព័ន្ធផ្សព្វផ្សាយសកម្មភាគច្រើន ដៃគូអភិវឌ្ឍន៍នៅកម្ពុជា ជាក្រុមការងារសកម្មថ្មីៗបន្ទាប់ពីវិទ្យុ VOD ត្រូវបានបិទនៅឆ្នាំ២០២៣។

៧ ក្រុមការងារប្រឆាំងអំពើពុករលួយ បានតស៊ូមតិលើច្បាប់ប្រឆាំងអំពើពុករលួយ និងច្បាប់លទ្ធកម្ម សាធារណៈដែលកំពុងធ្វើវិសោធនកម្មក្នុងឆ្នាំ២០២៣។

៨ គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC) ដែលយើងបានធ្វើការតស៊ូមតិលើអង្គការ សង្គមស៊ីវិលដែលផ្តល់បរិយាកាសជាមួយដៃគូអភិវឌ្ឍន៍ក្នុងកិច្ចសន្ទនាជាមួយអង្គការសង្គមស៊ីវិល។

កិច្ចប្រជុំភាពជាអ្នកដឹកនាំ និងសមាជិកភាពនៃអង្គការសង្គមស៊ីវិល បានយល់ព្រមឱ្យមានការសម្រប សម្រួលកាន់តែប្រសើរឡើងរវាងការដឹកនាំក្រុមការងារ កិច្ចប្រជុំសមាជិកភាព និងកិច្ចប្រជុំក្រុមការងាររួមគ្នា (WG) ជារៀងរាល់ថ្ងៃទី២២ នៃខែនីមួយៗ ចាប់តាំងពីខែមករា ឆ្នាំ២០២៣ និងកិច្ចខិតខំ ប្រឹងប្រែងតស៊ូមតិរួមគ្នានៅក្នុងសកម្មភាពជាក្រុមការងារ។






## គម្រោងទី២ យុវជនជជែកដេញដោលអំពីសេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន





### សកម្មភាព៖

១. **អង្គការ API បានដឹកនាំអង្គការសង្គមស៊ីវិលនៃក្រុមការងារសិទ្ធិទទួលព័ត៌មាន (A2IWG)** ក្រុមការងារសិទ្ធិទទួលព័ត៌មាន ក្រោមការជួយគាំទ្រពីគម្រោងទី១៥៖ ក្រសួងការបរទេសសហរដ្ឋអាមេរិក បានផ្តល់មូលនិធិតាមរយៈ វិទ្យាស្ថានគ្រប់គ្រងបូព៌ា-បស្ចិម (EWMI) ផ្តល់មូលនិធិដល់គម្រោង សិទ្ធិទទួលព័ត៌មានសម្រាប់ទាំងអស់គ្នា៖ ការលើកកម្ពស់លទ្ធភាពទទួលបានព័ត៌មាននៅកម្ពុជា ឆ្នាំ២០២០ - ២០២៣ គម្រោងទី១៨៖ ការពង្រឹងស្ត្រី និងយុវជនក្នុងកម្មវិធីភាពជាអ្នកដឹកនាំ (WYEL) ឆ្នាំ២០២២ - ២០២៤ និងគម្រោងទី២៖ ការជជែកដេញដោលរបស់យុវជន ស្តីពីសិទ្ធិទទួលព័ត៌មាន ឆ្នាំ២០២០ - ២០២១។

- បង្កើនការយល់ដឹងអំពីសារៈសំខាន់នៃក្របខ័ណ្ឌច្បាប់ដែលផ្តល់លទ្ធភាពទទួលព័ត៌មានសម្រាប់ប្រជាពលរដ្ឋកម្ពុជា និងផ្តល់អំណាចឱ្យប្រជាពលរដ្ឋស្នើសុំព័ត៌មានដែលពួកគេត្រូវការ និងឆ្លើយតបនឹងតម្រូវការរបស់ពួកគេ។ ជាលទ្ធផលក្នុងគម្រោង មានការឆ្លើយតបជាវិជ្ជមានដោយរដ្ឋាភិបាលចំនួន ១២៦ ក្នុងចំណោម ១៣០ (៩៧%) ចំពោះសំណើសុំព័ត៌មានរបស់ប្រជាពលរដ្ឋ។ ជាមួយគ្នានេះ អង្គការចំនួន ៩៧ ដែលជាសមាជិកនៃក្រុមការងារសិទ្ធិទទួលព័ត៌មាន (A2IWG) និងសម្ព័ន្ធ ភាពជាដៃគូក្នុងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ (CPDD) បានរួមគ្នាតស៊ូមតិ និងជំរុញឱ្យរដ្ឋាភិបាល អនុម័តច្បាប់ ស្តីពី សិទ្ធិទទួលព័ត៌មាន នៅក្នុងសិក្ខាសាលាថ្នាក់ជាតិប្រចាំឆ្នាំ (ទិវាអន្តរជាតិ ស្តីពី សិទ្ធិទទួលព័ត៌មាន នៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២៣)។

- បានទបណ្តុះបណ្តាលយុវជន និងជំនាញជជែកដេញដោលលើការតស៊ូមតិអំពីច្បាប់ ស្តីពី សទ្ធិទទួល ព័ត៌មាន (A2I) ជាមួយក្រសួងព័ត៌មាន និងតំណាងគណបក្សនយោបាយមុនយុទ្ធនាការបោះឆ្នោត នៅថ្នាក់ជាតិ។ គណបក្សនយោបាយកំពូលបានទទួលយកធាតុចូលពីអង្គការសង្គមស៊ីវិល និងអង្គការ សហគមន៍មូលដ្ឋាន ដែលតំណាងឱ្យជនជាតិដើមភាគតិច និងជនមានពិការភាព។ រដ្ឋាភិបាល និងគណបក្សនយោបាយ ជាពិសេស គណបក្សប្រជាជនកម្ពុជា បានប្តេជ្ញាអនុម័តសេចក្តីព្រាងច្បាប់ស្តីពី សិទ្ធិទទួលព័ត៌មាននៅក្នុងឆ្នាំ ២០២៤ - ២០២៥។ រដ្ឋលេខាធិការក្រសួងព័ត៌មាន និងរដ្ឋមន្ត្រី ប្រតិភូអមនាយករដ្ឋមន្ត្រី បានបញ្ជាក់ពីការគាំទ្រ និងរាយការណ៍ជូននាយករដ្ឋមន្ត្រីថ្មី ដើម្បីជំរុញឱ្យ អនុម័តច្បាប់ ស្តីពី សិទ្ធិទទួលព័ត៌មានឱ្យបានឆាប់រហ័សតាមដែលអាចធ្វើទៅបាន។

- ក្រសួងព័ត៌មានបានបញ្ជាក់ថា សេចក្តីព្រាងច្បាប់ ស្តីពី សិទ្ធិទទួលព័ត៌មានកំពុងស្ថិតក្នុងដំណាក់កាល ចុងក្រោយនៃការពិភាក្សារវាងក្រសួងព័ត៌មាន ក្រសួងយុត្តិធម៌ និងទីស្តីការគណៈរដ្ឋមន្ត្រី។ ជាងនេះទៅទៀត យើងរំពឹងថា ក្រសួងព័ត៌មាននឹងកែលម្អវាបន្ថែមទៀត ដោយផ្អែកលើអនុសាសន៍ របស់អង្គការសង្គមស៊ីវិល សម្រាប់សេចក្តីព្រាងច្បាប់ចុងក្រោយនេះមិនទាន់បានចែករំលែក និងធ្វើបច្ចុប្បន្នភាពជាមួយអង្គការសង្គមស៊ីវិលនៅឡើយទេ។ ធាតុចូលរបស់អង្គការសង្គមស៊ីវិលចំពោះ សេចក្តីព្រាងច្បាប់ ស្តីពី សិទ្ធិទទួលព័ត៌មានត្រូវបានទទួលស្គាល់ដោយរដ្ឋាភិបាល និងគណៈកម្មការទី៥នៃរដ្ឋសភា។ រដ្ឋសភាបានណែនាំឱ្យក្រសួងព័ត៌មានពន្លឿនដំណើរការនេះ។ ឯកឧត្តម កឹម គុណវឌ្ឍន៍ រដ្ឋលេខាធិការ ក្រសួងព័ត៌មាន និង ឯកឧត្តម ព្រាប កុល រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី ក្នុងនាមតំណាង រដ្ឋាភិបាលបានគាំទ្រ និងជំរុញឱ្យមានការអនុម័តច្បាប់ ស្តីពី សិទ្ធិទទួលបានព័ត៌មានឱ្យបានឆាប់រហ័ស តាមដែលអាចធ្វើទៅបានក្នុងសិក្ខាសាលាទិវាអន្តរជាតិ ស្តីពី ទទួលព័ត៌មានជាសកលនៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២៣។

- រដ្ឋាភិបាល អង្គការសហគមន៍មូលដ្ឋាន អង្គការអន្តរជាតិ អង្គការសង្គមស៊ីវិល វិស័យឯកជន យុវជន អាជីវករលក់ដូរតាមដងផ្លូវ ប្រព័ន្ធផ្សព្វផ្សាយ និងអ្នកពាក់ព័ន្ធផ្សេងទៀត បានទទួលស្គាល់ពីសារៈសំខាន់ នៃសិទ្ធិទទួលព័ត៌មាន ហើយជំរុញឱ្យមានការអនុម័តច្បាប់នេះឱ្យបានឆាប់រហ័យ។
- អង្គការវិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ (API) បានដឹកនាំកិច្ចប្រជុំ និងបានធ្វើបច្ចុប្បន្នភាព របាយការណ៍ត្រួតពិនិត្យជាសកល (UPR) ស្តីពី សិទ្ធិទទួលព័ត៌មាននៅកម្ពុជា និងដាក់ជូនអង្គការ សហប្រជាជាតិ និងធ្វើបច្ចុប្បន្នភាពជូន ដៃគូអភិវឌ្ឍន៍ដូចជា សហភាពអឺរ៉ុប អង្គការសុខភាព គ្រួសារអន្តរជាតិ កិច្ចសហប្រតិបត្តិការអាល្លឺម៉ង់ ស្ថានទូតអង់គ្លេស អង្គការសហប្រជាជាតិសិទ្ធិមនុស្សការិយាល័យឧត្តមស្នងការ វិទ្យាស្ថានគ្រប់គ្រង បញ្ញើមបូព៌ា ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់កិច្ចអភិវឌ្ឍន៍អន្តរជាតិ និងសមាជិកក្រុមការងារ សិទ្ធិទទួលព័ត៌មាន។

**២. គម្រោងទី៣៖ អង្គការ API ជាលេខាធិការនៃសម្ព័ន្ធភាពដៃគូដើម្បីការអភិវឌ្ឍ តាមបែបប្រជាធិបតេយ្យ (CPDD)** ចន្លោះឆ្នាំ ២០២១៩ - ២០២១ និងបានដើរតួនាទីជា ប្រធានក្រុមប្រឹក្សាភិបាលរបស់ CPDD ក្នុងឆ្នាំ២០២១ - ២០២៤






- បេសកកម្មរបស់សម្ព័ន្ធភាពដៃគូដើម្បីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ (CPDD) គឺ លើកស្ទួយ គណនេយ្យប្រជាធិបតេយ្យ និងអភិបាលកិច្ចល្អ តាមរយៈការលើកកម្ពស់សំឡេងរួម និងការចូលរួម ពេញលេញរបស់សង្គមស៊ីវិល។
- នៅឆ្នាំ ២០២៣ រដ្ឋាភិបាលបានបង្កើនថវិកាថ្នាក់ក្រោមជាតិលើការអភិវឌ្ឍសេវាសង្គមចាប់ពី ឆ្នាំ២០២៤ តទៅបន្ទាប់ពីអង្គការ API និង CPDD បានធ្វើការតស៊ូមតិជាច្រើនឆ្នាំ។
- អង្គការ API បានវិភាគថវិកាថ្នាក់ក្រោមជាតិ និងបានបើកដំណើរការកម្មវិធីវិភាគថវិកាសម្រាប់ ប្រជាពលរដ្ឋ CPDD បានប្រើប្រាស់កម្មវិធីវិភាគថវិកាសម្រាប់ប្រជាពលរដ្ឋរបស់អង្គការ API និងបានបង្ហាញរបាយការណ៍ថវិកាថ្នាក់ក្រោមជាតិ និងកម្មវិធីវិភាគថវិកាសម្រាប់ប្រជាពលរដ្ឋដល់ក្រសួងមហាផ្ទៃ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ យើងបានតស៊ូមតិដើម្បីបង្កើនការវិភាជន៍ថវិកាដល់ថ្នាក់ក្រោមជាតិ លើការអភិវឌ្ឍន៍សេវាសង្គម និងការគ្រប់គ្រងធនធានធម្មជាតិនៅក្នុងសិក្ខាសាលាថ្នាក់ជាតិ ស្តីពីការ ចូលរួមជាសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។
- អង្គការ API បានផ្តល់ការគាំទ្រយ៉ាងល្អដល់លេខាធិការ CPDD ដើម្បីបង្កើតយុទ្ធសាស្ត្រ ១០ឆ្នាំ ២០២១ - ២០២៣ ដើម្បីធ្វើឱ្យប្រសើរឡើងនូវគោលនយោបាយ និងប្រព័ន្ធអភិបាលកិច្ចផ្ទៃក្នុង និងភាពជាអ្នកដឹកនាំហើយបានចូលរួមជាសមាជិកដើម្បីតស៊ូមតិលើបញ្ហាគោលនយោបាយទាក់ទងនឹងវិមជ្ឈការ និងវិសហមជ្ឈការ (D&D) និងប្រមូលមូលនិធិដោយជោគជ័យពី ១០៦.០០០ ដុល្លារសហរដ្ឋអាមេរិកក្នុងឆ្នាំ២០២១ ដល់ ២៥២.០០០ ដុល្លារសហរដ្ឋអាមេរិកក្នុងឆ្នាំ២០២៣។

**៣. អង្គការ API បានដឹកនាំក្រុមការងារថវិកា(BWG)**

- អង្គការ API ត្រូវបានជ្រើសរើសជាប្រធាននៃក្រុមការងារថវិកាសម្រាប់អាណត្តិឆ្នាំ2022 - ២០២៣។ តួនាទីក្រុមការងារនេះផងដែរ វាមានឥទ្ធិពលលើសេចក្តីព្រាង ស្តីពី លទ្ធកម្មសាធារណៈ ដោយបង្ហាញលទ្ធផលនៃក្របខ័ណ្ឌច្បាប់សម្រាប់តម្លាភាពលទ្ធកម្មសាធារណៈ និងការអនុវត្តនៅក្នុងព្រះរាជាណាចក្រកម្ពុជាដល់ការដឹកនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ អគ្គនាយក និងមន្ត្រីជាន់ខ្ពស់ មុនពេលច្បាប់លទ្ធកម្មសាធារណៈត្រូវបានអនុម័តនៅឆ្នាំ2023 ។





- អង្គការ API បានផ្តល់ធាតុចូលផ្នែកច្បាប់ដល់រដ្ឋាភិបាលដោយផ្អែកលើគោលការណ៍លទ្ធកម្មសំខាន់ៗអន្តរជាតិដូចជា តម្លាភាព សុចរិតភាព សេដ្ឋកិច្ច ប្រសិទ្ធភាព និងគុណតម្លៃនៃថវិកា ភាពបើកចំហ យុត្តិធម៌ និងគណនេយ្យភាព។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានទទួលយកអនុសាសន៍ចំនួនបួនពីអង្គការ API។ ជាឧទាហរណ៍ សេចក្តីព្រាង ស្តីពីលទ្ធកម្មសាធារណៈ (PPL) គួរតែបញ្ជាក់ជាសាធារណៈនូវនីតិវិធីទាំងនេះ។ ដំណើរការលទ្ធកម្មទាំងមូលគួរតែមានតម្លាភាព។ នេះក៏រួមបញ្ចូលផងដែរនូវកិច្ចសន្យាដែលបានចុះហត្ថលេខារវាងអង្គភាពលទ្ធកម្ម និងអ្នកដេញថ្លៃដែលបានទទួលសិទ្ធិក្នុងការធ្វើលទ្ធកម្ម។
- អង្គការ API បានចូលរួមជាមួយរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល BWG និងឆ្លើយតបជាវិជ្ជមានចំពោះធាតុចូលរបស់អង្គការសង្គមស៊ីវិលមួយចំនួនលើកិច្ចពិភាក្សាគោលនយោបាយកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយផ្អែកលើលទ្ធផលនៃការប្រជុំក្រុមការងារថវិកាប្រចាំខែ ថ្នាក់ក្រោមជាតិ និងរបាយការណ៍វិភាគថវិកាជាតិប្រចាំឆ្នាំ2023។
- អង្គការ API បានផ្តល់អនុសាសន៍ដល់ ដៃគូអភិវឌ្ឍន៍ និងក្រសួងសេដ្ឋកិច្ច និងក្រសួងផ្សេងទៀតរបស់រដ្ឋាភិបាល។ ក្រុមការងារថវិកា (BWG) មានបេសកកម្មរបស់ខ្លួនក្នុងការផ្តល់នូវវេទិកាប្រឹក្សាថវិកាតាមស្ថាប័ន ដើម្បីវិភាគ ពិភាក្សា និងតស៊ូមតិលើការសម្រេចចិត្តថវិកាជាតិ និងថ្នាក់ក្រោមជាតិ និងដំណើរការត្រួតពិនិត្យប្រកបដោយតម្លាភាព គណនេយ្យភាព និងមានបរិយាបន្ន។
- អង្គការ API បានធ្វើបច្ចុប្បន្នភាពរបាយការណ៍ថវិកាពលរដ្ឋដំបូងសម្រាប់ប្រទេសកម្ពុជាឆ្នាំ 2023 ហើយបានដាក់ឱ្យដំណើរការដោយមានការចូលរួមពីអាជ្ញាធរមូលដ្ឋាន និងថ្នាក់ដឹកនាំសហគមន៍មូលដ្ឋាន (CBOs) នៅក្នុងខេត្តគោលដៅ និងដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងរដ្ឋាភិបាល។
- ក្រុមករងារថវិកា (BWG) បានទទួលរបាយការណ៍ត្រួតពិនិត្យតាមកាលកំណត់ជាសកលដែលផលិតដោយអង្គការ API ស្តីពីការប្រឆាំងអំពើពុករលួយឆ្នាំ2023 ហើយបានដាក់ជូនទៅទីស្នាក់ការអង្គការសហប្រជាជាតិ។

## ៤. អង្គការ API បានចូលរួមក្នុងកិច្ចប្រជុំកិច្ចគាំពារសង្គមសម្រាប់ទាំងអស់គ្នា (SP4ALL)





- អង្គការ API បានក្លាយជាសមាជិក នៃកិច្ចគាំពារសង្គមសម្រាប់ទាំងអស់គ្នា (SP4ALL) ដែលដឹកនាំដោយអង្គការ YRDP និងលេខាធិការដ្ឋានដោយអង្គការអុកស្វាមកម្ពុជា ដែលជាវេទិកា ដឹកនាំដោយពលរដ្ឋក្នុងគោលបំណង លើកកម្ពស់ការយល់ដឹងរបស់ពលរដ្ឋលើកិច្ចគាំពារសង្គម និងលើកពីក្តីកង្វល់របស់ ពលរដ្ឋទៅកាន់អ្នកមានកាតព្វកិច្ច។

- អង្គការ API បាននាំយកកិច្ចខិតខំប្រឹងប្រែងនៃការតស៊ូមតិរបស់ខ្លួនទៅបង្ហាញនៅក្នុងក្រុម។ ជាលទ្ធផលរដ្ឋាភិបាល បានចេញនូវក្របខ័ណ្ឌគោលនយោបាយ ផែនការ និងបានខិតខំប្រឹងប្រែង យ៉ាងខ្លាំងក្នុងការអនុវត្តកញ្ចប់ថវិកាបេឡាជាតិរបបសន្តិសុខសង្គម និងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច សម្រាប់កម្មករនិយោជិក និងសេដ្ឋកិច្ចក្រៅប្រព័ន្ធ (អ្នកលក់ដូរតាមដងផ្លូវ អ្នកបម្រើការងារតាមផ្ទះ និងកម្មករនិយោជិកនៅក្នុងវិស័យទេសចរណ៍ និងកម្សាន្ត) នៅទូទាំងប្រទេសនៅឆ្នាំ២០២៣។
- អង្គការ API បានគាំទ្រដល់អង្គការសង្គមស៊ីវិល (CSOs) ជាច្រើននៅក្នុងប្រទេសកម្ពុជា និងទូទាំងតំបន់ដើម្បីរៀនសូត្រ និងចែករំលែកចំណេះដឹងជុំវិញប្រធានបទកិច្ចគាំពារសង្គម។
- អង្គការ API បានផ្តល់ធាតុចូលដល់សេចក្តីព្រាងច្បាប់កិច្ចគាំពារសង្គម និងកម្មវិធីជាតិគាំពារសង្គម របស់រដ្ឋាភិបាលសម្រាប់ជនមានពិការភាព និងមនុស្សវ័យចាស់ ក៏ដូចជាអ្នកលក់ដូតាមដងផ្លូវដែលមិន ត្រូវបានបញ្ចូលនៅក្នុងកញ្ចប់នៃសេវាជំនួយសង្គម។

## ៥. អង្គការ API បានចូលរួមក្នុងគណៈកម្មាធិការបច្ចេកទេសនៃក្រុមការងារគណនេយ្យភាពសង្គម (ISAF)

- អង្គការ API បានចូលរួមកិច្ចប្រជុំនៃក្រុមការងារបច្ចេកទេស ISAF យ៉ាងទៀងទាត់ និងបានបញ្ចប់គោលការណ៍ណែនាំប្រតិបត្តិការផ្ទេកតម្រូវការ ISAF សម្រាប់កម្រិត ក្រុង ស្រុក ខណ្ឌ(DMK)។
- អង្គការ API បានផលិតគោលការណ៍ណែនាំបច្ចេកទេស និងដឹកនាំបានដោយជោគជ័យនូវគម្រោងសាកល្បងស្តីពីកិច្ចគាំពារសង្គមក្នុងក្របខ័ណ្ឌគណនេយ្យភាពសង្គម (ISAF) នៅក្នុងសង្កាត់ចំនួន 06 ក្នុងរាជធានីភ្នំពេញ។ ជាលើកដំបូងនៅក្នុងប្រទេសកម្ពុជា កិច្ចគាំពារសង្គម (សេវាសង្គម) បានសាកល្បងអនុវត្តនឹងបានប្រមូលនូវមតិកែលំអពីប្រជាពលរដ្ឋតាមរយៈការអនុវត្តក្របខ័ណ្ឌគណនេយ្យភាពសង្គមឆ្នាំ២០២២ - ២០២៣ ក្នុងគម្រោងសំឡេងពលរដ្ឋដើម្បីសេវាគាំពារសង្គមកាន់តែប្រសើរឡើងតាមរយៈការអនុវត្តផែនការគណនេយ្យភាពសង្គម I-SAF នៅខណ្ឌសែនសុខសម្រាប់ការកែលម្អសេវាគាំពារសង្គមជូនដល់ប្រជាពលរដ្ឋប្រមាណ 1,000នាក់ ជាជនមានពិការភាព ចាស់ជរា និងគ្រួសារក្រីក្រមានប័ណ្ណសមធម៌ នៅទីក្រុងភ្នំពេញ ។
- អង្គការ API បានបណ្តុះបណ្តាល និងកៀរគរអ្នកដឹកនាំជនមានពិការភាព ចាស់ជរា និងសមាគមគ្រួសារក្រីក្រមានប័ណ្ណសមធម៌ ដើម្បីតស៊ូមតិសម្រាប់កិច្ចគាំពារសង្គមក្នុងកិច្ចសន្ទនាគោលនយោបាយកំរិតថ្នាក់ជាតិដោយផ្អែកលើបទពិសោធន៍ ដែលបានពីការចូលរួមជាមួយគ្នានៃគម្រោងនៅក្នុងខណ្ឌសែនសុខ។ រដ្ឋាភិបាលបានចាប់អារម្មណ៍ក្នុងការស្វែងយល់បន្ថែមអំពីរបៀបនៃកិច្ចគាំពារសង្គមអាចត្រូវបានបញ្ជ្រាបទៅក្នុងក្របខ័ណ្ឌគណនេយ្យភាពសង្គម និងដើម្បីពង្រីកទៅតំបន់ដទៃទៀត។
- អង្គការ API បានបង្កើតគោលការណ៍ណែនាំប្រតិបត្តិស្តីពីពិការភាព និងបរិយាប័ន្នសង្គមនៅក្នុង ISAF ដែលគាំទ្រដោយគណៈកម្មាធិការគ្រប់គ្រងការអនុវត្តផែនការយុទ្ធសាស្រ្តគណនេយ្យភាពសង្គម (គ.គ.អ.ស./PSC) និងរដ្ឋាភិបាល ដើម្បីពង្រឹងការអនុវត្ត ISAF សម្រាប់បរិយាប័ន្នសង្គមឱ្យកាន់តែទូលាយនៅគ្រប់ទិដ្ឋភាព និងវដ្ត ISAF ពេញលេញ រួមទាំងការបញ្ចូលការកសាងសមត្ថភាព ការអនុវត្ត ការត្រួតពិនិត្យ ការវាយតម្លៃ និងការរាយការណ៍។

## ៦. ក្រុមការងារសិទ្ធិឌីជីថល (DRWG)





- អង្គការ API បានចូលរួមក្នុងនាមជាសមាជិកស្នូលជាមួយក្រុមការងារសិទ្ធិឌីជីថលដែរបានចូលរួម ពីអង្គការសង្គមស៊ីវិលចំនួន ១៤ ដើម្បីស្វែងរកមតិគាំទ្រសម្រាប់សិទ្ធិឌីជីថល និងសេរីភាពអ៊ីនធឺណិត ដូចជាអនុក្រឹត្យស្តីពីច្រកចេញចូលអ៊ីនធឺណិត។

- អង្គការ API បានកសាងសមត្ថភាពទៅដល់សមាជិកក្រុមការងារលើប្រធានបទការត្រួតពិនិត្យសេរីភាព សុវត្ថិភាព និង តស៊ូមតិលើបណ្តាញអនឡាញ។
- អង្គការ API បានសរសេរ និងចេញផ្សាយរបាយការណ៍ត្រួតពិនិត្យអ៊ីនធឺណេតកម្ពុជាលើកទីពីរ ក្នុងឆ្នាំ២០២៣។ ការរកឃើញបានបញ្ជាក់ថា មានគេហទំព័រចំនួន៤៣ ត្រូវបានបិទ ក្នុងឆ្នាំ២០២២ និងគេហទំព័រចំនួន៣៦ ត្រូវបានបិទនៅឆ្នាំ២០២៣។ របាយការណ៍ស្តីពីការត្រួតពិនិត្យអ៊ីនធឺណិត នៅកម្ពុជាបានបង្ហាញពីភស្តុតាងនៃការរឹតត្បិតអ៊ីនធឺណិត និងប្រើជាឯកសារយោងនៅក្នុងរបាយ ការណ៍ជាសកលឆ្នាំ2023។
- អង្គការ API បានបញ្ជូនរបាយការណ៍ត្រួតពិនិត្យអ៊ីនធឺណិតកម្ពុជាក្នុងឆ្នាំ២០២២ - ២០២៣ និងរបាយការណ៍ត្រួតពិនិត្យជាសកល (UPR) ទៅកាន់ដៃគូអភិវឌ្ឍន៍ ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ កិច្ចអភិវឌ្ឍន៍អន្តរជាតិ និងរដ្ឋសមាជិកសហភាពអឺរ៉ុប ប្រព័ន្ធផ្សព្វផ្សាយ និងសាធារណជន ព្រមទាំងទៅកាន់ ទីស្នាក់ការសិទ្ធិមនុស្សអង្គការសហប្រជាជាតិនៅទីក្រុងហ្សឺណែវ ដែលជាផ្នែកនៃ ដំណើរការពិនិត្យរបាយការណ៍ត្រួតពិនិត្យជាសកល (UPR) សម្រាប់កម្ពុជានៅឆ្នាំ២០២៤។

## ៧. ក្រុមការងារប្រឆាំងអំពើពុករលួយ

កិច្ចប្រជុំប្រចាំខែរបស់ក្រុមការងារអង្គការសង្គមស៊ីវិលដែលធ្វើឡើងនៅរៀងរាល់ថ្ងៃទី២២ នៃខែនីមួយៗ បានគាំទ្រក្រុមការងារប្រឆាំងអំពើពុករលួយ ដើម្បីធ្វើបច្ចុប្បន្នភាពសេចក្តីព្រៀងរបាយការណ៍ថវិកាពលរដ្ឋសម្រាប់ កម្ពុជាឆ្នាំ២០២៣ បានសរសេររបាយការណ៍ត្រួតពិនិត្យជាសកល ស្តីពី ការប្រឆាំងអំពើពុករលួយឆ្នាំ២០២៣ ហើយដាក់ជូនទីស្នាក់ការអង្គការសហប្រជាជាតិ។

## ៨. គណៈកម្មាធិការសហប្រតិបត្តិការសម្រាប់កម្ពុជា (CCC)

បានតស៊ូមតិសម្រាប់បង្កើតបរិយាកាសងាយស្រួលមួយដែលអាចឱ្យអង្គការសហគមន៍មូលដ្ឋានធ្វើការជាមួយដៃគូអភិវឌ្ឍន៍ (EU, EU member states, SIDA, SDC, Australian Embassy, INGOs, និងផ្សេងៗទៀត).

**លទ្ធផលទី២**

## ដើម្បីលើកកម្ពស់ភាពអង់អាចរបស់ប្រជាពលរដ្ឋជាពិសេសយុវជនក្រុមស្ត្រីនិងក្រុមដែលងាយរងគ្រោះ ចង់ឱ្យរដ្ឋាភិបាលមានគណនេយ្យភាព ចំពោះការ សម្រេចចិត្ត និងសកម្មភាពឆ្លើយតបដើម្បីកែលម្អសេវាកម្មសាធារណៈ និងការអនុវត្ត គោលយោបាយនៅថ្នាក់ក្រោមជាតិ

**គម្រោងទី៣**

## សំឡេង និងសកម្មភាពរបស់ប្រជាពលរដ្ឋសម្រាប់ការអភិវឌ្ឍប្រកបដោយ និរន្តរភាព នៅកម្ពុជា ដំណាក់កាលទី១ បានបញ្ចប់នៅឆ្នាំ២០២២ និងបន្តដំណាក់ កាលទី២ ពីឆ្នាំ២០២៣ ដល់ឆ្នាំ២០២៥

**គោលបំណងនៃគម្រោង៖** ដើម្បីបំពេញសិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការចូលរួមសម្រាប់ការអភិវឌ្ឍប្រកបដោយ និរន្តរភាពនៅក្នុងប្រទេសកម្ពុជា។

**គាំទ្រថវិកាដោយ៖** ៧៥០.០០០ អឺរ៉ូ គាំទ្រថវិការដោយអង្គការ ប្រេដ ហ្វ័រ ដឺ វើល( BfdW) និងជំនួយព្រះវិហារដាណឺម៉ាក (DCA)។

**តំបន់គោលដៅសម្រាប់អនុវត្តគម្រោងមាន៖** ក្រុង ស្រុក ខណ្ឌ ចំនួន ១១ ដែលមានរាជធានី ខេត្តចំនួន ០៦ រួមមាន រាជធានីភ្នំពេញ ខេត្តពោធិ៍សាត់ ខេត្តបន្ទាយមានជ័យ ខេត្តកំពង់ធំ ខេត្តក្រចេះ និងខេត្តកំពង់ស្ពឺ។

### លទ្ធផល៖

**ពង្រឹងការចូលរួមរបស់ប្រជាពលរដ្ឋនៅក្នុងអភិបាលកិច្ចមូលដ្ឋាន ជាពិសេសស្ត្រី យុវជន ជនជាតិដើមភាគតិច និងជនមានពិការភាពជាមួយនឹងលទ្ធផលដូចខាងក្រោម៖**

- ៦២% ត្រូវបានដោះស្រាយ (បញ្ហាតស៊ូមតិចំនួន ០៦ ត្រូវបានដោះស្រាយដោយជោគជ័យដែលមាន ១២% លើការកាប់បំផ្លាញព្រៃឈើ បទល្មើសព្រៃឈើ និងការទន្ទ្រានយកដី កង្វះបច្ចេកទេសលាយដី និងដីដាំបន្លែ)។
- បញ្ហាតស៊ូមតិចំនួន ២៥ ក្នុងចំណោម ៥០ ត្រូវបានដោះស្រាយបានខ្លះដោយ ៥០% លើវិវាទដីធ្លីគ្មាន ក្រមសីលធម៌សម្រាប់អ្នកផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍ បញ្ហារដ្ឋបាលឃុំមិនបង្ហាញព័ត៌មានថវិកា (ថវិកាឃុំ) ជាសាធារណៈ បញ្ហានេសាទខុសច្បាប់ បញ្ហាកាប់ព្រៃឈើ និងការទន្ទ្រានយកដីសហគមន៍។
- ៤០% នៃសមាជិកអង្គការសហគមន៍ត្រូវបានចូលរួមយ៉ាងហោចណាស់យន្តការចូលរួមរបស់ប្រជាពលរដ្ឋចំនួន ០៣ មានដូចជា៖ ការចូលរួមវេទិកាសាធារណៈ ស្តីពី ព័ត៌មានថវិកាក្រុង ស្រុក ព័ត៌មានថវិកាឃុំ សង្កាត់ និងកិច្ចប្រជុំនៅកម្រិតថ្នាក់ក្រុង ស្រុកចំនួន ០៤ (ក្រុងសិរីសោភ័ណ និងស្រុកមង្គលបូរី ក្នុងខេត្តបន្ទាយមានជ័យ ក្រុងពោធិ៍សាត់ និងស្រុកភ្នំក្រវាញ ក្នុងខេត្តពោធិ៍សាត់)។
- ៣០% នៃប្រធាន ឬតំណាងសហគមន៍បានចូលរួមជាមួយអាជ្ញាធរមូលដ្ឋាន។ ប្រធាន ឬតំណាងសហគមន៍ចំនួន ១៨នាក់ (ស្ត្រី ២២%) ដែលបានចូលរួមវេទិកាសាធារណៈ និងកិច្ចប្រជុំជាមួយរដ្ឋបាលក្រុង ស្រុក និងបានលើកឡើងពីបញ្ហាក្នុងអំឡុងពេលវេទិកាសាធារណៈ។ យុវជនបានចូលរួមវេទិកាសាធារណៈ និងជួបប្រជុំជាមួយរដ្ឋបាលក្រុង ស្រុក និងបានលើកឡើងពីបញ្ហានានាអំឡុងពេលវេទិកាសាធារណៈផងដែរ។

**ធ្វើឱ្យប្រសើរឡើងនូវតម្លាភាព និងការទទួលបានព័ត៌មាននៅថ្នាក់ជាតិស្តីពីថវិកា លទ្ធកម្ម និងព័ត៌មានឯកសារសម្បទានដីសេដ្ឋកិច្ច (ELCs) និងការវាយតម្លៃផល ប៉ះពាល់បរិស្ថាន និងសង្គម (ESIAs):**

- ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចចំនួនពីរ (ELCs) បានបង្ហាញព័ត៌មានសំខាន់ៗ នៅក្នុងក្រុង ស្រុក គោលដៅ។
- រដ្ឋបាលស្រុកបានបើកចំហព័ត៌មានស្តីពីចំណូល និងចំណាយថវិកាឆ្នាំ២០២២ និងថវិកាឆ្នាំ២០២៣ និងសម្បទានដីសេដ្ឋកិច្ចដល់សមាជិកសហគមន៍ ក្នុងស្រុកចិត្របុរី ខេត្តក្រចេះ។
- រដ្ឋបាលស្រុកបានធ្វើវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ផ្សព្វផ្សាយព័ត៌មានថវិកាស្រុកដល់ សមាជិក សហគមន៍អំពីចំណូល និងចំណាយ ក្នុងឆ្នាំ២០២២ និង២០២៣ នៅស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ។
- របាយការណ៍ ស្តីពី វេទិកាសម្បទានដីសេដ្ឋកិច្ច (ELCs) នៅខេត្តក្រចេះ និងខេត្តកំពង់ធំ។

- ផែនការលទ្ធកម្មសរុបចំនួន ៣៣ ក្នុងចំណោម ៨៣ (៤៥%) នៃក្រសួងគោលដៅចំនួន ០៤ បានបង្ហាញ៖ ការប្រកាសអំពីលក្ខណៈបច្ចេកទេសនៃគម្រោងលទ្ធកម្មការ ប្រកាសលទ្ធផល និងបញ្ជី ឈ្មោះក្រុមហ៊ុន ដែលទទួលបានជោគជ័យក្នុងការដេញថ្លៃគម្រោង និងតម្លៃនៃគម្រោង លទ្ធកម្ម មិនមានព័ត៌មានលម្អិតអំពីកិច្ចសន្យានោះទេ។
- អង្គការ API បានពង្រឹងសិទ្ធិអំណាចដល់សហគមន៍ជាង ៥០សហគមន៍ ដែលមានប្រធាន ២៥០នាក់ (ស្ត្រី ៧០%) សមាជិកសហគមន៍ត្រូវបានបែងចែកជាប្រភេទផ្សេងៗគ្នា ក្រីក្រប្រហែល ៥០០គ្រួសារ មនុស្សចាស់ ១.០០០នាក់ យុវជន ៥០០នាក់ ជនមានពិការភាព ១.០០០នាក់ ស្ត្រី ៤០០នាក់ មកពី ក្រុមអ្នកលក់ដូរតាមដងផ្លូវប្រជាជនសហគមន៍ចំនួន ២០.០០០នាក់ (ជនជាតិដើមភាគតិច ៣០% ស្ត្រី ៧០% យុវជន ៦០%) អង្គការសហគមន៍ដែលធ្វើការលើការគ្រប់គ្រងធនធានធម្មជាតិ។ ក្រុមគោលដៅទាំងអស់នេះ ត្រូវបានពង្រឹងសិទ្ធិអំណាចដើម្បីបង្ហាញនូវក្តីកង្វល់របស់ពួកគេ និងធ្វើឱ្យរដ្ឋាភិបាលទទួលខុសត្រូវក្នុងការដោះស្រាយបញ្ហាសហគមន៍ និងធ្វើឱ្យប្រសើរឡើងនូវសេវាសាធារណៈ ដូចជា កិច្ចគាំពារសង្គម សុខភាព ការអប់រំ សេវារដ្ឋបាលជិត ៣០០ឃុំ និង ៥០ក្រុង ស្រុក ក្នុងខេត្តចំនួន ១១។
- អង្គការ API បានកៀរគរ និងពង្រឹងសមត្ថភាពប្រជាពលរដ្ឋចំនួន ៣០៨នាក់ ក្នុងនោះមានស្ត្រី ៩៨នាក់ រួមបញ្ចូលទាំងយុវជន ជនជាតិដើមភាគតិច និងជនមានពិការភាពដើម្បីចូលរួមក្នុង អភិបាលកិច្ចមូលដ្ឋាន។ ពួកគេបានលើកបញ្ហាចំនួន ៥០ ដែលក្នុងនោះ ២៥ បញ្ហា ត្រូវបានដោះ ស្រាយបានខ្លះនិង ០៦ បញ្ហា ត្រូវបានដោះស្រាយដោយជោគជ័យ។
- សមាជិកសហគមន៍ចំនួន ៧៤នាក់ ស្ត្រី ២១១នាក់ បានបង្កើនសមត្ថភាពរបស់ពួកគេ ក្នុងការទទួលបានព័ត៌មានអំពីការអភិវឌ្ឍមូលដ្ឋាន ការអនុវត្តការងារនៅក្នុងរដ្ឋបាលឃុំ និងស្រុក។ សហគមន៍ចំនួន ៥៣ បានលើកឡើងនូវបញ្ហា និងតម្រូវរបស់ពួកគេទៅកាន់អាជ្ញាធរ ដើម្បីពង្រឹងការ គ្រប់គ្រងផ្ទៃក្នុង ការប្រព្រឹត្តទៅ និងធ្វើឱ្យប្រសើរឡើងនូវតម្លាភាពរបស់ឃុំ និងស្រុកគោលដៅ និងការទទួលបានព័ត៌មានស្តីពីថវិកាលទ្ធកម្ម សម្បទានដីសេដ្ឋកិច្ច(ELCs) និងការវាយតម្លៃផល ប៉ះពាល់ បរិស្ថានសង្គមសេដ្ឋកិច្ច(ESIAs)។
- ក្នុងអំឡុងពេលធ្វើផែនការសកម្មភាពអាទិភាពបន្ទាប់នៅក្នុងសិក្ខាសាលាឆ្លុះបញ្ចាំងប្រចាំឆ្នាំអង្គការ API បានពិគ្រោះជាមួយអ្នកចូលរួមចំនួន ៣៥នាក់ ស្រី ១២នាក់ពីដៃគូអភិវឌ្ឍន៍ ម្ចាស់ជំនួយ អង្គការសង្គមស៊ីវិលក្នុងស្រុក សហគមន៍មូលដ្ឋាន អាជ្ញាធរមូលដ្ឋាន និងស្ថាប័នរដ្ឋាភិបាលដើម្បី ប្រមូលផ្តុំ និងពិភាក្សាអំពីធាតុចូលសម្រាប់យុទ្ធសាស្ត្ររបស់អង្គការ API ថ្មីឆ្នាំ ២០២៤ ដល់ឆ្នាំ ២០២៨ និងដើម្បីផ្សព្វផ្សាយការយល់ដឹងកាន់តែស៊ីជម្រៅអំពីការប្រើប្រាស់ឧបករណ៍បច្ចេកវិទ្យា និងរបាយការណ៍ ស្តីពី ថវិកាថ្នាក់ក្រោមជាតិ និងសេវាច្រកចេញចូលតែមួយ។ អង្គការ API បានបង្ហាញ ពីបញ្ហាប្រឈមសំខាន់ៗ មេរៀនបទពិសោធន៍ និងសមិទ្ធិផលនានា។
- អ្នកចូលរួមចំនួន ៥១នាក់ ស្រី ១៨នាក់ មកពីអង្គការក្រៅរដ្ឋាភិបាលចំនួន ៥០ និងប្រធាន ក្រុមប្រឹក្សាថ្នាក់មូលដ្ឋានចំនួន ០១នាក់ បានពិភាក្សាអំពីយន្តការសម្រាប់ប្រសិទ្ធភាពការងារ ភាពជាដៃគូអភិវឌ្ឍន៍ ពហុវិស័យ និងអនុវិស័យនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

## សកម្មភាព៖

- របាយការណ៍សិក្សាស្ថានភាពដើមគម្រោងត្រូវបានបញ្ចប់។
- បានធ្វើបច្ចុប្បន្នភាពកម្មវិធីឧបករណ៍វិភាគថវិកាសម្រាប់ប្រជាពលរដ្ឋទៅកាន់ AppStore។ តំណភ្ជាប់ ឧបករណ៍វិភាគថវិកា៖ https://citizenbudget.apiinstitute.org/
- បានគាំទ្រដំណើរការរបស់សហគមន៍ជាមួយប្រធានសហគមន៍ចំនួន ៧៤នាក់ (ស្រី ២១នាក់) ដើម្បីបង្កើនសមត្ថភាពរបស់ពួកគេ និងការទទួលបានព័ត៌មានបន្ថែមដែលពាក់ព័ន្ធទៅនឹងការអភិវឌ្ឍ មូលដ្ឋាន និងការអនុវត្តមុខងាររបស់ឃុំ និងស្រុក។
- បានគាំទ្រដល់ការអនុវត្តផែនការសកម្មភាពតស៊ូមតិរបស់សហគមន៍មូលដ្ឋានតាមរយៈកិច្ចប្រជុំ ពិភាក្សាជាមួយអភិបាលក្រុង ស្រុក ដែលសហគមន៍បានលើកឡើងពីបញ្ហា ឬក្តីកង្វល់របស់ពួកគេ។
- បានពិនិត្យឡើងវិញ និងការកែសម្រួលនៃសេចក្តីណែនាំស្តីពីការពង្រឹងសមត្ថភាពដល់សហគមន៍ មូលដ្ឋាន និងយុទ្ធសាស្ត្រភាពជាដៃគូដោយទទួលបានមតិយោបល់ពីម្ចាស់ជំនួយ។
- សហការរៀបចំវេទិកាសាធារណៈថ្នាក់ជាតិ ស្តីពី "ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការរៀបចំថវិកា និងការត្រួតពិនិត្យលើដំណើរការចំណូល និងចំណាយថវិកាសាធារណៈ" ដែលមានអ្នកចូលរួមចំនួន ១៣០នាក់ ស្រី ៦២នាក់។

- គាំទ្រការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គមរបស់រដ្ឋបាលក្រុង ស្រុក សម្រាប់ការផ្សព្វផ្សាយព័ត៌មាន សកម្មភាពនានា និងការទទួលយកមតិយោបល់សាធារណៈចំនួន ៧ដងក្នុង ស្រុកសណ្ដាន់ ខេត្តកំពង់ធំ និងក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ។
- បានធ្វើការឆ្លុះបញ្ចាំងជាទៀងទាត់ និងចែករំលែកការអនុវត្តល្អក្នុងចំណោមគោលដៅក្រុងស្រុក និងពានរង្វាន់ការអនុវត្តល្អប្រចាំឆ្នាំដល់ក្រុង ស្រុកដែលយល់ដឹងល្អពីការប្រើប្រាស់ឧបករណ៍បច្ចេកវិទ្យាស្ដីពីថវិកាថ្នាក់ក្រោមជាតិ និងសេវាច្រកចេញចូលតែមួយ។
- ការសម្របសម្រួលសម្រាប់កិច្ចសន្ទនារវាង សហគមន៍ ប្រជាពលរដ្ឋ និងរដ្ឋបាលក្រុង ស្រុក។ អាជ្ញាធរ មូលដ្ឋាន និងអង្គការមិនមែនរដ្ឋាភិបាលចំនួន ៥០ បានយល់ច្បាស់អំពីគោលគំនិតនៃយន្តការសម្រាប់ប្រសិទ្ធភាពការងារភាពជាដៃគូអភិវឌ្ឍន៍ពហុវិស័យ។
- បានធ្វើរបាយការណ៍វិភាគគោលនយោបាយមួយស្តីពីរបាយការណ៍វិភាគព័ត៌មានថវិកាដោយជោគ-ជ័យសម្រាប់ជាភស្តុតាងក្នុងការតស៊ូមតិ។
- សម្របសម្រួលការសន្ទនាគោលនយោបាយចំនួន ០២ និងការជជែកដេញដោលរបស់យុវជននៅ ថ្នាក់ជាតិ ដើម្បីលើកបញ្ហាដែលមិនអាចដោះស្រាយបាននៅថ្នាក់មូលដ្ឋានលើសេចក្ដីព្រាងច្បាប់ស្ដីពី លទ្ធកម្មសាធារណៈ និងបទប្បញ្ញត្តិពាក់ព័ន្ធ និងសិទ្ធិទទួលបានព័ត៌មាន និងសារៈសំខាន់តាមវិស័យ សម្រាប់សម្បទានដីសេដ្ឋកិច្ច ឬការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

## មេរៀនដែលបានរៀននៅក្នុងគម្រោង៖

នៅពេលដែលសហគមន៍អាចបង្កើតផែនការសកម្មភាពតស៊ូមតិដោយមានគោលបំណង និងសកម្មភាពច្បាស់លាស់ ដូច្នេះពួកគេធ្វើការតស៊ូមតិកាន់តែជោគជ័យបាន។

## បញ្ហាប្រឈមក្នុងគម្រោង៖

ថវិកាក្រុង ស្រុក និងឃុំ សង្កាត់ មិនត្រូវបានវិភាជន៍ទៅផ្នែកធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុទេ។ ដូច្នេះសហគមន៍ព្រៃឈើមិនត្រូវបានគាំទ្រដោយរដ្ឋាភិបាលដើម្បី អនុវត្តសកម្មភាពនោះទេ។

## ផែនការក្នុងឆ្នាំ២០២៤៖

- ផ្ដល់ការពង្រឹងសមត្ថភាពដល់សហគមន៍។
- ពង្រឹងដំណើរការ ឬការបណ្ដុះបណ្ដាលសហគមន៍ក្នុងការបង្កើតផែនការសកម្មភាពសហគមន៍។
- គាំទ្រសហគមន៍ក្នុងការអនុវត្តផែនការសកម្មភាពតស៊ូមតិ។
- ប្រជុំប្រចាំត្រីមាសប្រជុំឆ្លុះបញ្ចាំងការចែករំលែកអំពីការអនុវត្តល្អពានរង្វាន់ការអនុវត្តល្អប្រចាំឆ្នាំ និងការវាយតម្លៃលើការតស៊ូមតិរបស់សហគមន៍។
- ការកសាងសមត្ថភាពរបស់សមាជិកក្រុមប្រឹក្សាក្រុង ស្រុក ដែលទើបជាប់ឆ្នោតថ្មី និងមន្ត្រីក្រុង ស្រុក ស្តីពីសិទ្ធិពលរដ្ឋ និងការចូលរួមរបស់ប្រជាពលរដ្ឋ ការបង្ហាញព័ត៌មានស្តីពីថវិកា និងលទ្ធកម្ម សាធារណៈ។
- គាំទ្រការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គមរបស់រដ្ឋបាលក្រុង ស្រុក សម្រាប់ការបង្ហាញព័ត៌មានសកម្ម និងមតិត្រឡប់ជាសាធារណៈ។
- គាំទ្រសកម្មភាពក្រុង ស្រុក លើយន្តការការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការថវិកា និងលទ្ធកម្ម សាធារណៈ។
- កិច្ចប្រជុំឆ្លុះបញ្ចាំងសម្រាប់ការចែករំលែកការអនុវត្តល្អតាមរយៈអ៊ីនធឺណិត។
- កំណត់អត្តសញ្ញាណ និងបណ្ដុះបណ្ដាលអ្នកស្ម័គ្រចិត្តសម្រាប់យុទ្ធនាការផ្សព្វផ្សាយ និងការត្រួត ពិនិត្យលើលទ្ធកម្មសាធារណៈ។
- យុទ្ធនាការលើកកម្ពស់ការយល់ដឹងជាសាធារណៈដោយការផ្សព្វផ្សាយបែបបុរាណ និងការប្រើប្រាស់ ឧបករណ៍បច្ចេកវិទ្យា។

- ពង្រឹងសមត្ថភាព និងកិច្ចសហប្រតិបត្តិការនៃក្រុមការងារសិទ្ធិទទួលបានព័ត៌មាន (A2IWG) និងបណ្តាញរបស់អង្គការសង្គមស៊ីវិល។ល។

**ករណីសិក្សាទី១៖** សិទ្ធិ និងសមត្ថភាពរបស់សហគមន៍កសិកម្មដប់បាតអភិវឌ្ឍន៍ក្នុងការស្វែងរកដំណោះស្រាយតាមរយៈកិច្ចប្រជុំថ្នាក់ក្រុង ស្ថិតនៅក្នុងក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់




ចាប់តាំងពីឆ្នាំ២០០៧ **សហគមន៍កសិកម្មដប់បាតអភិវឌ្ឍន៍** មិនមានបច្ចេកទេសលាយជីទឹកសម្រាប់ដាំបន្លែបានឡើយ ដែលនាំឱ្យទិន្នផលដែលទទួលបានទាប និងកង្វះបច្ចេកទេសចិញ្ចឹមមាន់ និងត្រីផងដែរ។ សហគមន៍របស់ពួកគេគ្របដណ្តប់លើតំបន់មួយដែលមានភូមិចំនួន ០៤ លើផ្ទៃដី ១៧ ហិចតា មានប្រជាជន ៦៨គ្រួសារ ក្នុងនោះមានគណៈកម្មាការ ០៨រូប ។ ទិន្នផលទាបប៉ះពាល់ដល់ប្រជាពលរដ្ឋ ដែលដាំបន្លែ។ ប្រសិនបើបន្លែត្រូវបានដាំដុះតាមវិធីសាស្ត្រទំនើប នោះទិន្នផលក៏អាចនឹងខ្ពស់ ហើយអាចផ្តល់ចំណូលល្អប្រសើរមួយផងដែរ។ បញ្ហានេះត្រូវបានរាយការណ៍ទៅមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអភិបាលក្រុងពោធិ៍សាត់ ប៉ុន្តែមិនទទួលបានដំណោះស្រាយ។ ប្រធាន និងតំណាងសហគមន៍បានស្នើសុំការគាំទ្រផ្នែកបច្ចេកទេស និងជួយប្រមូលព័ត៌មាន ដើម្បីរៀបចំផែនការសម្រាប់អ្នកចូលរួមក្នុង វេទិកាសាធារណៈ កិច្ចប្រជុំប្រចាំខែរបស់រដ្ឋបាលក្រុង និងសង្កាត់ ដើម្បីលើកបញ្ហាប្រឈម និងស្វែងរកដំណោះស្រាយនៅថ្នាក់ក្រោមជាតិ បន្ទាប់ពីពួកគេបានទទួលការបណ្តុះបណ្តាល និងការបង្វឹក។ អង្គការ API បានរៀបចំកិច្ចប្រជុំពិភាក្សាថ្នាក់ក្រុងជាមួយភាគីពាក់ព័ន្ធ។ ជាលទ្ធផលសហគមន៍បានទទួលការបណ្តុះ បណ្តាលពីមន្ត្រីកសិកម្ម និងទទួលបានគ្រាប់ពូជបន្លែពីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ឥឡូវនេះមន្ទីរកសិកម្ម និងរដ្ឋបាលក្រុងបានសហការណ៍ជាមួយការិយាល័យពាក់ព័ន្ធ និងអង្គការក្រៅរដ្ឋាភិបាល ដើម្បីផ្តល់ការបណ្តុះបណ្តាលដល់សហគមន៍លើការដាំដុះ និងការចិញ្ចឹមសត្វ។

នៅដើមឆ្នាំ២០២៣ អង្គការ ADRA បានចាប់ផ្តើមអនុវត្តគម្រោងដែលមានទីតាំងនៅស្រុកភ្នំក្រវាញ ប៉ុន្តែមិនអាចស្វែងរកសហគមន៍ដែលជាអ្នកទទួលផលបានទេ។ អង្គការ API និងរដ្ឋបាលក្រុងពោធិ៍សាត់ ព្រមទាំងមន្ទីរកសិកម្មបានសហការ នឹងសម្របសម្រួលឱ្យសហគមន៍កសិកម្មដប់បាតអភិវឌ្ឍន៍ បានក្លាយជា ក្រុមគោលដៅរបស់អង្គការ ADRA។ សមាជិករបស់សហគមន៍កសិកម្មដប់បាតអភិវឌ្ឍន៍ បានបន្តទទួលវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពលើប្រធានបទផ្សេងៗ រួមទាំងការធ្វើផែនការអាជីវកម្ម ភាពជាអ្នកដឹកនាំ ផែនការទីផ្សារ និងបច្ចេកទេសកសិកម្មដូចជា ការប្រើប្រាស់ជី ការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិតជាដើម។ សហគមន៍ក៏ត្រូវបានផ្តល់ប្រាក់ចំនួន ៣.០០០ ដុល្លារអាមេរិកដើម្បីធ្វើជាដើមទុនផងដែរ។

**ករណីសិក្សាទី២៖** សំឡេងរបស់ស្ត្រីមានផលជះលើជីវភាពរស់នៅរបស់គ្រួសារ



**សហគមន៍ព្រៃឈើគល់ទទឹង** ជាតំបន់គោលដៅរបស់គម្រោងដែលស្ថិតនៅក្នុងភូមិក្សេតបូរី ឃុំ សន្ទ្រែ ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់។ សហគមន៍នេះត្រូវបានបង្កើតឡើងក្នុង ឆ្នាំ២០១៦ ដែលមានសមាជិកសរុបចំនួន ២៧០នាក់ ក្នុងនោះ ២១០នាក់ ជាស្ត្រី។ សហគមន៍ព្រៃឈើគល់ទទឹង ត្រូវបានបង្កើតឡើងក្នុងគោលបំណង លើកកម្ពស់ការគ្រប់គ្រង និងការការពារធនធានធម្មជាតិ រួមចំណែក កាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់ជីវភាពរស់នៅតាមរយៈការប្រើប្រាស់អនុផលព្រៃឈើប្រកបដោយនិរន្តរភាពដែលមានការគាំទ្រយ៉ាងសកម្មពីរដ្ឋបាលព្រៃឈើក្នុងការត្រួតពិនិត្យ និងដោះស្រាយបញ្ហា។ បញ្ហា

ប្រឈម ក្នុងសហគមន៍រួមមាន ការមិនមានថវិកាសម្រាប់គាំទ្រក្នុងការចុះល្បាត ការទប់ស្កាត់បទល្មើស និងការទន្ទ្រានដីព្រៃសហគមន៍។ ទោះជាយ៉ាងណាក៏ដោយបញ្ហាដែលកើតឡើងក្នុងខែមេសា ឆ្នាំ២០២០ នៅពេល ដែលក្រុមហ៊ុន PP-MixCom បានរំលោភយកដីចំនួន ៤០ ហិចតា របស់ប្រជាពលរដ្ឋចំនួន ៣០គ្រួសារ នៅក្នុងភូមិក្បែតបូរី ឃុំសន្ត្រែ ដែលបណ្តាលឱ្យប្រជាពលរដ្ឋបាត់បង់ឱកាសក្នុងការធ្វើស្រែចំការ ឬផលិតស្រូវ អង្ករ ដើម្បីរកប្រាក់ចំណូលសម្រាប់ផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃ។ បញ្ហានេះមិនទាន់មានការ អន្តរាគមន៍ពីអាជ្ញាធរ មូលដ្ឋានដល់សហគមន៍នៅឡើយទេ។ រហូតមកដល់ខែសីហា ឆ្នាំ២០២១ ប្រជាពលរដ្ឋទាំង ៣០គ្រួសារ បានដាក់សំណើទៅរដ្ឋបាលឃុំដើម្បីដោះស្រាយការទន្ទ្រានយកដីនៅភូមិក្បែតបូរី ឃុំសន្ត្រែ ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់។ ជាលទ្ធផលតំណាងក្រុមហ៊ុន និងប្រជាពលរដ្ឋពាក់ព័ន្ធរួមទាំងអាជ្ញាធរ ឃុំ ស្រុក បានជួបជាមួយភាគីពាក់ព័ន្ធដើម្បីព្យាយាមដោះស្រាយបញ្ហានេះ។ ក្រុមហ៊ុនបានប្រគល់ដីដល់ប្រជារដ្ឋចំនួន ១០គ្រួសារ ដែលមានផ្ទៃដីសរុបចំនួន ០៦ហិចតា។ ចំណែកដី ដែលនៅសេសសល់ ៣៤ហិចតាទៀត ដែលជាបញ្ហាសម្រាប់ ២០គ្រួសារ នៅតែមិនទាន់ដោះស្រាយបាននៅឡើយទេ។

កាលពីថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២ ដីរបស់ប្រជាពល រដ្ឋចំនួន ២០គ្រួសារទៀត ត្រូវបានអ្នកម៉ៅការជនជាតិ ចិនឈ្មោះកុល រំលោភយកដីប្រជាពលរដ្ឋដោយអះ អាងថាមានកម្មសិទ្ធិលើដី និងមិនអនុញ្ញាតឱ្យប្រជាពល រដ្ឋធ្វើស្រែ និងដាំដំឡូងដូចមុនឡើយ។ បញ្ហានេះបានធ្វើ ឱ្យក្រុមគ្រួសារ ដែលរងផលប៉ះពាល់មានការខឹងសម្បារ ពួកគេបានដាក់បណ្តឹងទៅមេភូមិ និងឃុំប៉ុន្តែអាជ្ញាធរ មូលដ្ឋានមិនបានដោះស្រាយឡើយ។



បញ្ហានេះនៅតែ បន្តរហូតដល់ឆ្នាំ២០២៣។ ដោយឡែក នៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២៣ សមាជិកសហគមន៍ ព្រៃឈើគល់ទទឹងចំនួន ១០គ្រួសារ បានចូលរួមក្នុងវេទិកាសាធារណៈរបស់ឃុំ ដែលបានរៀបចំដោយអង្គការ API តាមរយៈសមាជិកសហគមន៍ព្រៃឈើគល់ទទឹង នៅឃុំសន្ត្រែ និងមានការចូលរួមពីភាគីពាក់ព័ន្ធ រួមទាំងមន្ត្រីឃុំ ស្រុក និងអ្នកពាក់ព័ន្ធផ្សេងៗទៀត។ ក្នុងឱកាសនេះអ្នកចូលរួមទាំងអស់មានឱកាសលើក ឡើងពីបញ្ហាសហគមន៍ដើម្បីឱ្យប្រជាពលរដ្ឋលើកឡើង ពីកង្វល់របស់ខ្លួនពាក់ព័ន្ធទៅនឹងដី ៣៤ហិចតា ដែល ក្រុមហ៊ុនចិនម៉ៅការទន្ទ្រានយកបណ្តាលឱ្យមានផលប៉ះពាល់ដល់ប្រជពលរដ្ឋចំនួន ២០គ្រួសារ។ ប្រជាពលរដ្ឋ មិនត្រឹមតែលើកឡើងពីទុក្ខលំបាករបស់ពួកគេទៅភាគីពាក់ព័ន្ធក្នុងវេទិកាសាធារណៈប៉ុណ្ណោះទេ លើសពីនេះ ទៅទៀតពួកគេថែម ទាំងបានបង្ហោះអត្ថបទដកស្រង់នៃការពិភាក្សាលើបណ្តាញសង្គមផងដែរ។ បញ្ហានេះបាន ធ្វើឱ្យមានការចាប់អារម្មណ៍ពីលោកអភិបាលស្រុកភ្នំក្រវាញ (លោក ហេង ផាណា) រួមទាំងមន្ត្រីពាក់ព័ន្ធក្នុងឃុំ និងស្រុក។




នៅចុងបញ្ចប់នៃវេទិកា សមាជិកក្រុមការងារឃុំ ស្រុក និងមន្ត្រីជំនាញ តំណាងក្រុមហ៊ុន និងអ្នកម៉ៅការចិន ហើយ និងអ្នកពាក់ព័ន្ធផ្សេងទៀត បានចុះទៅពិនិត្យទីតាំង ដើម្បីស្វែងរកការពិត និងផ្តួចផ្តើម ការពិភាក្សារកដំណោះ ស្រាយ។ នៅអំឡុងពេលសរសេររបាយការណ៍ពីបញ្ហារបស់ ២០គ្រួសារ បញ្ហាក៏កំពុងតែត្រូវបានដោះស្រាយជាបណ្តើរៗ ទោះជាយ៉ាងណាក៏ដោយពួកគេត្រូវការពេលវេលា បន្ថែមទៀតដើម្បីស្វែងរកដំណោះស្រាយរវាងគ្រួសារដែលរង ផលប៉ះពាល់ និងអ្នកម៉ៅការជនជាតិចិនបន្ទាប់ពីការបោះឆ្នោតរួច។ អ្នកស្រី **សេង សុខណា** អាយុ ៣៦ឆ្នាំ មានសមាជិក ៤នាក់។ អ្នកស្រី បានលើកឡើងថាគាត់សប្បាយចិត្តណាស់ដែលឃើញមានចំណាត់ការពី មន្ត្រីឃុំ និងស្រុក ចាត់ វិធានការដោះស្រាយ និងប្រគល់ដី ជូនគ្រួសារគាត់វិញ។ ផ្ទៃដីចំនួន ០៤ហិកតា របស់គាត់ត្រូវបានទន្ទ្រានកាលឆ្នាំ២០១៧។ មុននោះ គ្រួសាររបស់អ្នកស្រី អាចរកប្រាក់ចំណូលសរុបពី ៣.០០០.០០០ រៀល (៧៥០ដុល្លារ) ទៅ ៤.០០០.០០០ រៀល (១.០០០ដុល្លារ) ដោយការធ្វើស្រែ និងដំឡូងមី។ បន្ទាប់ពីបាត់បង់ដីធ្លីអ្នកស្រី និងស្វាមីត្រូវ ប្រកបការងារជាកម្មករដូជាកម្មករច្រូតកាត់ និងកម្មករសំណង់ ដោយប្រាក់ចំណូលមិនទៀងទាត់ ហើយពេលខ្លះមិនមានប្រាក់ចំណូលនោះទេ។ អស់រយៈពេលពីរឆ្នាំ កន្លងមកនេះ និងគ្រួសារ

ផ្សេងទៀត ដែលដីត្រូវក្រុមហ៊ុនរំលោភយកធ្វើឱ្យប៉ះពាល់ដល់ការចិញ្ចឹមជីវិតរបស់ពួកគាត់។ មកទល់ពេលនេះក្រុមហ៊ុន បានត្រឡប់មកវិញត្រឹមតែ ១.៥ ហិកតា ក្នុងមួយគ្រួសារ ហើយស្ថានភាពសេដ្ឋកិច្ចគ្រួសារបានធូរស្បើយ បន្តិចដោយសារការប្រគល់ដីរបស់គាត់មកវិញ។ អ្នកស្រី **សេង សុខណា** បញ្ជាក់ថាប្រសិន បើអ្នកស្រីមិនទទួលយកដី ១.៥ ហិកតា ដែលក្រុមហ៊ុនប្រគល់មកវិញទេ អ្នកស្រីនឹងមិនមានអ្វីសម្រាប់ ដាំស្រូវ និងដំឡូងមីនោះទេ។



**លោក ប៊ិន ប៊ន** មេភូមិក្សេតបូរី ឃុំសន្ទ្រែ ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ មានប្រសាសន៍ថា៖ “ខ្ញុំសប្បាយចិត្តណាស់ដែលឃើញ ប្រជាពលរដ្ឋចំនួន ១០គ្រួសារ នៅក្នុងភូមិបានទទួលដីពីក្រុមហ៊ុន PP-MIX ដើម្បីដាំដំណាំរបស់ពួកគេ”។ ករណីពលរដ្ឋ ២០ គ្រួសារទៀត ដែលត្រូវឈ្នួញចិនទន្ទ្រានយកដី នឹងត្រូវបន្តដោះស្រាយដោយ អភិបាលស្រុកដែលសន្យាជួយអន្តរាគមន៍។ លោកបានបន្តទៀតថា បញ្ហានេះកើតឡើងតាំងតែឆ្នាំ២០២១ ហើយកំពុងត្រូវបានដោះស្រាយបណ្ដើរៗដោយសមាជិកសហគមន៍ ដែលបានដាក់ពាក្យបណ្ដឹងទៅមេភូមិ ឃុំ និងតាមរយៈការចូលរួមក្នុងវេទិកាសាធារណៈឃុំ ដែលបានរៀបចំដោយអង្គការ API នៅស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់។ លោកបានថ្លែងអំណរគុណដល់អង្គការ API សម្រាប់ការរៀបចំវេទិកា សាធារណៈនេះឡើង និងបានផ្ដល់ឱកាសដល់ក្រុមគ្រួសារទាំងនោះ ក្នុងការទទួលបានព័ត៌មាន និងលើកទឹកចិត្តពួកគេឱ្យហ៊ានលើកយកបញ្ហារបស់ពួកគេមកនិយាយផងដែរ។ **លោក ប៊ិន ប៊ន** សន្យាថានឹងបន្តតាមដានសំណើរបស់ប្រជាពលរដ្ឋទាំង ២០គ្រួសារ ដែលករណីមិនទាន់បានដោះស្រាយរួចរាល់នៅឡើយដើម្បីឱ្យប្រជាពលរដ្ឋ ក៏ដូចជាសមាជិកសហគមន៍ដែលរស់នៅក្នុងភូមិ ឬឃុំរបស់គាត់ទទួលបានដីរបស់ពួកគេ វិញ និងប្រកបរបរធ្វើស្រែ ចំការ ព្រោះដីគឺជាជីវិត ដីអាចរកប្រាក់ចំណូលចិញ្ចឹមជីវិត និងបន្តជីវភាពរស់ នៅរបស់ពួកគេបាន។

## គម្រោងទី៤ ការពង្រឹងការចូលរួមរបស់យុវជនក្នុងការរៀបចំផែនការមូលដ្ឋាន និងផែនការថវិកា

**គោលបំណង៖** ដើម្បីគាំទ្រដល់ការធ្វើឱ្យប្រសើរឡើងរបស់រដ្ឋាភិបាលក្នុងតំបន់ក្នុងការផ្តល់សេវាសង្គម ជាពិសេស សម្រាប់យុវជន ស្ត្រី កុមារ និងប្រជាជនមកពីក្រុមងាយរងគ្រោះរួមទាំងជនមានពិការភាពផងដែរ។

**លទ្ធផលគម្រោង៖** រដ្ឋបាលថ្នាក់ក្រោមជាតិ (ឃុំ និងសង្កាត់) ផ្តល់អាទិភាពលើបញ្ហា និងតម្រូវការរបស់ យុវជននៅក្នុងផែនការអភិវឌ្ឍន៍ និងបែងចែកធនធានសម្រាប់សេវាសង្គមដើម្បីលើកកម្ពស់សុខមាលភាពរបស់យុវជន។

**គាំទ្រថវិកាដោយ៖** ១២៣.៥៣៥ ដុល្លារសហរដ្ឋអាមេរិកបរិច្ចាគដោយ SIDA/UNICEF។

**តំបន់គោលដៅ៖** ខណ្ឌសែនសុខ រាជធានីភ្នំពេញ ស្រុកស្អាង និងស្រុកអង្គស្នួល ខេត្តកណ្តាល និងស្រុកចិត្របុរី ក្នុងខេត្តក្រចេះ។




### លទ្ធផល៖

រដ្ឋាភិបាលបានបញ្ជាក់ពីការគាំទ្ររបស់ខ្លួនក្នុងការបង្កើនថវិកាថ្នាក់ក្រោមជាតិរហូតដល់២០% លើផ្នែកអភិវឌ្ឍ សេវាសង្គមចន្លោះឆ្នាំ២០២៤ ដល់២០២៨។

### សកម្មភាព៖

គម្រោងនេះត្រូវបានបញ្ចប់នៅឆ្នាំ២០២១ ហើយបន្ទាប់មកអង្គការ API បានប្រើប្រាស់ផលិតផល ឧបករណ៍បច្ចេកវិទ្យារបស់គម្រោង (កម្មវិធីវិភាគថវិកាសម្រាប់ប្រជាពលរដ្ឋ) ដើម្បីប្រមូលទិន្នន័យថវិកា និងវិភាគសម្រាប់ថវិកា របស់រដ្ឋបាលឃុំ និងស្រុក ២០២២ - ២០២៣។ នៅឆ្នាំ២០២៣ របាយការណ៍វិភាគ ថវិកាត្រូវបានដាក់ជូនរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល ជាពិសេស ១០០ អង្គការ ដែលជាសមាជិកក្រុមការងារថវិកា និងអង្គការសមាជិកសម្ព័ន្ធដើម្បីភាពជាដៃគូក្នុងអង្គការអភិវឌ្ឍប្រជាធិបតេយ្យ។ នៅឆ្នាំ២០២៣ អង្គការ API បានប្រើប្រាស់ទាំងកម្មវិធីវិភាគ ថវិកាសម្រាប់ប្រជាពលរដ្ឋ និងប្រើប្រាស់ជា ភស្តុតាងដើម្បីផ្តួចផ្តើមកិច្ចសន្ទនាជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងគណៈកម្មាធិការជាតិសម្រាប់ការ អភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

## គម្រោងទី៥ គម្រោងច្រកចេញចូលតែមួយសម្រាប់ពលរដ្ឋ

**ថវិកាគម្រោង៖** អង្គការ API ទទួលបានថវិកាចំនួន ៤៦១.៨១៩,៨១ ដុល្លារពីទីភ្នាក់ងារទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់កិច្ចអភិវឌ្ឍន៍អន្តរជាតិ (USAID) សម្រាប់អនុវត្តសកម្មភាពពី ខែតុលា ឆ្នាំ២០១៩ ដល់ខែ កញ្ញា ឆ្នាំ២០២២។

**ម្ចាស់ជំនួយ៖** ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់កិច្ចអភិវឌ្ឍន៍អន្តរជាតិ (USAID)

**ដៃគូអនុវត្ត៖** អង្គការ API និង InSTEDD (អង្គការទាំងពីរ គឺជាដៃគូដែលដឹកនាំដោយក្រុមហ៊ុន Nickol Global Solutions)។

**តំបន់គោលដៅ៖** អង្គភាព និងការិយាល័យច្រកចេញចូលតែមួយ នៅខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ និងខេត្តកំពង់ឆ្នាំង។




### លទ្ធផល៖

- ឧបករណ៍ប្រព័ន្ធបច្ចេកវិទ្យារបស់គម្រោងច្រកចេញចូលតែមួយសម្រាប់ពលរដ្ឋ (Pidor Chatbot និង Public Dashboard) ត្រូវបានប្រគល់ភាពជាម្ចាស់ដល់អង្គការ API និងក្រុមហ៊ុនកសាង (KAWSANG) ដើម្បីបន្តយកទៅអនុវត្តរួមគ្នា។ ព័ត៌មានស្តីពីសេវាច្រកចេញចូលតែមួយត្រូវបានធ្វើបច្ចុប្បន្នភាពបន្ថែមក្នុង ប្រព័ន្ធបច្ចេកវិទ្យាគម្រោងសម្រាប់ឆ្នាំ២០២៣ ដែលប្រព័ន្ធនេះ អាចប្រើប្រាស់បានចំនួន ៤០ក្រុង ស្រុកនៃខេត្តផ្សេងៗទៀត ដើម្បីឱ្យប្រជាពលរដ្ឋក្នុងតំបន់គោលដៅថ្មីអាចទទួលបានព័ត៌មានពីសេវាច្រក ចេញចូលតែមួយ ក្រោមការគាំទ្រថវិកាដោយអង្គការប្រេដ ហ្វ៊រ ឌឺ វើល ( BfdW) និងជំនួយព្រះវិហារដាណឺម៉ាក (DCA) ដើម្បីបន្តរក្សាមុខងារឧបករណ៍ប្រព័ន្ធបច្ចេកវិទ្យាសម្រាប់ឆ្នាំ២០២២ ដល់ឆ្នាំ២០២៥។
- គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ មានអ្នកចូលមើលប្រព័ន្ធបច្ចេកវិទ្យារបស់គម្រោងសរុបចំនួន ៣៦.៧៨២នាក់ អ្នកចូលសាកសួរព័ត៌មានពីសេវា និងតាមដានឯកសារចំនួន ២៩.៦៥៩នាក់ ក្នុងនោះសេវាដែលសាកសួរព័ត៌មានច្រើនជាងគេ គឺការបញ្ជាក់ឯកសារមានចំនួនសរុប ១៥.៧០៣នាក់។ សរុបអ្នកផ្តល់មតិយោបល់ត្រឡប់មានចំនួន ២.៩៥០នាក់ (ស្ត្រី ១.៥៣៥នាក់ ស្មើនឹង៥២%) ក្នុងនោះ អ្នកពេញចិត្តនឹងការផ្តល់សេវាមានចំនួន ១.៣២៥នាក់ (៤៤.៩%) ចំនួនអ្នកដែលអាចទទួលយកបានពីការផ្តល់សេវាមាន ១.២០៣នាក់ (៤០.៧៦%) និងចំនួនអ្នកដែលមិនពេញចិត្តនឹងការផ្តល់សេវា មានចំនួន ៤២៣នាក់ (១៤.៣៣%) ដែលចំនួនមិនពេញចិត្តច្រើនជាងគេគឺទាក់ទងនឹងតម្លៃសេវា។

### សកម្មភាព៖

គម្រោងច្រកចេញចូលតែមួយសម្រាប់ពលរដ្ឋ (OW4C) បានបញ្ចប់ដោយជោគជ័យក្នុងឆ្នាំ ២០២២ ហើយឧបករណ៍ប្រព័ន្ធបច្ចេកវិទ្យារបស់គម្រោង (Pidor Chatbot និង Public Dashboard) ត្រូវបានប្រគល់ភាពជាម្ចាស់ជាផ្លូវការទៅអោយអង្គការ API និងក្រុមហ៊ុនកសាង (KAWSANG) ដើម្បីបន្តយកទៅអនុវត្តរួមគ្នា។ ក្នុងឆ្នាំ២០២៣ស្ថាប័នទាំងពីរបានបន្តធ្វើបច្ចុប្បន្នភាពព័ត៌មានស្តីពីយន្តការសេវាច្រកចេញចូលតែមួយនៅថ្នាក់ឃុំសង្កាត់សម្រាប់ការប្រើប្រាស់ជាសាធារណៈនៅទូទាំងប្រទេសផងដែរ។

## ការជម្នះឧបសគ្គលើពាក្យចចាមអារ៉ាមអំពីតម្លាភាព

កម្មវិធីវិមជ្ឈការរបស់រាជរដ្ឋាភិបាលកម្ពុជាមានគោលបំណង ដើម្បីផ្លាស់ប្តូរសេវាជូនប្រជាពលរដ្ឋ តាមរយៈ ការិយាល័យច្រកចេញចូលតែមួយ (OWSO) ដែលបានបើកដំណើរការដំបូងក្នុងឆ្នាំ២០០៦។ នៅឆ្នាំ ២០២០ ការស្ទង់មតិមុនគម្រោងរបស់គម្រោងច្រកចេញចូលតែមួយសម្រាប់ពលរដ្ឋ (O4WC) របស់ទីភ្នាក់ងារ សហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID) បានរកឃើញថាមានប្រជាពលរដ្ឋត្រឹមតែ ៤៥% ប៉ុណ្ណោះបានដឹងពី OWSOs។ កង្វះចំណេះដឹងនេះ ធ្វើឱ្យពលរដ្ឋកាន់តែងាយរងនូវហានិភ័យក្នុងការ ជឿពាក្យចចាមអារ៉ាម ចាញ់ឧបាយកល និងការប្រឈមមុខនឹងអំពើពុករលួយ ដោយការបដិសេធព័ត៌មាន ប្រកបដោយតម្លាភាព ឬការប្រើប្រាស់សេវារដ្ឋបាលរបស់រដ្ឋាភិបាលដូចជាសារការី ការចុះបញ្ជីអាជីវកម្ម និងប័ណ្ណកម្មសិទ្ធិដីធ្លី។ល។ ដើម្បីដោះស្រាយហានិភ័យទាំងនេះគម្រោងច្រកចេញចូលតែមួយសម្រាប់ពលរដ្ឋ (OW4C) របស់ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID) បានបង្កើតវិធីសាស្ត្រ កូនកាត់មួយដែលភ្ជាប់សកម្មភាពគណនេយ្យភាពសង្គមបែបប្រពៃណី ដូចជាតារាងពិន្ទុសហគមន៍ ផែនការ កែលម្អសេវាកម្ម និងវេទិកាសាធារណៈ ទៅជាឧបករណ៍បច្ចេកវិទ្យាផ្តោតលើពលរដ្ឋដើម្បីបង្កើនការចូលរួម របស់ប្រជាពលរដ្ឋកម្ពុជាឱ្យទទួលបានព័ត៌មាន ដែលមានតម្លាភាពលើសេវារដ្ឋបាលរបស់រដ្ឋាភិបាល និងដើម្បី បើកឱកាសសម្រាប់ប្រជាពលរដ្ឋក្នុងការផ្តល់មតិកែលម្អលើសេវារដ្ឋបាលរបស់រដ្ឋាភិបាលព្រមទាំងបង្កើតវេទិកាសុវត្ថិភាពសម្រាប់ប្រជាពលរដ្ឋក្នុងការចូលរួម និងធ្វើឱ្យមន្ត្រីរបស់រដ្ឋាភិបាលមានគណនេយ្យភាពក្នុងការផ្តល់ សេវាឱ្យកាន់តែប្រសើរឡើង។

### សាច់រឿងរបស់យើងទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់កិច្ចអភិវឌ្ឍន៍អន្តរជាតិរដ្ឋវ៉ាស៊ីនតោន ឌីស៊ី ២០៥២៣-១០០០

**http;//stories.usaid.gov**



**សុផល** បង្ហាញវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មដោយមោទនភាព។

> “ខ្ញុំធ្លាប់ឮគេនិយាយថា ការចុះបញ្ជីអាជីវកម្មត្រូវចំណាយខ្ទង់មួយពាន់ដុល្លារ។ ខ្ញុំមិនបានចុះបញ្ជីទេ ព្រោះខ្ញុំព្រួយបារម្ភអំពីការចំណាយ និងនីតិវិធីដ៏ស្មុគស្មាញ។ បន្ទាប់ពីខ្ញុំបានប្រើឧបករណ៍បច្ចេកវិទ្យាហ្វេសប៊ុកឆាតបត ដែលមានឈ្មោះ ពិដោរ អ្នកភូមិឆ្លាតវៃ ទើបខ្ញុំដឹងថា វាចំណាយត្រឹមតែ ២.៥០០០ រៀល (៧ ដុល្លារ) ហើយវាមិនស្មុគស្មាញទេ។
> *លោកស្រី ប៉ាច សុផល ម្ចាស់ហាងមហាហេងភីហ្សា ខេត្តបាត់ដំបង ប្រទេសកម្ពុជា*”

មុនពេលរៀនប្រើប្រាស់ឧបករណ៍បច្ចេកវិទ្យារបស់ OW4C គឺពិដោរ អ្នកភូមិឆ្លាតវៃ លោកស្រី ប៉ាច សុផល អាយុ ៣២ឆ្នាំ កំពុងដំណើរការហាងភីហ្សា និងហាងនំប៉័ង នៅខេត្តបាត់ដំបងប្រទេសកម្ពុជា ដែលមានលក់ភីហ្សា នំដុត និងនំផ្សេងៗទៀត។ លោកស្រី សុផល បានចាប់ផ្តើម អាជីវកម្មរបស់គាត់បាន ប្រហែលមួយឆ្នាំមុន ប៉ុន្តែគាត់មិនបានដឹងពីរបៀបដែលត្រូវទទួលបានអាជ្ញាប័ណ្ណអាជីវកម្មទេ។ “ខ្ញុំមិនបាន ដឹងអ្វីទាំងអស់អំពីដំណើរការចុះបញ្ជីអាជីវកម្ម ហើយខ្ញុំមិនដែលប្រើប្រាស់សេវារដ្ឋបាលការិយាល័យច្រកចេញ ចូលតែមួយពីមុនមកទេ។ ប៉ុន្តែសំណាងល្អ ខ្ញុំបានចូលរួមសិក្ខាសាលាស្តីពីសិទ្ធិសេដ្ឋកិច្ចសង្គមរបស់ក្រុមគាំទ្រភូមិដែលបានបង្ហាញពីគម្រោងច្រកចេញចូលតែមួយ និងឧបករណ៍បច្ចេកវិទ្យារបស់ពួកគេ ដោយផ្តល់ព័ត៌មានអំពីសេវារដ្ឋបាលដែលមាននៅការិយាល័យច្រកចេញចូលតែមួយក្នុងខេត្តបាត់ដំបង”។

បន្ទាប់ពីចប់សិក្ខាសាលានោះ លោកស្រី សុផល បានប្រើប្រាស់ពិដោរ អ្នកភូមិឆ្លាតវៃ ហ្វេសប៊ុកឆាតបតរបស់ OW4C។ គាត់បានស្វែងរក និងបានរកឃើញព័ត៌មានលម្អិតអំពីដំណើរការចុះ បញ្ជីអាជីវកម្ម និងឯកសារពាក់ព័ន្ធផ្សេងៗ ដែលគាត់ត្រូវការដើម្បីរៀបចំ មុនពេលទៅការិយាល័យច្រក ចេញចូលតែមួយ។ មុនពេលប្រើពិដោរ គាត់គិតថាការចុះបញ្ជីអាជីវកម្ម គឺជាដំណើរការដ៏ស្មុគស្មាញមួយ ហើយត្រូវចំណាយច្រើន ហើយគាត់ថានឹង «ត្រូវចំណាយប្រាក់បន្ថែមដើម្បីធ្វើអ្វីគ្រប់យ៉ាងឱ្យចប់សព្វគ្រប់»។ លើសពីនេះទៅទៀត គាត់បានរាយការណ៍ថា ការប្រើប្រាស់ពិដោរ អ្នកភូមិឆ្លាតវៃហ្វេសប៊ុកឆាតបតរបស់ OW4C បានធ្វើឱ្យ ជីវិតរបស់គាត់កាន់តែងាយស្រួលដោយសន្សំពេលវេលា និងថវិកាហើយមិនចាំបាច់ទៅការិយាល័យច្រកចេញចូលតែមួយម្តងហើយម្តងទៀតដោយគ្រាន់តែទៅសួរព័ត៌មាន។ ជាលទ្ធផលនៃការប្រើប្រាស់ឧបករណ៍ OW4C អាជីវកម្មរបស់គាត់គឺហាង មហាហេងភីហ្សា បានចុះបញ្ជីជាផ្លូវការដែលផ្តល់សុវត្ថិភាពអាជីវកម្ម និងប្រាក់ចំណូលដល់គាត់ និងគ្រួសារនាពេលអនាគត។

## គម្រោងទី៦ កម្មវិធីធ្វើឱ្យប្រសើរឡើងដល់ការផ្តល់សេវាជូនប្រជាពលរដ្ឋនៅក្នុងប្រទេសកម្ពុជា

**ថវិកាសម្រាប់អនុវត្តគម្រោង៖** អង្គការ API ទទួលបានថវិកា ២៩៣.០៧៥ដុល្លារ សម្រាប់អនុវត្ត សកម្មភាពពីឆ្នាំ២០២៣ ដល់ឆ្នាំ២០២៥។

**ម្ចាស់ជំនួយ៖** រដ្ឋាភិបាលនៃប្រទេសស្វីស និងអាល្លឺម៉ង់

**ដៃគូអនុវត្តគម្រោង៖** GFA និង GIZ

**តំបន់គោលដៅសម្រាប់អនុវត្តគម្រោងមាន៖** ខេត្តសៀមរាប ខេត្តបាត់ដំបង និងខេត្តបន្ទាយមានជ័យ។

### លទ្ធផល៖

- អង្គការ API បានចាប់ផ្តើមអនុវត្តកម្មវិធីធ្វើឱ្យប្រសើរឡើង ដល់ការផ្តល់សេវាជូនប្រជាពលរដ្ឋនៅ ក្នុងប្រទេសកម្ពុជា (ISD) លើសេវាច្រកចេញចូលតែមួយ និងទឹកស្អាត ដោយមានការគាំទ្រ ផ្នែកហិរញ្ញវត្ថុពីរដ្ឋាភិបាលនៃប្រទេសស្វីស និងអាល្លឺម៉ង់ គម្រោងទី១៩ ពីឆ្នាំ២០២៣ ដល់ឆ្នាំ២០២៥។ ក្រុមការងារ សរុបចំនួន ១១នាក់ មានក្រុមការងាររដ្ឋបាល និងអ្នកជំនាញបច្ចេកទេសត្រូវបាន ជ្រើសរើសដើម្បីបំពេញការងារនៅតំបន់គោលដៅក្នុងខេត្តសៀមរាប ខេត្តបាត់ដំបង និងខេត្តបន្ទាយមានជ័យ។
- វគ្គបណ្តុះបណ្តាល ស្តីពី ការធ្វើបដិសណ្ឋារកិច្ច (ការផ្តល់សេវាផ្តោតលើប្រជាពលរដ្ឋ) និងការ ផ្សព្វផ្សាយព័ត៌មានអំពីការផ្តល់សេវារដ្ឋបាលរបស់ការិយាល័យច្រកចេញចូលតែមួយ ត្រូវបានផ្តល់ជូន ដល់រដ្ឋបាល ក្រុង ស្រុកជាដៃគូចំនួន ១០ក្រុង ស្រុក តាមរយៈការសហការជាមួយនាយកដ្ឋានមុខងារ និងធនធាននៃអគ្គនាយកដ្ឋានរដ្ឋបាលក្រសួងមហាផ្ទៃ ដែលមានអ្នកចូលរួមសរុបចំនួន ៤០នាក់។ រដ្ឋបាលស្រុក ចំនួនពីរ ត្រូវបានជ្រើសរើសសម្រាប់អនុវត្តសាកល្បងការផ្តល់សេវាការិយាល័យច្រកចេញចូលតែមួយចល័ត។

### សកម្មភាព

វិធីសាស្ត្រអនុវត្តដែលបានប្រើ៖

- **១. ការផ្តល់សេវាតាមប្រព័ន្ធឌីជីថល៖** សិក្ខាសាលាពិគ្រោះយោបល់ជាមួយក្រុង ស្រុកដៃគូ ចំនួន ១០ ត្រូវបានរៀបចំឡើង ដើម្បីកំណត់ការរំពឹងទុក និងតម្រូវការសម្រាប់ការផ្តល់សេវាឌីជីថលលើសេវា ច្រកចេញចូលតែមួយ។
- បានធ្វើកិច្ចព្រមព្រៀងស្តីពីវិសាលភាពការងាររវាងកម្មវិធីធ្វើឱ្យប្រសើរឡើងដល់ការផ្តល់សេវាជូនប្រជាពលរដ្ឋនៅក្នុងប្រទេសកម្ពុជា (ISD) និងធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ទាក់ទងនឹងការផ្តល់សេវា ឌីជីថលលើសេវាច្រកចេញចូលតែមួយ។
- កម្មវិធីធ្វើឱ្យប្រសើរឡើងដល់ការផ្តល់សេវាជូនប្រជាពលរដ្ឋនៅក្នុងប្រទេសកម្ពុជា (ISD) ក្រសួងមហាផ្ទៃ និងធនាគារអភិវឌ្ឍន៍អាស៊ី (ADB) បានសម្រេចចិត្តរួមគ្នាជ្រើសរើសសេវាចំនួន ០៩ សម្រាប់អនុវត្តន៍ សាកល្បងការផ្តល់សេវាតាមប្រព័ន្ធឌីជីថល ដោយផ្តោតលើវិស័យចំនួន ០៣ មានដូចជា៖ នីត្យានុកូលកម្ម អគ្រានុកូលដ្ឋាន និងវិស័យទេសចរណ៍។
- បានទិញប្រព័ន្ធផ្ទុកទិន្នន័យព័ត៌មានវិទ្យា (Server) និងជ្រើសរើសទីប្រឹក្សារយៈពេលខ្លីដើម្បីតម្លើង និងផ្ទេរទិន្នន័យព័ត៌មានសម្រាប់ការផ្តល់សេវាឌីជីថលនៅក្រសួងមហាផ្ទៃ។
- **២. ការផ្តល់សេវាតាមការិយាល័យច្រកចេញចូលតែមួយចល័ត៖** ស្រុកចំនួនពីរ គឺស្រុកពួក ខេត្តសៀមរាប និងស្រុកមោងឫស្សី ខេត្តបាត់ដំបង ត្រូវបានជ្រើសរើស ដើម្បីសាកល្បងអនុវត្តផ្តល់សេវាការិយាល័យច្រកចេញចូលតែមួយចល័ត។កម្មវិធីធ្វើឱ្យប្រសើរឡើងដល់ការផ្តល់សេវាជូនប្រជាពលរដ្ឋនៅក្នុងប្រទេសកម្ពុជា (ISD) បានធ្វើការសិក្សា លទ្ធភាពជាមួយរដ្ឋបាលស្រុកដើម្បីផ្តល់សេវាចល័តរបស់ការិយាល័យច្រកចេញចូលតែមួយដោយប្រើវិធីសាស្ត្រគំរូ TELOS (បច្ចេកវិទ្យា សេដ្ឋកិច្ច លិខិតបទដ្ឋាន ប្រតិបត្តិការ ការកំណត់ពេលវេលា) និងបានជួបពិភាក្សាជាមួយពលរដ្ឋដែលជួបការលំបាកដើម្បីសិក្សាអំពីតម្រូវការសេវារដ្ឋបាល និងការរំពឹងទុកអំពីកាផ្តល់សេវាចល័តរបស់ការិយាល័យច្រកចេញចូលតែមួយផងដែរ។ បានគាំទ្ររដ្ឋបាលស្រុកដៃគូក្នុងការរៀបចំសេចក្តីព្រាងសេចក្តីសម្រេចចំនួនពីរ សម្រាប់ការអនុវត្តសាកល្បងការផ្តល់សេវាចល័តដល់ប្រជាពលរដ្ឋដែលជួបការលំបាក។

- **៣.ការគ្រប់គ្រងទឹក៖** ស្រុកចំនួន ០៤ ក្នុងខេត្តបន្ទាយមានជ័យ ត្រូវបានជ្រើសរើសជាតំបន់គោលដៅសម្រាប់ការអនុវត្តសាកល្បងកម្មវិធីទឹកស្អាត។ បានបង្កើតអនុគណៈកម្មាធិការគ្រប់គ្រងបរិស្ថាន និងទឹក (E&W-SC) ក្រុង ស្រុកទាំង ០៤ នៅក្នុងខេត្តបន្ទាយមានជ័យ។ បានជួបជាមួយរដ្ឋបាលក្រុង ស្រុកជាដៃគូដើម្បីបង្ហាញពីទម្រង់ព័ត៌មានគ្រប់គ្រងទឹកដោយគិតគូរពីផលប៉ះពាល់អាកាសធាតុព្រមទាំងបានកសាងសមត្ថភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកជាប់ពាក់ព័ន្ធ ស្តីពី "ក្របខ័ណ្ឌច្បាប់នៃវិស័យទឹកថ្នាក់ក្រោមជាតិ និងមុខងារ" និងការអនុវត្តរបស់អនុគណៈកម្មាធិ ការគ្រប់គ្រងបរិស្ថាន និងទឹក។

## មេរៀនដែលបានរៀនក្នុងគម្រោង៖

- មានការសហការល្អទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដោយសារគម្រោងសេវាឌីជីថលដែលផ្តោតលើ សេវាច្រកចេញចូលតែមួយត្រូវជាមួយនឹងសកម្មភាពអាទិភាពរបស់កម្មវិធីថ្នាក់ជាតិ(NP-2)។
- គណៈកម្មការត្រូវបានបង្កើតឡើងដើម្បីគាំទ្រដល់ការអនុវត្តកម្មវិធី ISD តាំងពីថ្នាក់ជាតិរហូតដល់ថ្នាក់ក្រោមជាតិ។

## បញ្ហាប្រឈមក្នុងគម្រោង៖

ការិយាល័យច្រកចេញចូលតែមួយ៖ គម្រោងសេវាឌីជីថលដែលផ្តោតលើសេវាច្រកចេញចូលតែមួយ បានពន្យាពេលដោយសារជាន់គ្នាជាមួយគម្រោងធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និងបានផ្តល់អាទិភាពជំនួស ដោយសកម្មភាពសេវារដ្ឋបាលចល័តការិយាល័យច្រកចេញចូលតែមួយវិញ។

## គម្រោងទី៧ ការសម្រុះសម្រួល និងការយល់ព្រម ឆេងឌឹហ្គេមអាកាដឺមី សម្រាប់ការកៀរគរការគាំទ្រមតិនៅកម្ពុជា

**គោលបំណង៖** សុវត្ថិភាពធនធានសម្រាប់អង្គការសង្គមស៊ីវិលដែលគេអាចធ្វើឱ្យមាននិរន្តរភាពប្រតិបត្តិការរបស់គេនៅកម្ពុជា។

**ដៃគូអនុវត្ត៖** មិនមាន

**ការផ្តល់មូលនិធិ៖** ស្វីកធីវ៉ាលហ្គិនសិន ផ្តល់មូលនិធិ ៥០.០០០យូរ៉ូ។ ចូលបដិភាគពីអង្គការសង្គមស៊ីវិល ២.៧៦០ ដុល្លារសហរដ្ឋអាមេរិក

**តំបន់គោលដៅ៖** ទូទាំងប្រទេស






### លទ្ធផល៖

- អង្គការសង្គមស៊ីវិលចំនួន ០២ (៣៣%) បានអនុវត្តផែនការកៀរគរការគាំទ្រមតិរបស់គេដោយ ជោគជ័យ។ អាជ្ញាធរមូលដ្ឋានបានផ្តល់ប័ណ្ណសមធម៌ចំនួន ៥០២ និងអត្តសញ្ញាណកម្មជនមានពិការ ភាពចំនួន ២៥៩ ហើយសប្បុរសជនបានផ្តល់ជាអង្ករ ភេសជ្ជៈ និងម្ហូបអាហារ ដើម្បីគាំទ្រដល់ អង្គការដុនបូស្កូ។ អង្គការសង្គមស៊ីវិលចំនួន ០៧ទៀតកំពុងធ្វើការអនុវត្តផែនការកៀរគរការគាំទ្រមតិ។
- អង្គការសង្គមស៊ីវិលចំនួន ០២កៀរគរបានការគាំទ្រពីសហគមន៍ សប្បុរសជន និងអាជ្ញាធរមូលដ្ឋាន ដើម្បីបោះបង្គោលព្រំ និងសាងសង់ផ្ទាំងបដាធំៗដើម្បីការពារព្រៃសហគមន៍។

### សកម្មភាព៖

- អង្គការវិទ្យាស្ថានតស៊ូមតិបានបណ្តុះបណ្តាលវគ្គថ្នាក់ដឹកនាំនិងវគ្គបណ្តុះបណ្តាលរយៈពេល ៥ថ្ងៃ លើការកៀរគរការគាំទ្រមតិដល់បុគ្គលិកអង្គការក្រៅរដ្ឋាភិបាលចំនួន ១៩ ដែលជាមន្ត្រីជាន់ខ្ពស់ និងនាយកស្ថាប័នមក។ អ្នកចូលរួមសរុបមានចំនួន១៩នាក់មកពីអង្គការសង្គមស៊ីវិលចំនួន ០៩ បានចូលរួមវគ្គបណ្តុះបណ្តាលចំនួន ០៤វគ្គ ស្តីពី ការកៀរគរការគាំទ្រមតិរយៈពេល ១១ថ្ងៃ និងការអនុវត្តរយៈពេលមួយឆ្នាំពេញដោយជោគជ័យ។ តាមរយៈសិក្ខារំលឹកឡើងវិញចំនួន ០២ថ្ងៃ សិក្ខាកាមចំនួន ១០នាក់បានធ្វើបច្ចុប្បន្នភាពឯកសារបណ្តុះបណ្តាលស្តីពីការកៀរគរការគាំទ្រមតិ ជាភាសាខ្មែរបានចប់សព្វគ្រប់។ អតីតអ្នកចូលរួមវគ្គការកៀរគរការគាំទ្រមតិចំនួន ១៦នាក់បានចែក រំលែកអំពីភាពជោគជ័យរបស់ពួកគេមេរៀនដែលបានរៀនសូត្រ និងផែនការបន្ទាប់នៃការអនុវត្តការ កៀរគរការគាំទ្រមតិ។ ក្រៅពីនោះគ្រូបង្វឹកបានធ្វើការបង្វឹកសិក្ខាកាមចំនួនពីរដងដល់កន្លែងធ្វើការលើផែនការកៀរគរការគាំទ្រមតិចំនួន ១២ និងបានធ្វើបច្ចុប្បន្នភាព និងអនុវត្ត។ អង្គការសង្គមស៊ីវិល ចំនួន ០២ បានរាយការណ៍ថាពួកគេបានកៀរគរការគាំទ្រការសាងសង់ផ្ទះតូចៗ និងការពារព្រៃសហគមន៍ ដោយជោគជ័យ។
- ការបង្ហាត់បង្ហាញនៅតាមសហគមន៍: ផែនការកៀរគរការគាំទ្រមតិចំនួន ១២ ត្រូវបានរៀបចំឡើង ដោយអ្នកចូលរួម ហើយក្រុមធ្វើផែនការទាំង ១២ នោះបានធ្វើបច្ចុប្បន្នភាពផែនការកៀរគរការ គាំទ្រមតិរបស់ខ្លួនតាមរយៈការបង្ហាត់បង្ហាញលើកទី១។ ក្រុមធ្វើផែនការទាំង ១២ នោះត្រូវបានបង្ហាត់ បង្ហាញផងដែរអំពីរបៀបដោះស្រាយការប្រឈមរបស់ពួកគេក្នុងការអនុវត្តផែនការកៀរគរការគាំទ្រមតិ។ នៅគ្រាដដែលនោះពួកគេក៏បានចែករំលែកភាពជោគជ័យ និងសកម្មភាពបន្តទៀតផងដែរ។ ក្រុម អនុវត្តផែនការកៀរគរការគាំទ្រមតិចំនួន ០២ក្រុម នៃអង្គការសង្គមស៊ីវិលចំនួន ០២ បានអនុវត្ត ផែនការកៀរគរការគាំទ្រមតិរបស់គេចប់សព្វគ្រប់ហើយ ១០ក្រុម មកពីអង្គការសង្គមស៊ីវិលចំនួន ០៧ ទៀតកំពុងអនុវត្តសកម្មភាពបានខ្លះហើយ។

- សិក្ខាសាលារំលឹកឡើងវិញរយៈពេល ០១ថ្ងៃ ជាមួយអតីតអ្នកចូលរួមវគ្គបណ្តុះបណ្តាលក្នុង ឆ្នាំ២០២២ បានបង្ហាញថាពួកគាត់ទទួលបានជោគជ័យក្នុងការអនុវត្តផែនការកៀរគរការគាំទ្រមតិ របស់ខ្លួន។ នៅគ្រាដដែលនោះ សិក្ខាកាមទាំង ១៦នាក់ បានចែករំលែកពីការប្រឈម និងមេរៀន បទពិសោធន៍ដែលគេរៀនសូត្របានផងដែរ។ ជាចុងក្រោយ សិក្ខាកាមពេញចិត្តជាមួយនឹងវគ្គបណ្តុះ បណ្តាលស្តីពីការកៀរគរការគាំទ្រមតិពីព្រោះវាចូលរួមបង្កើនពុទ្ធិ បទពិសោធន៍ និងជំនាញកៀរគរការ គាំទ្រមតិដើម្បីអនុវត្តសកម្មភាពគម្រោងយ៉ាងមានប្រសិទ្ធភាព។ សិក្ខាកាមបានបញ្ជាក់ថា គេនៅតែបន្ត អនុវត្តទស្សនទានការកៀរគរការគាំទ្រមតិនៅក្នុងគម្រោងកម្មវិធីក៏ដូចជា ចែករំលែកចំណេះដឹងនោះ ដល់អ្នកដទៃទៀត។ សិក្ខាសាលារំលឹកឡើងវិញរយៈពេល ០២ថ្ងៃ បាននាំទៅធ្វើបច្ចុប្បន្នភាព សម្ភារបណ្តុះបណ្តាលជាភាសាខ្មែរ។ វាក្យសព្ទជាភាសាខ្មែរត្រូវបានកែសម្រួល និងបញ្ចប់រួចរាល់។
- អនុវត្តការផ្សាភ្ជាប់ និងការរៀនសូត្រមន្ត្រីគម្រោងម្នាក់បានទៅចូលរួមវគ្គបណ្តុះបណ្តាលអំពី គណនេយ្យភាពសង្គមនៅប្រទេសអេត្យូពី។ គាត់បានផ្តល់ និងចែលរំលែកទាំងឯកសារ និងការអនុវត្តជាក់ស្តែងនៅកម្ពុជា។
- ការផ្សព្វផ្សាយការធ្វើទីផ្សារកម្មវិធីបណ្តុះបណ្តាលការសម្របសម្រួល និងការប្រាស្រ័យទាក់ទង គម្រោងបានផលិតវីដេអូចំនួន ០២ ស្តីពីរឿងរ៉ាវជោគជ័យ ដែលទាក់ទងទៅនឹងការកៀរគរការគាំទ្រមតិពីអាជ្ញាធរមូលដ្ឋានដើម្បីបោះបង្គោលព្រំដី និងតម្លើងផ្ទាំងផ្សព្វផ្សាយព័ត៌មានដើម្បីការពារព្រៃសហគមន៍បានដោយជោគជ័យ។
- ទន្ទឹមនឹងនោះ ពួកគេបានកៀរគរធនធានពីសប្បុរសជន និងអាជ្ញាធរមូលដ្ឋានដើម្បីសាងសង់ ផ្ទះតូចៗជូនដល់ជនក្រីក្រ។ អង្គការវិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ (API) បានផ្សព្វផ្សាយ សេចក្តីប្រកាសរបស់ខ្លួនតាមរយៈគេហទំព័រហ្វេសប៊ុក (API Facebook) រួមទាំងសកម្មភាព នៃការបណ្តុះបណ្តាល និងការបង្ហាត់បង្ហាញ។ អង្គការ API បានផលិតខិត្តប័ណ្ណស្តីពីការបណ្តុះ បណ្តាលលើការកៀរគរការគាំទ្រមតិ។ សិក្ខាកាមចំនួន ១៩នាក់ បានចុះឈ្មោះ និងចូលរួមវគ្គបណ្តុះ បណ្តាលស្តីពីការកៀរគរការគាំទ្រមតិរហូតដល់បញ្ចប់។

## មេរៀនដែលរៀនសូត្របាន៖

- រៀបចំឯកសារគាំទ្រឱ្យទាន់ពេលវេលាដើម្បីធ្វើបុរេប្រទានលើការចំណាយសម្រាប់សកម្មភាពគម្រោង។
- ចំណាយពេលវេលាមួយសមរម្យដើម្បីបង្រៀនសាកល្បងមុនពេលចេញបណ្តុះបណ្តាល។

## ការប្រឈមនានា៖

- យើងមានពេលវេលាខ្លីដើម្បីផ្សព្វផ្សាយអំពីវគ្គបណ្តុះបណ្តាលស្តីពីការកៀរគរការគាំទ្រមតិ។

## ផែនការបន្ត៖

- រៀបចំខិត្តប័ណ្ណ វគ្គបណ្តុះបណ្តាល និងកម្មវិធីបណ្តុះបណ្តាលឱ្យទាន់ពេលវេលាដើម្បីផ្សព្វផ្សាយនៅដើមខែនៃឆ្នាំនីមួយៗ។
- កំណត់កាលបរិច្ឆេទឱ្យបានច្បាស់សម្រាប់វគ្គបណ្តុះបណ្តាលនីមួយៗ នោះអ្នកចូលរួមទាំងអស់អាច ចូលរួមពេញលេញគ្រប់ព្រឹត្តិការណ៍នៃការបណ្តុះបណ្តាល។
- ចំណាយពេលវេលាសមរម្យមួយដើម្បីពិនិត្យមើលឡើងវិញរៀបចំនិងបង្រៀនសាកល្បង ដើម្បីធានាថាគ្រូបណ្តុះបណ្តាលយល់ទស្សនទាន ដំណើរបណ្តុះបណ្តាល និងប្រើប្រាស់សម្ភារមានសង្គតិភាព ទាំងអស់គ្នា។

## គម្រោងទី៨ ជំនួយសង្គ្រោះបន្ទាន់ដល់គ្រួសារដែលងាយរងគ្រោះបំផុតអំឡុងពេលកូវីដ-១៩

គម្រោងនេះត្រូវបានបញ្ចប់ និងចូលរួមជាមួយគ្រួសារក្រីក្រដែលមានអត្តសញ្ញាណប័ណ្ណ ដូចគ្នានិង គម្រោងថ្មីទី១០៖ ការចូលរួមរបស់ប្រជាពលរដ្ឋសម្រាប់គណនេយ្យភាពសង្គមក្នុងការគាំពារសង្គម។

## គម្រោងទី៩ **សំឡេង និងសកម្មភាពរបស់ជនពិការក្នុងគណនេយ្យភាពសង្គម** (ដើមឡើយកំណត់សម្រាប់រយៈពេល ២០១៩ - ២០២០ វាត្រូវបានបន្តរហូតដល់ខែមិថុនា ឆ្នាំ២០២១)

**គោលបំណង៖** ពង្រីកសំឡេងរបស់ជនមានពិការភាពដើម្បីលើកកម្ពស់លទ្ធភាពទទួលបានសេវាសាធារណៈ ប្រកបដោយសមធម៌ និងគុណភាពបន្ថែមទៀតនៅក្នុងស្រុកគោលដៅ។

**ថវិកា៖** កម្មវិធីសំឡេងរបស់អង្គការអុកស្វាមនៅកម្ពុជា ទទួលបានថវិកា ១៥៦.៨៥៨ ដុល្លារ។

**ដៃគូអនុវត្ត៖** Epic Arts

**តំបន់គោលដៅ៖** ឃុំចំនួនប្រាំពីរ ក្នុងស្រុកត្រាំកក់ ខេត្តតាកែវ។

***គម្រោងទី៩*** ត្រូវបានបញ្ចប់ និងដំណាក់កាលចេញពីស្រុកត្រាំកក់ ខេត្តតាកែវ (អ្នកក្រីក្រជនបទ) បន្ទាប់មកសាកល្បងនៅតំបន់គោលដៅថ្មីក្នុងខណ្ឌសែនសុខ រាជធានីភ្នំពេញ (ជនក្រីក្រក្នុងទីក្រុង)។

## គម្រោងទី១០ ការចូលរួមរបស់ប្រជាពលរដ្ឋសម្រាប់កិច្ចការពារសង្គមតាមរយៈយន្តការគណនេយ្យភាពសង្គម

**គោលបំណងរួមនៃគម្រោង៖** កែលម្អសេវាកិច្ចការពារសង្គមសាធារណៈសម្រាប់ប្រជាពលរដ្ឋងាយរងគ្រោះនៅតំបន់ទីក្រុង

**ការផ្តល់មូលនិធិ៖** ៥៨.៧២៨ ដុល្លារសហរដ្ឋអាមេរិកគាំទ្រថវិកាដោយអង្គការអុកស្វាម (Oxfam)

**តំបន់គោលដៅ៖** ខណ្ឌសែនសុខ និងសង្កាត់ចំនួន ៣ សាលាបឋមសិក្សាចំនួន ៧ និងមណ្ឌលសុខភាពចំនួន ៥។

***គម្រោងនេះ*** ត្រូវបានបញ្ចប់នៅដើមឆ្នាំ២០២៣។

## គម្រោងទី១១ គាំទ្រការចូលរួមរបស់ប្រជាពលរដ្ឋប្រកបដោយអត្ថន័យតាមរយៈការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ដើម្បីធ្វើឱ្យប្រសើរឡើងនូវគណនេយ្យភាពសង្គម

**គោលបំណងទូទៅ៖** ដើម្បីអភិវឌ្ឍន៍ឱ្យមានប្រសិទ្ធភាពគណនេយ្យភាព និងតម្លាភាព និងធានាបាននូវការ ទទួលបាននូវព័ត៌មានសាធារណៈ និងសេរីភាពជាមូលដ្ឋានដល់ស្ថាប័នគ្រប់កំរិត (SDG16)

**គោលបំណងជាក់លាក់៖** ដើម្បីពង្រឹងសិទ្ធិអំណាចយុវជន ជនជាតិដើមភាគតិចដើម្បីឱ្យការគ្រប់គ្រងដោយមានការចូលរួមកាន់តែច្រើនមានតម្លាភាពការឆ្លើយតប និងគណនេយ្យភាពដោយការបញ្ចូលនូវការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល។

**មូលនិធិ៖** 397.281,29 អឺរ៉ូ

**ដៃគូអនុវត្តគម្រោង៖** អង្គការ API អង្គការឃែរអន្តរជាតិនៅកម្ពុជា InSTEDD និងអង្គការដៃគូ 14 ផ្សេងទៀត

**តំបន់គោលដៅ៖** ស្ទឹងត្រែង ក្រចេះ រតនគិរី មណ្ឌលគិរី និងកោះកុង

### លទ្ធផលគម្រោង៖

សកម្មភាព នៃគម្រោងនេះភាគច្រើនត្រូវបានបញ្ចប់យ៉ាងល្អ ហើយលទ្ធផលរំពឹងទុកនៅក្នុងសូចនាករ ភាគច្រើនសម្រេចបាន។ អង្គការ API បានបង្កើនសមត្ថភាព និងលទ្ធភាពបង្ហាត់បង្ហាញរបស់អ្នកសម្របសម្រួលផ្នែកគណនេយ្យភាពសហគមន៍ (CAFs) ជាង 500 នាក់ នៅក្នុងខេត្តចំនួន 5 ហើយបានដាក់ចេញនូវការអនុវត្ត ISAF នៅកម្រិតក្រុងបន្ទាប់ពីបុគ្គលិកដៃគូក្នុងស្រុក និង CAFs បានអនុវត្តតាមការ បណ្តុះបណ្តាលរយៈពេល 3 ថ្ងៃ និងការបង្ហាត់បង្ហាញនៅតាមមូលដ្ឋានយ៉ាងហោចណាស់មួយជុំក្នុងចំណោមពីរជុំក្នុងស្រុកទាំង ៣៣។

**គិតត្រឹមខែធ្នូ ឆ្នាំ២០២៣ គម្រោងសម្រេចបានលទ្ធផលដូចខាងក្រោម៖**

- ធ្វើឱ្យប្រសើរឡើងនូវលទ្ធភាពទទួលបានព័ត៌មានជាសាធារណៈ និងការបើកចំហចវិកាសម្រាប់ក្រុម គោលដៅរបស់យើង។ 96% នៃអ្នកផ្តល់សេវាគោលដៅ (174 ឃុំ 539 សាលារៀន និង 98 មណ្ឌលសុខភាព) បានធ្វើបច្ចុប្បន្នភាពផ្ទាំងព័ត៌មាន ឌីជីថល I4C របស់ពួកគេ។
- ជាមធ្យម 44% នៃចំនួនប្រជាពលរដ្ឋបានទទួលនូវចំណេះដឹងអំពីសិទ្ធិរបស់ពួកគេ និងបានប្រើប្រាស់ សិទ្ធិទាំងនេះក្នុងការទទួលបានសេវាសាធារណៈ និងព័ត៌មាន អំពីស្តង់ដារ ការអនុវត្តការងារ និងថវិកាសម្រាប់រដ្ឋបាលឃុំ សង្កាត់ មណ្ឌលសុខភាព និង សាលាបឋមសិក្សា។
- 83% នៃ CAFs មានទំនុកចិត្តក្នុងការបណ្តុះបណ្តាលយុវជន។ នេះស្របនឹងការវាយតម្លៃ សមត្ថភាពដែលបានធ្វើឡើងក្នុង ខែវិច្ឆិកា ឆ្នាំ2022 ដែលបង្ហាញថា 82% នៃ CAFs បានធ្វើឱ្យប្រសើរឡើងនូវជំនាញភាពជាអ្នកដឹកនាំ និងអាចប្រើប្រាស់ ឧបករណ៍ “សូចនាករភាពជាអ្នកដឹកនាំរបស់យុវជន” ក្នុងការសម្របសម្រួលការបង្កើតផែនការនៅថ្នាក់ឃុំ។
- តាមរយៈយុវជន អ្នកផ្តល់សេវាសាធារណៈផ្តល់សេវាបានល្អប្រសើរជាងមុនមានភស្តុតាងដែលបង្ហាញថា 78% នៃផែនការ សកម្មភាពគណនេយ្យភាពរួម (JAAPs) បានឆ្លុះបញ្ចាំងពីអាទិភាពនៃយុវជន ជនជាតិភាគតិច ដែលស្របតាមផែនការវិនិយោគ ឃុំ (CIPs) និងផែនការវិនិយោគស្រុក (DIP) ក្នុងឆ្នាំ២០២២។
- លទ្ធផលជាច្រើនទៀតត្រូវបានរាយការណ៍ធៀបនឹងសូចនាករ និងចាត់ថ្នាក់តាមប្រភេទមនុស្សក្នុង រយៈពេលអនុវត្តគម្រោងដូច ខាងក្រោម។

**តារាង៖ សង្ខេបកម្រិតនៃការពេញចិត្តរបស់ប្រជាពលរដ្ឋ (ដំបូង ពាក់កណ្តាលអាណត្តិ និងបញ្ចប់)**

| | ប្រជាពលរដ្ឋទាំងអស់ | | | ជនពិការ | | | ជនជាតិដើមភាគតិច | | | ស្រី | | | ប្រុស | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ដំបូង | ពាក់កណ្តាល | ចប់ | ដំបូង | ពាក់កណ្តាល | ចប់ | ដំបូង | ពាក់កណ្តាល | ចប់ | ដំបូង | ពាក់កណ្តាល | ចប់ | ដំបូង | ពាក់កណ្តាល | ចប់ |
| ការិយាល័យឃុំ/សង្កាត់ | 69% | 64% | 87% | 62% | 75% | 84% | 76% | 71% | 91% | 74% | 68% | 88% | 62% | 53% | 83% |
| ការិយាល័យស្រុក | 70% | 68% | 81% | 57% | 90% | 87% | 76% | 88% | 74% | 72% | 72% | 84% | 67% | 27% | 71% |
| ការអប់រំបឋម | 81% | 72% | 81% | 71% | 75% | 77% | 86% | 86% | 80% | 82% | 77% | 83% | 80% | 63% | 76% |
| អនុវិទ្យាល័យ | 75% | 65% | 72% | 73% | 74% | 66% | 69% | 78% | 73% | 77% | 70% | 70% | 72% | 56% | 80% |
| មណ្ឌលសុខភាព | 75% | 65% | 81% | 49% | 62% | 88% | 77% | 62% | 78% | 76% | 69% | 82% | 75% | 57% | 76% |
| ស្រុកប្រតិបត្តិ/មន្ទីរពេទ្យបង្អែកខេត្ត | 69% | 60% | 79% | 50% | 73% | 83% | 66% | 71% | 77% | 70% | 62% | 79% | 69% | 56% | 81% |
| សេវាកម្មប្រមូលសំរាម | 66% | 48% | 51% | 80% | 0% | 42% | 57% | 93% | 43% | 53% | 60% | 53% | 85% | 10% | 44% |
| សេវាកម្មផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី | 63% | 61% | 75% | 50% | 69% | 82% | 66% | 73% | 73% | 68% | 66% | 78% | 56% | 49% | 67% |
| ការគ្រប់គ្រងបរិស្ថាន | 31% | 41% | 55% | 35% | 38% | 70% | 47% | 60% | 64% | 34% | 44% | 56% | 27% | 36% | 50% |
| **មធ្យម** | **67%** | **61%** | **74%** | **59%** | **62%** | **75%** | **69%** | **76%** | **73%** | **67%** | **65%** | **75%** | **66%** | **45%** | **70%** |

**២. % នៃផែនការសកម្មភាពរួមគណនេយ្យភាពសង្គម បានអនុវត្ត(ដោះស្រាយ) ក្នុងរយៈពេល ១២ខែនៅចុង បញ្ចប់គម្រោង**

| | 2021 | 2022 |
|---|---|---|
| រដ្ឋបាលឃុំ សង្កាត់ | 78% | 6% |
| មណ្ឌលសុខភាព | 74% | 14% |
| សាលាបឋមសិក្សា | 73% | 23% |

ទិន្នន័យនេះគិតត្រឹម ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៣

**កំណត់សម្គាល់៖** ផែនការសកម្មភាពរួមគណនេយ្យភាពសង្គម (JAAP) ឆ្នាំ២០២៣ មិនទាន់ចប់សព្វគ្រប់

| | គោលដៅ | ឆ្នាំទី៣(២០២២) | ឆ្នាំទី៤(២០២៣) |
|---|---|---|---|
| % សកម្មភាពនៃផែនការរួមគណនេយ្យភាពសង្គមបានអនុវត្ត(ដោះ | 60% | 78% | 80% |

**លទ្ធផលទី២៖ ដើម្បីពង្រឹងអំណាចយុវជនជនជាតិដើមភាគតិចដើម្បីឱ្យការគ្រប់គ្រងមានការចូលរួមកាន់តែ ច្រើនមានតម្លាភាព ការឆ្លើយតប និងគណនេយ្យភាពដោយការបញ្ចូលនូវការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល។**

**១. %នៃយុវជនជនជាតិដើមភាពតិច (បុរស/ស្ត្រី) ចូលរួមក្នុងការបង្កើតផែនការ (ដំណើរការដាក់ពិន្ទុសហគមន៍ ការប្រជុំរួម និង ទិន្នន័យឌីជីថល dashboard)**

| 2020 | 2021 | 2022 | 2023 |
|---|---|---|---|
| មានតែ 30% នៃយុវជនជនជាតិដើមភាពតិច | មាន ៦១,៥០% នៃ ៤៦៥ CAFs, ២៦,៤៥% នៃយុវជន ១២៣នាក់ ៦,០២% នៃជន មានប័ណ្ណក្រីក្រ ២៨នាក់ | ២៦,០៥% ស្មើយុវជន ជនជាតិដើមភាពតិច ១៤២នាក់ ១០៣ជាស្ត្រី | ៣៦,៥៧%ស្មើយុវជនជនជាតិដើមភាពតិច ២០៧នាក់ (រាប់បញ្ចូល ស្ត្រីជាយុវជន ១១៧នាក់) នៃCAFs ៥៦៦នាក់ |

| | គោលដៅ | ឆ្នាំទី៣(២០២២) | ឆ្នាំទី៤(២០២៣) |
|---|---|---|---|
| % នៃយុវជនជនជាតិដើមភាពតិច (បុរស ឬស្ត្រី) ចូលរួមក្នុងការបង្កើតផែនការ (ដំណើរការដាក់ពិន្ទុសហគមន៍ការប្រជុំរួម និងឌីជីថលដាសបត dashboard) | 60% | 85% | 75% |

**២. % នៃគំនិតជាធាតុចូលពីអ្នកចូលរួមតាមទម្រង់ឌីជីថលនានា (Digital plateform)**

២០២៣៖ ៨៥% នៃធាតុចូលបានមកពីអ្នកចូលរួមតាមរយៈកម្មវិធីឌីជីថលនានា។ កម្មវិធីឌីជីថលនានាត្រូវបានធ្វើឱ្យប្រសើរឡើងយ៉ាងខ្លាំងក្នុងអំឡុងពេលរាយការណ៍ដោយមានអ្នកចូលរួមគម្រោង 7.542 ចូលរួមតាមរយៈ ប័ណ្ណពិន្ទុសហគមន៍ឌីជីថល (DCSC) (ត្រឹមថ្ងៃទី30 ខែមិថុនា ឆ្នាំ 2023)

## សកម្មភាព៖

- មានការកើនឡើងនូវសមត្ថភាពរបស់មន្ត្រីអង្គការសង្គមស៊ីវិលអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ និងរដ្ឋបាលមូលដ្ឋានក្នុងការសម្របសម្រួលកិច្ចសន្ទនារវាងអាជ្ញាធរមូលដ្ឋាន និងយុវជន។
- បានបណ្តុះបណ្តាល និងបង្ហាត់បង្ហាញ CAF ចំនួន 557 នាក់ (ស្រី 360 នាក់) យុវជន 289នាក់ (ស្រី 213នាក់) និងជនជាតិភាគតិច 207នាក់ (ស្រី 117នាក់) នៅក្នុង 33 ក្រុង ស្រុកគោលដៅ។
- ពង្រឹងសមត្ថភាពយុវជនចំនួន14.400នាក់ តាមរយៈកិច្ចប្រជុំផ្តល់យោបល់លើសេវាដែល ដឹកនាំដោយពលរដ្ឋតាមបែបឌីជីថល។

- មនុស្សសរុបចំនួន 30.348 នាក់បានចូលរួមក្នុងគម្រោងសកម្មភាពយល់ដឹងនានា និងទទួលបាន ការអប់រំពលរដ្ឋអំពីគណនេយ្យភាពសង្គម និងសិទ្ធិក្នុងសង្គម។
- អ្នកចូលរួមទាំងនេះត្រូវបានចាត់ថ្នាក់តាមប្រភេទនៃអ្នកចូលរួមនៅក្នុងតារាងខាងក្រោម។

| ប្រជាពលរដ្ឋបានចូលរួមក្នុងការផ្តល់ចំណេះដឹងលើ I4C (2020 - 2023) | | | | | | |
|---|---|---|---|---|---|---|
| សកម្មភាព | អ្នកចូលរួមសរុប | ស្ត្រី | យុវជន | អ្នកមានប័ណ្ណក្រីក្រ | ជនជាតិដើមភាគតិច | ជនងាយរងគ្រោះ |
| អ្នកចូលរួមផ្ទាល់ | 30,348 | 7,797 | 4,008 | 2,753 | 5,795 | 205 |
| ការផ្សព្វផ្សាយជាសាធារណៈ និងតាមសេវាសង្គម | 749,896 | | | | | |
| **សរុប** | **780,244** | **7,797** | **4,008** | **2,753** | **5,795** | **205** |

## ការរៀនសូត្រអំពីបទពិសោធន៍

- ការបង្ហាត់បង្ហាញនូវមូលដ្ឋាន និងការត្រួតពិនិត្យនៅមូលដ្ឋានគឺជាវិធីសាស្ត្រដ៏មានប្រសិទ្ធភាព សម្រាប់ការកសាងសមត្ថភាពអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ (CAFs) ដើម្បីយល់ពី របៀបរៀបចំសម្ភារទាំងអស់ រៀបចំព្រឹត្តិការណ៍ផ្សព្វផ្សាយព័ត៌មានសម្រាប់ពលរដ្ឋ (I4C) ធ្វើផ្ទាំង រូបភាព ជាភាសាខ្មែរ និងពន្យល់ដោយប្រើពាក្យសំដីជាភាសាជនជាតិដើមដែលធ្វើឱ្យកាន់តែងាយស្រួល សម្រាប់ជនជាតិដើមភាគតិចក្នុងការ យល់ដឹងអំពីសិទ្ធិរបស់ពួកគាត់ និងអនុញ្ញាតឱ្យពួកគេចែករំលែកកង្វល់ និងតម្រូវការរបស់ពួកគាត់ជាភាសាដើមរបស់គាត់ ខណៈពេលដែលគាត់ចូលរួមក្នុងការប្រជុំ ដាក់ពិន្ទុដោយប្រជាពលរដ្ឋប្រកបដោយអត្ថន័យ។
- វគ្គបណ្តុះបណ្តាលនេះរួមបញ្ចូលគ្នាទាំងដំណើរការប័ណ្ណដាក់ពិន្ទុដោយប្រជាពលរដ្ឋតាមបែបប្រពៃណី និងការអនុវត្តអំពីរបៀបដាក់ពិន្ទុបែបឌីជីថលនៅក្នុងថ្នាក់រៀន។ វិធីសាស្ត្រទាំងនេះបានជួយអ្នកសម្រប សម្រួលយល់កាន់តែច្បាស់អំពីខ្លឹមសារ និងដំណើរការនៃវដ្ត ISAF ហើយអនុវត្តភ្លាមៗបន្ទាប់តាម ដំណាក់កាលនីមួយៗ។
- ការសម្របសម្រួលល្អជាមួយរដ្ឋាភិបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិបានលើកទឹកចិត្តដល់ផ្នែក ផ្គត់ផ្គង់ ដែលជាមន្ត្រីរដ្ឋាភិបាលក្នុងការជួយកៀងគរប្រជាពលរដ្ឋឱ្យចូលរួមវាយតម្លៃសេវាសាធារណៈ របស់គេការរៀបចំឱ្យមានដំណើរការស្វ័យវាយតម្លៃ និងរៀបចំផែនការរួមគ្នាដើម្បីកែលម្អសេវារបស់គេ ដោយផ្អែកលើមតិយោបល់របស់ប្រជាពលរដ្ឋ។
- ទិន្នន័យពីប័ណ្ណដាក់ពិន្ទុសហគមន៍ស្វ័យវាយតម្លៃផែការការរួមគណនេយ្យភាពសង្គម (JAAP) និង ស្ថានភាពនៃការអនុវត្ត JAAP គួរតែត្រូវបានប្រមូលទូទាំងប្រទេសពីគ្រប់អ្នកអនុវត្ត ISAF អង្គការមិន មែនរដ្ឋាភិបាល និងរដ្ឋាភិបាលទាំងអស់ដែលអនុវត្ត ISAF ដំណាក់កាលទី២ ដើម្បីឆ្លុះបញ្ចាំង និងកំណត់យុទ្ធសាស្ត្រថ្មីសម្រាប់ ISAF ដំណាក់កាលទី៣ ការឆ្លុះបញ្ចាំងលើគោលនយោបាយ ថ្នាក់ជាតិសម្រាប់សកម្មភាពអនុវត្តគោលនយោបាយក្នុងគោលបំណងធ្វើឱ្យប្រសើរឡើងជាប្រព័ន្ធនូវសេវាសាធារណៈទូទាំងប្រទេស។

## ផែនការបន្ទះ

- កិច្ចសន្ទនាលើគោលនយោបាយផ្អែកលើទិន្នន័យវិភាគបានមកពីការដាក់ពិន្ទុរបស់ប្រជាពលរដ្ឋស្វ័យវាយតម្លៃ JAAP និងស្ថានភាពនៃការអនុវត្ត JAAP សម្រាប់ការឆ្លុះបញ្ចាំងគោល នយោបាយកំរិតថ្នាក់ជាតិសម្រាប់សកម្មភាពអនុវត្តន៍គោលនយោបាយក្នុងគោលបំណងធ្វើឱ្យប្រសើរឡើងជាប្រព័ន្ធនូវសេវាសាធារណៈទូទាំងប្រទេស។
- គម្រោងបានបញ្ចប់ និងប្រគល់ Digital APP និងផ្ទាំងព័ត៌មានសារធាណៈ (តារាងទិន្នន័យ)ឱ្យអង្គការ API អង្គការ CARE In STEDD និងអង្គភាពផ្សេងទៀត ។
- JAAP នឹងត្រូវបានតាមដានដោយ អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ ហើយត្រូវរាយ ការណ៍ជូនរាជរដ្ឋាភិបាល។

## គម្រោងទី១២ គម្រោងការច្នៃប្រឌិតថ្មីសម្រាប់គណនេយ្យភាពសង្គមនៅប្រទេសកម្ពុជា

**គោលដៅគម្រោង៖** គឺគាំទ្រដល់ប្រជាពលរដ្ឋក្នុងការបង្កើនសមត្ថភាពរបស់ពួកគេទទួលបាននូវកញ្ចប់ ព័ត៌មាន និងពង្រឹងបណ្តាញសម្រាប់ប្រមូលសកម្មភាពជួយគាំទ្រពួកគេក្នុងការកសាងតម្រូវការសាធារណៈ និងបង្កើត ដំណោះស្រាយដើម្បីលើកយកបញ្ហាអាទិភាពរបស់សហគមន៍។

**ដៃគូអនុវត្តការងារ៖** អង្គការវិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ

**ថវិកា៖** ៤៨១.៦២៧ ដុល្លារអាមេរិក ដោយទទួលបានមូលនិធិពីទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ ការអភិវឌ្ឍន៍អន្តរជាតិ តាមរយៈអង្គការសុខភាពអន្តរជាតិ៣៦០។

**តំបន់គោលដៅ៖** ១០សង្កាត់ ក្នុងក្រុងតាខ្មៅ និង០១ក្រុង (តាខ្មៅ) ខេត្តកណ្តាល ប្រទេសកម្ពុជា។





### លទ្ធផល៖

- បានគាំទ្រប្រជាពលរដ្ឋក្នុងការលើកកម្ពស់សមត្ថភាព ដើម្បីចូលទៅកាន់ព័ត៌មាន និងបណ្តាញសម្រាប់ប្រមូលសកម្មភាព ជួយបង្កើតតម្រូវការសាធារណៈ និងរកដំណោះស្រាយដើម្បីដោះស្រាយបញ្ហារបស់សហគមន៍។ គម្រោងបានសម្រេចលទ្ធផល (១២៨%) ធៀបនឹងគោលដៅប្រចាំឆ្នាំ២០២៣ ដែលមានអ្នកចូលរួមសរុបចំនួន ១,៦៧១នាក់ ក្នុងនោះមានស្ត្រី ១.០៤៦នាក់។
- ក្នុងរយៈពេល ៤ឆ្នាំ (២០២០ - ២០២៣) មានប្រជាពលរដ្ឋចំនួន ៦.៩១៩នាក់ (ស្រី ៤,៤០០នាក់) ទទួលបានការអប់រំអំពីសកម្មភាពអប់រំ និងបានផ្តល់មតិដោយផ្ទាល់ដើម្បីកែលម្អសេវាសាធារណៈរបស់ សង្កាត់ទាំង១០ មណ្ឌលសុខភាព០៥ សាលាបឋមសិក្សា២៤ ក្រុង១ (ក្រុងតាខ្មៅ) ខេត្តកណ្តាល។
- លើសពីនេះ មានមនុស្សចំនួន ៥.៨៨៣នាក់ (ស្ត្រី ៣.៧៧៤នាក់) បានទទួលការអប់រំពលរដ្ឋតាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គម និងវេទិកាអនឡាញ។
- នៅឆ្នាំ២០២៣ មានសកម្មភាពគណនេយ្យភាពសង្គមចំនួន ២៨៥ក្នុងចំណោម ៣៦៤ (៧៨%) ត្រូវបានអនុវត្ត។ សមិទ្ធផលសម្រេចបានគួរឱ្យកត់សំគាល់ ១២៨% ធៀបទៅនឹងសូចនាករគោលដៅ (៥០%)។
- សេវារដ្ឋបាលសង្កាត់ទាំង១០មានភាពប្រសើរឡើងជាមួយនឹងលទ្ធផលសម្រេចបាន ៨៩% នៃផែនការ សកម្មភាពរួមស្តីពីគណនេយ្យភាពសង្គមលើសេវាសង្កាត់។
- សេវាសាលាបឋមសិក្សាទាំង ២៤ មានភាពប្រសើរឡើង ជាមួយនឹងលទ្ធផលសម្រេចបាន ៧៤% នៃផែនការសកម្មភាពរួមស្តីពីគណនេយ្យភាពសង្គមលើសេវាសាលាបឋមសិក្សា។
- សេវាមណ្ឌលសុខភាពទាំង ០៥ មានភាពប្រសើរឡើងជាមួយនឹងលទ្ធផលសម្រេចបាន ៧៤% នៃផែនការសកម្មភាពរួមស្តីពីគណនេយ្យភាពសង្គមលើសេវាមណ្ឌលសុខភាព។
- សេវារដ្ឋបាលក្រុងតាខ្មៅបានចាប់ផ្តើមប្រសើរឡើងជាមួយនឹងផែនការសកម្មភាពរួមស្តីពីគណនេយ្យ ភាពសង្គមចំនួន ២០ ដែលបានគ្រោងទុក។

- រដ្ឋបាលថ្នាក់ក្រោមជាតិ (ខេត្ត ក្រុង សង្កាត់) នៃខេត្តកណ្ដាលបានបង្កើនភាពជាម្ចាស់ និងនិរន្តរភាពរបស់ខ្លួនដោយរដ្ឋបាលខេត្តកណ្ដាល បានវិភាជន៍ថវិកាសម្រាប់អនុវត្តសកម្មភាពគណនេយ្យភាពសង្គមក្នុងឆ្នាំ២០២៣ ក្នុងនោះរដ្ឋបាលខេត្តបានវិភាជន៍ចំនួន ៤.០០០.០០០រៀល ក្រុងតាខ្មៅចំនួន ២.០០០.០០០រៀល និងសង្កាត់ចំនួន ២.០០០.០០០រៀល។ សរុប ១០សង្កាត់ដែលសង្កាត់នីមួយៗទទួលបានចំនួន ៨.០០០.០០០រៀល ក្នុងឆ្នាំ២០២៣ និង២.០០០ ដុល្លារអាមេរិក សម្រាប់ឆ្នាំបន្ទាប់។ សង្កាត់ចំនួន ០៧ បានប្រើប្រាស់ថវិកាវិភាជន៍របស់រដ្ឋាភិបាលក្នុងការអនុវត្តការងារគណនេយ្យភាពសង្គមនៅខេត្តកណ្ដាលក្នុងឆ្នាំ២០២៣ ដែលជាការរួមចំណែកបន្ថែមចំពោះសកម្មភាពដែលបានផ្ដល់មូលនិធិដល់គម្រោង។
- នៅឆ្នាំ២០២៣ មានពលរដ្ឋចំនួន ៥៥៥នាក់ (ស្ត្រី ៣១៨នាក់) បានកើនចំណេះដឹង ស្ដីពីការអប់រំពលរដ្ឋ តាមរយៈសំនួរនៅលើគេហទំព័រហ្វេសប៊ុកអង្គការវិទ្យាស្ថានតស៊ូមតិ និងគោល នយោបាយ។
- ព័ត៌មានរបស់រាជរដ្ឋាភិបាលស្ដីពីថវិកាជាតិ និងថវិកាថ្នាក់ក្រោមជាតិ ការរៀបចំផែនការ និងថវិកាត្រូវបានបិទផ្សាយជាសាធារណៈ ១០០% ឱ្យពលរដ្ឋបានដឹងនៅសង្កាត់ទាំង ១០ និងក្រុង ០១។
- ចំណេះដឹងរបស់ពលរដ្ឋអំពីមុខងារ និងភារកិច្ចរបស់រដ្ឋបាលមូលដ្ឋានសម្រាប់ថវិកា ផែនការ និងសេវាបានកើនឡើង។ មនុស្សចំនួន ១.៦៧១នាក់ (ស្ត្រី ១.០៤៦នាក់) បានកើនចំណេះដឹង ពីការអប់រំពលរដ្ឋនូវផែនការសកម្មភាពរួមស្ដីពីគណនេយ្យភាពសង្គមកម្រិតសង្កាត់ និងកម្រិតក្រុង។ លទ្ធផលសម្រេចបាន ១២៨% ប្រៀបធៀបនឹងសូចនាករគោលដៅ ១.៣០០នាក់។
- បានបង្កើនចំនួនប្រជាពលរដ្ឋចូលរួម និងប្រមូលនូវសកម្មភាពដើម្បីឱ្យរដ្ឋាភិបាលមូលដ្ឋានមាន គណនេយ្យភាពលើសេវាសាធារណៈ។ ពលរដ្ឋបានទទួលការអប់រំហើយលទ្ធផលនៃចំណេះដឹង គឺមានការកើនឡើង។
- ព័ត៌មានដែលបង្កើតដោយពលរដ្ឋអំពីការសម្រេចចិត្តរបស់រាជរដ្ឋាភិបាលដំណើរការ និងការអនុវត្ត បានកើនឡើងនិងចែករំលែក។ សរុបមានកិច្ចប្រជុំដាក់ពិន្ទុចំនួន ១១ បានអនុវត្ត១០០%។ សង្កាត់ទាំង១០ និងក្រុង០១ បាននិងកំពុងអនុវត្តឧបករណ៍គណនេយ្យភាពសង្គមម្បីធ្វើឱ្យអាជ្ញាធរមូលដ្ឋានមានគណនេយ្យភាពលើសេវាសាធារណៈ។
- បានគាំទ្រអង្គការសង្គមស៊ីវិលសហគមន៍ចូលរួមតាមរយៈផែនការសកម្មភាពរួមស្ដីពីគណនេយ្យភាពសង្គម។ ផែនការសកម្មភាពរួមស្ដីពីគណនេយ្យភាពសង្គមកម្រិតសង្កាត់ចំនួន ១០ បានបង្កើត ឡើងនៅសង្កាត់ទាំង ១០ និងផែនការសកម្មភាពរួមស្ដីពីគណនេយ្យភាពសង្គមកម្រិតក្រុង ០១ បានបង្កើតឡើងនៅក្រុងតាខ្មៅ។
- គណៈកម្មការផែនការសកម្មភាពរួមស្ដីពីគណនេយ្យភាពសង្គមនៅសង្កាត់ទាំង ១០ និងក្រុង ០១ ត្រូវបានបង្កើត និងបានពង្រឹងដោយសារគំនិតផ្ដួចផ្ដើមពីសកម្មភាពគម្រោង។
- ផែនការសកម្មភាពរួម ស្ដីពី គណនេយ្យភាពសង្គមត្រូវបានសន្ទនាពិភាក្សាដោះស្រាយរវាងមន្ត្រី រដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល សហគមន៍ តំណាងប្រជាពលរដ្ឋ (អ្នកសម្របសម្រួល គណនេយ្យភាពសហគមន៍ និងគណៈកម្មការផែនការសកម្មភាពរួមស្ដីពីគណនេយ្យភាពសង្គម) តាមរយៈកិច្ចប្រជុំចំនួន ១១ រវាងអ្នកចូលរួមចម្រុះ។
- ៧៨% នៃផែនការសកម្មភាពរួមស្ដីពីគណនេយ្យភាពសង្គមឆ្នាំ២០២៣ ត្រូវបានអនុវត្តនៅសង្កាត់ ទាំង ១០ ដោយបានឆ្លើយតបទៅនឹងតម្រូវការផ្ដួចផ្ដើមរបស់ពលរដ្ឋ។
- លើកកម្ពស់ ឬពង្រឹងការចូលរួមរបស់ពលរដ្ឋជាស្ត្រី។ សរុប ១១នាក់ (ស្ត្រី ០៦នាក់) ត្រូវបាន ជ្រើសរើសអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ដែលមានស្នាដៃគម្រូ។

## សកម្មភាព

- កិច្ចប្រជុំផ្ទាល់ចំនួន ៣០ បានរៀបចំឡើងដោយមានពលរដ្ឋចូលរួម ៩៧៩នាក់ (ស្ត្រី ៦៣៦នាក់) ស្ដីពីសិទ្ធិ និងការចូលរួមដំណើរការសេវាសាធារណៈ របស់សាលាបឋមសិក្សា មណ្ឌលសុខភាព សង្កាត់ និងក្រុង។
- វគ្គបណ្ដុះបណ្ដាលស្ដីពីគណនេយ្យភាពសង្គមកញ្ចប់ព័ត៌មានសម្រាប់ពលរដ្ឋ និងកិច្ចដាក់ពិន្ទុ សហគមន៍ ត្រូវបានបណ្ដុះបណ្ដាលទៅដល់អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ចំនួន ៣៥នាក់ (ស្ត្រី ២១នាក់)។





- ក្រុមតេឡេក្រាមរបស់អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍បានបង្កើត។ បណ្តាញសង្គម មួយនេះ ត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយជាមួយនឹងអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ នៅក្រុងតាខ្មៅដើម្បីផ្តល់ព័ត៌មានពីសម្ភារវគ្គបណ្តុះបណ្តាលការណាត់ជួបការជូនដំណឹងអំពីការរៀបចំកិច្ចប្រជុំនានា។
- បានពិភាក្សាមេរៀនដែលបានរៀនសូត្របញ្ហាប្រឈម និងករណីសិក្សាល្អៗសម្រាប់ការអនុវត្តគម្រោង “ការច្នៃប្រឌិតថ្មីសម្រាប់គណនេយ្យភាពសង្គមនៅកម្ពុជា” ជាមួយអ្នកសម្របសម្រួលគណនេយ្យភាព សហគមន៍ចំនួន ២៨នាក់ (ស្ត្រី ១៨នាក់)។
- កិច្ចប្រជុំបង្កើតចក្ខុវិស័យរួមចំនួន ៣៩ បានរៀបចំឡើងដោយមានអ្នកចូលរួមចំនួន ៥៩៩នាក់ (ស្ត្រី ៣៥០នាក់) ដែលបានលើកឡើងអំពីការរំពឹងទុករបស់សហគមន៍បញ្ហានានា បញ្ហាអាទិភាព ទៅតាមសេវានីមួយៗ (សាលាបឋមសិក្សា មណ្ឌលសុខភាព និងសង្កាត់) និងបានរៀនសូត្រ អំពីដំណើរការនៃការបង្កើតទស្សនៈវិស័យ គោលបំណង អត្ថប្រយោជន៍ គោលការណ៍ទាំង៧ វដ្តនៃការអនុវត្តគណនេយ្យភាពសង្គមរបស់គម្រោង។
- កិច្ចប្រជុំដាក់ពិន្ទុសហគមន៍ចំនួន ៣៩ បានរៀបចំឡើង ដោយមានពលរដ្ឋចូលរួមចំនួន ១.២០៤នាក់ (ស្ត្រី ៧៧៤នាក់) និងកិច្ចប្រជុំដាក់ពិន្ទុដោយអ្នកផ្តល់សេវាចំនួន ៣៩ បានរៀបចំឡើង ដោយមានមន្ត្រីរដ្ឋាភិបាលចំនួន ៣០២នាក់ (ស្ត្រី ១៥៧នាក់) ជាអ្នកផ្តល់សេវាបានចូលរួម ដាក់ពិន្ទុលើសេវាសង្កាត់ សាលាបឋមសិក្សា និងមណ្ឌលសុខភាព ព្រមទាំងបានរៀបចំផែនការសម្រាប់ធ្វើឱ្យសេវាសាធារណៈប្រសើរឡើង។
- មនុស្សចំនួន ២៥០នាក់ (ស្ត្រី ១៥៦នាក់) បានចូលរួមក្នុងកិច្ចប្រជុំរួម។ អ្នកសម្របសម្រួល គណនេយ្យភាពសហគមន៍បានទទួលការយល់ដឹងអំពីរបៀប នៃកិច្ចប្រជុំរួមរបៀបចាត់អាទិភាព សកម្មភាពដើម្បីព្រមព្រៀងហើយជំនាញរបស់ពួកគេបានអភិវឌ្ឍន៍ដោយការសម្របសម្រួលកិច្ចប្រជុំ និងធ្វើបទបង្ហាញផែនការសកម្មភាពរួមស្តីពីគណនេយ្យភាពសង្គម។ បច្ចេកទេសផែនការអនុវត្ត និងធនធានសក្តានុពលនៃការផ្តល់មូលនិធិដើម្បីគាំទ្រដល់ការអនុវត្តផែនការសកម្មភាពរួមស្តីពីគណនេយ្យភាពសង្គមត្រូវបានរៀនសូត្រ។ លើសពីនេះទៅទៀត ពួកគេក៏បានរៀនសូត្រពី សាមគ្គីភាព សហគមន៍ ហើយនិងជំនាញពីការគ្រប់គ្រងជម្លោះ និងការស្វែងរកដំណោះស្រាយបែបឈ្នះឈ្នះ។ បន្ថែមពីនេះមានអ្នកចូលរួមកិច្ចប្រជុំរួមកម្រិតក្រុង ចំនួន ២៦នាក់ (ស្ត្រី ១៩នាក់)។
- គណៈកម្មាធិការផែនការសកម្មភាពរួមស្តីពីគណនេយ្យភាពសង្គមចំនួន ១៥៦នាក់ (ស្ត្រី ៧៥នាក់) បានសម្របសម្រួលកិច្ចប្រជុំត្រួតពិនិត្យ និងតាមដានវឌ្ឍនភាពផែនការសកម្មភាពរួមស្តីពី គណនេយ្យភាពសង្គមទាំង ១០សង្កាត់។ មានសកម្មភាពចំនួន ២៨៥ ក្នុងចំណោម ៣៦៤ ស្មើនឹង៧៨% ក្នុងឆ្នាំទី៣ ត្រូវបានដោះស្រាយ។ លទ្ធផលនេះសម្រេចលើសផែនការ ២៨% ប្រៀបធៀបនឹងសូចនករគោលដៅ (៥០%)។ ក្នុងនោះមានសកម្មភាពដែលមានការគាំទ្រពីខាងក្រៅ ចំនួន ៣៣ ក្នុងចំណោម ៨០បានអនុវត្ត ស្មើនឹង ៤០% និងសកម្មភាពដែលមានការគាំទ្រ ពីខាងក្នុងចំនួន ២៥២ ក្នុងចំណោម ២៨៤ បានអនុវត្តន៍ស្មើនឹង ៨៩%។
- បានផ្តល់វគ្គបណ្តុះបណ្តាលទៅដល់សមាជិកគណៈកម្មាធិការផែនការសកម្មភាពរួម ស្តីពី គណនេយ្យភាពសង្គមចំនួន ១០០នាក់ (ស្ត្រី ៤៩នាក់)។ ការយល់ដឹងស៊ីជម្រៅទៅលើតួនាទី និងភារកិច្ចការទទួលខុសត្រូវរបស់គណៈកម្មាធិការផែនការសកម្មភាពរួមស្តីពីគណនេយ្យភាពសង្គម ការប្រមូលធនធានក្នុងស្រុកដើម្បីគាំទ្រផែនការសកម្មភាពរួមស្តីពីគណនេយ្យភាពសង្គម និងការពង្រឹងភាពជាម្ចាស់របស់គណៈកម្មាធិការផែនការសកម្មភាពរួមស្តីពីគណនេយ្យភាពសង្គម។ លើសពីនេះ ការយល់ដឹង និង ការប្រើប្រាស់ឧបករណ៍ដើម្បីត្រួតពិនិត្យតាមដានពីវឌ្ឍនភាពផែនការសកម្មភាពរួម ស្តីពីគណនេយ្យភាពសង្គម ដោយគណៈកម្មាធិការផែនការ

សកម្មភាពរួមស្តីពីគណនេយ្យភាពសង្គម។ បន្ថែមពីនេះ មានសមាជិកគណៈកម្មាធិការផែនការសកម្មភាពរួមស្តីពីគណនេយ្យភាពសង្គមកម្រិត ក្រុងចំនួន ១៧នាក់ (ស្ត្រី ០៩នាក់) បានចូលរួមវគ្គបណ្តុះបណ្តាលវគ្គខាងលើផងដែរ។

- បានគាំទ្រពលរដ្ឋចំនួន ៨៣៨នាក់ (ស្ត្រី ៥៥១នាក់) ចូលរួមការផ្សព្វផ្សាយផែនការសកម្មភាព រួមស្តីពីគណនេយ្យភាពសង្គមកម្រិតសង្កាត់ និងកម្រិតក្រុង នៅទូទាំងសង្កាត់ទាំង ១០។

## មេរៀនជាបទពិសោធន៍៖





- គណៈកម្មការជ្រើសរើសអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ដែលមានស្នាដៃគំរូមាន ០៤នាក់ ដូច្នេះចំនួននេះពិបាកនឹងធ្វើការសម្រេចចិត្តឱ្យមានប្រសិទ្ធភាព។ យើងសូមស្នើឱ្យមាន សមាសភាពគណៈកម្មការចំនួន ០៥នាក់ និងបន្ថែម ០១នាក់ទៀតមកពីអង្គការសុខភាពគ្រួសារ អន្តរជាតិ៣៦០ ជាអ្នកសង្កេតការ។
- យើងសូមឱ្យមានការថតចម្លងផែនការសកម្មភាពរួមស្តីពីគណនេយ្យភាពសង្គមសម្រាប់ពលរដ្ឋដើម្បី ពួកគេងាយស្រួលក្នុងការត្រួតពិនិត្យ និងតាមដានពីវឌ្ឍនភាពផែនការសកម្មភាពរួមស្តីពីគណនេយ្យ ភាពសង្គមតាមសង្កាត់របស់គេផ្ទាល់។
- អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍មួយចំនួនមិនបានចូលរួមប្រជុំប្រចាំខែរបស់សង្កាត់ ដោយសារហេតុផលផ្ទាល់ខ្លួន។ ដូច្នេះក្រុមការងារគម្រោងបានទាក់ទងអ្នកសម្របសម្រួល គណនេយ្យភាពសហគមន៍ដទៃទៀតនៅក្នុងសង្កាត់ដដែលមកចូលរួមជំនួស។
- សាលារៀនជាកន្លែងដ៏ល្អបំផុតសម្រាប់កិច្ចប្រជុំផ្សព្វផ្សាយកញ្ចប់ព័ត៌មានប្រជាពលរដ្ឋដោយផ្ទាល់ ប៉ុន្តែវាក៏មានការរំខានខ្លះនៅពេលសិស្សចេញលេង។ អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ បានជួយសម្របសម្រួលសិស្សដោយឱ្យពួកគេលេងឱ្យឆ្ងាយពីបន្ទប់ប្រជុំ។
- បោះពុម្ពប្រតិទិនគម្រោង ដោយមានរូបភាព និងអត្ថបទដែលបញ្ជាក់ពីសិទ្ធិ ស្តង់ដារការបំពេញការងាររបស់រដ្ឋបាលសង្កាត់ មណ្ឌលសុខភាព និងសាលាបឋមសិក្សា គឺជាសម្ភារដ៏មានសារសំខាន់ សម្រាប់ធ្វើការផ្សព្វផ្សាយកញ្ចប់ព័ត៌មានជូនប្រជាពលរដ្ឋដោយផ្ទាល់ និងផ្សព្វផ្សាយតាមឧឃោសន សព្ទវាមិនត្រឹមតែជួយឱ្យពលរដ្ឋបានរៀនសូត្រនៅក្នុងពេលប្រជុំប៉ុណ្ណោះទេថែមទាំងរៀនសូត្រនៅផ្ទះថែមទៀត។
- កិច្ចប្រជុំត្រៀមជាកិច្ចប្រជុំដ៏សំខាន់ មុនកិច្ចប្រជុំណែនាំទូទាំងសង្កាត់ កិច្ចប្រជុំបង្កើតចក្ខុវិស័យរួម។ អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍មានឱកាសរៀបចំសម្ភារទុកជាមុន និងបញ្ជាក់ សកម្មភាពមុនពេលអនុវត្ត។ លើសពីនេះ ពួកគេបានរៀបចំផែនការសកម្មភាព និងពេលវេលាសម្រាប់ចុះអនុវត្តសកម្មភាពជាមួយក្រុមរបស់គេ។
- ក្រុមបុគ្គលិកគម្រោងបានធ្វើការបែងចែកសមាជិកជា ០២ក្រុមដើម្បីអនុវត្តកម្មវិធីប្រជុំណែនាំទូទាំងសង្កាត់ និងកិច្ចប្រជុំបង្កើតចក្ខុវិស័យរួមទាំង ១០សង្កាត់។ លើសពីនេះក្រុមនីមួយៗត្រូវបញ្ចូលទិន្នន័យគម្រោងក្នុងប្រព័ន្ធត្រួតពិនិត្យតាមដាននិងវាយតម្លៃ (កូបូ)។
- មានឧឃោសនសព្ទចំនួន ០២ សម្រាប់សម្រាប់ប្រជុំផ្សព្វផ្សាយតាមមូលដ្ឋាន។ វាមានសារៈសំខាន់ ដោយវាបានជួយបំពងសម្លេងឮច្បាស់ខ្លាំង ទៅដល់អ្នកចូលរួមទាំងអស់ហើយបានជួយឱ្យអ្នកសម្រប សម្រួលមិនចាំបាច់ប្រើសម្លេងខ្លាំងក្នុងពេលប្រជុំ។

- សាលារៀនជាកន្លែងដ៏ល្អបំផុត សម្រាប់កិច្ចប្រជុំផ្សព្វផ្សាយនានាព្រោះមានមានភាពងាយស្រួលដោយ មានសម្ភារគ្រប់គ្រាន់ ដូចជា កៅអី តុ ក្តារខៀន និងកង្ហារសម្រាប់អ្នកចូលរួម។
- ការចូលរួមជាមួយការិយាល័យអប់រំយុវជន និងកីឡាក្រុង ដោយអញ្ជើញសិស្សអនុវិទ្យាល័យ និងវិទ្យាល័យចូលរួម ពិតជាមានសារៈសំខាន់ណាស់។ វាបានជួយបង្កើនយុវជន ក្នុងការចូលរួមជាមួយ គម្រោងផងដែរ។
- មន្ត្រីបង្គោលគណនេយ្យភាពសង្គមក្រុងតាខ្មៅ បានផ្តល់នូវគាំទ្រយ៉ាងខ្លាំង នៅក្នុងកិច្ចប្រជុំដាក់ពិន្ទុ ដោយអ្នកផ្តល់សេវា និងកិច្ចប្រជុំដាក់ពិន្ទុដោយប្រជាពលរដ្ឋ នៅសាលាក្រុងតាខ្មៅ និងសាលាបឋមសិក្សាតាខ្មៅ។
- អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ថ្មីៗ បានរៀនសូត្របទពិសោធន៍ជាច្រើនពីអ្នកសម្រប សម្រួលគណនេយ្យភាពសហគមន៍ចាស់ ដូចជា ការសម្របសម្រួល ការរៀបចំ ការទំនាក់ទំនង ការធ្វើបទបង្ហាញជាដើម។ល។
- ការគាំទ្របច្ចេកទេសពីអង្គការសុខភាពគ្រួសារអន្តរជាតិ៣៦០ តាមរយៈវគ្គបណ្តុះបណ្តាល រំលឹកឡើងវិញ ជាវិធីសាស្ត្រដ៏ល្អ ដើម្បីជួយរំលឹកបុគ្គលិកគម្រោង ឱ្យសម្រេចបានតាមគោលដៅដែលបានកំណត់។

## បញ្ហាប្រឈម៖





- សមាជិកគណៈកម្មាធិការផែនការសកម្មភាពរួមស្តីពីគណនេយ្យភាពសង្គមអវត្តមាននៅពេលវគ្គបណ្តុះបណ្តាលដោយសារមូលហេតុផ្ទាល់ខ្លួនរបស់គេ។ ដូច្នេះបុគ្គលិកគម្រោងបានទំនាក់ទំនងទៅប្រធានគណៈកម្មាធិការផែនការសកម្មភាពរួមស្តីពីគណនេយ្យភាពសង្គមដើម្បីជួយអន្តរាគមន៍។
- សមាជិកគណៈកម្មាធិការផែនការសកម្មភាពរួមស្តីពីគណនេយ្យភាពសង្គមមួយចំនួនថ្មីសម្រាប់វគ្គ បណ្តុះបណ្តាល ដោយពួកគេទើបតែបានជាប់ឆ្នោតជាក្រុមប្រឹក្សាឃុំ សង្កាត់។ ដើម្បីដោះស្រាយ បញ្ហានេះ បុគ្គលិកគម្រោងបានបណ្តុះបណ្តាលតាមជំហានៗ និងសួរបញ្ជាក់តាមប្រធានបទនីមួយៗ។ លើសពីនេះទៅទៀត ពួកគេបានធ្វើតេស្តមុន និងក្រោយវគ្គផងដែរ។
- នៅទីតាំងសង្កាត់មួយចំនួន មិនមានកន្លែងសមរម្យសម្រាប់វគ្គបណ្តុះបណ្តាលសម្រាប់គណៈកម្មាធិការ ផែនការសកម្មភាពរួមស្តីពីគណនេយ្យភាពសង្គមទេ។ កម្មវិធីវគ្គបណ្តុះបណ្តាលខ្លះក៏ជាន់គ្នានឹងម្មវិធី ប្រជុំរបស់សង្កាត់ផងដែរ បុគ្គលិកគម្រោងបានប្តូរទីកន្លែងបណ្តុះបណ្តាលទៅកន្លែងផ្សេងៗទៀត ដូចជាវត្តជាដើម។
- ការធ្វើសមាហរណកម្មផែនការសកម្មភាពរួមស្តីពីគណនេយ្យភាពសង្គម ទៅក្នុងកម្មវិធីវិនិយោគឃុំ សង្កាត់ និងធ្វើបទបង្ហាញនៅសិក្ខាសាលាថ្នាក់ក្រុង គឺជាន់គ្នានឹងកិច្ចប្រជុំប្រចាំឆ្នាំរបស់អង្គការ វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ។ មន្ត្រីក្រុងតាខ្មៅក៏បានកំណត់ចំនួនអ្នកសម្របសម្រួល គណនេយ្យភាពសហគមន៍ដើម្បីចូលរួម។
- អ្នកចូលរួមជាស្ត្រីមួយចំនួនបាននាំកូនតូចៗរបស់គេមកជាមួយក្នុងកម្មវិធីប្រជុំផ្សព្វផ្សាយនានារបស់ គម្រោងដូច្នេះពួកគេមិនបានចូលរួមពេញលេញទេ។ ដើម្បីជៀសវាងការរំខាននានាពីកូនតូចៗ បុគ្គលិកគម្រោងបានផ្តល់នំ និងស្ករគ្រាប់មួយចំនួនដល់ពួកគេ។
- អ្នកចូលរួមមួយចំនួនជាអនក្ខរជន ហើយមួយចំនួនជាមនុស្សចាស់ ពួកគេមានការលំបាកក្នុងការបំពេញតេស្តមុន និងក្រោយវគ្គសម្រាប់ការផ្សព្វផ្សាយកញ្ចប់ព័ត៌មានរបស់ពលរដ្ឋ ដូច្នេះអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍បានជួយសម្របសម្រួលយ៉ាងច្រើនលើបញ្ហានេះ។
- សង្កាត់មួយចំនួនតូចមិនបានអញ្ជើញអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ចូលរួមកិច្ចប្រជុំប្រចាំខែទេ បុគ្គលិកគម្រោងបានរាយការណ៍បញ្ហានេះជូនចៅសង្កាត់។

- អ្នកផ្តល់សេវាមួយចំនួនមិនបានចូលរួមកិច្ចប្រជុំណែនាំទូទាំងសង្កាត់និងកិច្ចប្រជុំបង្កើតចក្ខុវិស័យរួមទេ ហើយមួយចំនួនទៀតក៏មកយឺតយ៉ាវដោយសារហេតុផលផ្ទាល់ខ្លួន។ ទោះបីយ៉ាងណាបុគ្គលិកគម្រោងបានទំនាក់ទំនងជាមួយថ្នាក់ដឹកនាំរបស់ពួកគេដើម្បីជួយអន្តរាគមន៍។
- ពលរដ្ឋមួយចំនួនមិនបានចូលរួមកិច្ចប្រជុំណែនាំទូទាំងសង្កាត់និងកិច្ចប្រជុំបង្កើតចក្ខុវិស័យរួមទេ ហើយមួយចំនួនទៀតក៏មកយឺតយ៉ាវដោយសារហេតុផលផ្ទាល់ខ្លួន។ ទោះបីយ៉ាងណាបុគ្គលិកគម្រោង បានអញ្ជើញពលរដ្ឋដែលនៅក្បែរនោះមកចូលរួមជំនួស។
- ជនមានពិការភាពភាគច្រើនពិបាកក្នុងការធ្វើដំណើរមកចូលរួមកិច្ចប្រជុំណែនាំទូទាំងសង្កាត់និងកិច្ចប្រជុំបង្កើតចក្ខុវិស័យរួមដោយសារទីកន្លែងប្រជុំនៅឆ្ងាយពីផ្ទះរបស់ពួកគេ ដូច្នេះបុគ្គលិកគម្រោងបាន សម្របសម្រួលជាមួយសន្តិសុខភូមិដើម្បីជូនពួកគេមកទីកន្លែងប្រជុំ។
- វាពិតជាមានការលំបាកបន្តិច ក្នុងការអញ្ជើញសិស្សមកចូលរួមក្នុងកិច្ចប្រជុំផ្សព្វផ្សាយកញ្ចប់ព័ត៌មាន ក្រុង ស្រុកដោយសារពួកគេស្ថិតក្នុងវិស្សមកាល។ បុគ្គលិកគម្រោងបានធ្វើការយ៉ាងសកម្មជាមួយ ការិយាល័យអប់រំក្រុងតាខ្មៅ ដើម្បីដោះស្រាយបញ្ហានេះ។
- នៅមិនទាន់មានទិន្នន័យលទ្ធផលបំពេញការងាររបស់ក្រុងតាខ្មៅសម្រាប់ផ្សព្វផ្សាយកញ្ចប់ព័ត៌មាន ក្រុង ស្រុកនៅឡើយទេ ដូច្នេះបុគ្គលិកគម្រោងបានបោះពុម្ពទិន្នន័យលទ្ធផលបំពេញការងាររបស់ ខណ្ឌសែនសុខជាគម្រូសម្រាប់កិច្ចប្រជុំផ្សព្វផ្សាយនេះ។
- កិច្ចប្រជុំដាក់ពិន្ទុនៅតាមសង្កាត់មួយចំនួន ព្រមទាំងកិច្ចប្រជុំកម្រិតក្រុងផងដែរបានពន្យាពេលដោយ សារព្រឹត្តិការណ៍ ឬកម្មវិធីរបស់អាជ្ញាធរមូលដ្ឋានមួយចំនួនបានរៀបចំឡើងស្របពេលគ្នាដូចជា ការសម្ពោធផ្លូវ និងស្ពានមួយចំនួន។ បុគ្គលិកគម្រោងបានធ្វើការជាមួយអាជ្ញាធរ មូលដ្ឋានក្នុងការ ផ្លាស់ប្តូរពេលវេលាប្រជុំ។
- បើទោះបីជាមានការគាំទ្រពីរដ្ឋបាលក្រុងតាខ្មៅ ក្នុងការសម្របសម្រួលអញ្ជើញពលរដ្ឋមកប្រជុំ ដាក់ពិន្ទុក្រុងក៏ដោយ កិច្ចប្រជុំដាក់ពិន្ទុចំនួន ០២ មិនមានពលរដ្ឋចូលរួមគ្រប់ចំនួនទេ ដូច្នេះបុគ្គលិកគម្រោង បានលើកពេលប្រជុំ និងប្តូរវិធីសាស្ត្រដោយបោះពុម្ពសំបុត្រអញ្ជើញ និងអនុញ្ញាតិឱ្យអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ អញ្ជើញពលរដ្ឋដែលធ្លាប់ប្រើប្រាស់សេវាការិយាល័យច្រកចេញចូលតែមួយក្រុងតាខ្មៅ។ បន្ថែមពីនេះ បុគ្គលិកគម្រោងបានអង្គុយរងចាំនៅការិយាល័យច្រកចេញចូលតែមួយក្រុងតាខ្មៅពេញមួយថ្ងៃ ដើម្បីអញ្ជើញពលរដ្ឋផ្ទាល់ដែលមកទទួលសេវាដើម្បីចូលរួមកិច្ចប្រជុំដាក់ពិន្ទុក្រុង។
- កម្មវិធីវិទ្យុតតៀងទុកមួយបានរៀបចំឡើងនៅថ្ងៃចុងក្រោយនៃត្រីមាសទី៤ របស់គម្រោងធ្វើឱ្យ បុគ្គលិកគម្រោងត្រូវចំណាយពេលមួយសប្តាហ៍ ដើម្បីរៀបចំវាហើយនោះជាពេលវេលាដែលត្រូវធ្វើ របាយការណ៍ប្រចាំឆ្នាំផងដែរ។
- បុគ្គលិកគម្រោង ០៣នាក់ បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពីអក្ខរកម្មគណនេយ្យភាពសង្គម ដែលរៀបចំឡើងដោយអង្គការ ODC នៅ ០៣ថ្ងៃ ចុងក្រោយនៃត្រីមាសទី៤ របស់គម្រោង ហើយនោះជាពេលវេលាដែលត្រូវបញ្ចូលទិន្នន័យនៅក្នុងប្រព័ន្ធត្រួតពិនិត្យ តាមដាន និងវាយតម្លៃ (កូបូ) ផងដែរ។
- អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍មួយចំនួនបានសុំលាឈប់ដោយសារហេតុផលផ្ទាល់ខ្លួនរបស់ពួកគេបុគ្គលិកគម្រោងបានជ្រើសរើសអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ថ្មីមួយចំនួនដើម្បីជំនួសបន្តអនុវត្តគម្រោង។
- កម្រិតនៃការយល់ដឹង និងបទពិសោធន៍របស់អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ថ្មីដែល ទើបនឹងជ្រើសរើសនៅមានកម្រិត ដែលតម្រូវឱ្យបុគ្គលិកគម្រោងត្រូវប្រាកដក្នុងការគ្រប់គ្រង និងបែង ចែកពួកគេ ដើម្បីចុះបំពេញការងារឱ្យមានប្រសិទ្ធិភាពនៅតាមសហគមន៍។
- បុគ្គលិកគម្រោងមានកិច្ចការជាច្រើនដែលត្រូវសម្របសម្រួលមិនត្រឹមតែស្នើសុំថវិកាដើម្បីអនុវត្តកម្មវិធីប៉ុណ្ណោះទេ មានទាំងទូទាត់ថវិកា ធ្វើរបាយការណ៍ និងការបញ្ចូលទិន្នន័យក្នុងប្រព័ន្ធត្រួតពិនិត្យ តាមដាន និងវាយតម្លៃ (កូបូ)ថែមទៀត។

## ផែនការបន្ទះ

- បើកវគ្គបណ្តុះបណ្តាលរំលឹកឡើងវិញ ម៉ូឌុល០១ ដល់ម៉ូឌុល០៤ សម្រាប់អ្នកសម្របសម្រួល គណនេយ្យភាពសហគមន៍ (សរុប ០៥ថ្ងៃ)។
- កិច្ចប្រជុំឆ្លុះបញ្ចាំងប្រចាំឆ្នាំ ០១ថ្ងៃ។

- កិច្ចប្រជុំផ្សព្វផ្សាយកញ្ចប់ព័ត៌មានសម្រាប់ពលរដ្ឋដោយផ្ទាល់នៅតាមភូមិ (០២ ប្រជុំរៀបចំជាមួយ ពលរដ្ឋ និង ០១ ប្រជុំរៀបចំជាមួយយុវជននៅសាលារៀន)។
- ប្រជុំត្រៀមជាមួយអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍មុនពេលប្រជុំណែនាំទូទាំងសង្កាត់ និងកិច្ចប្រជុំរួមតាមសង្កាត់។
- ប្រជុំណែនាំទូទាំងសង្កាត់ និងកិច្ចប្រជុំរួមតាមសង្កាត់ដើម្បីធានាឱ្យមានការយល់ដឹង និងកិច្ចសហការ រវាងអ្នកពាក់ព័ន្ធទាំងអស់។
- ប្រជុំត្រៀមជាមួយអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍មុនពេលប្រជុំដាក់ពិន្ទុសហគមន៍។
- ប្រជុំដាក់ពិន្ទុសហគមន៍ដោយអ្នកផ្តល់សេវា។
- ប្រជុំដាក់ពិន្ទុសហគមន៍ដោយពលរដ្ឋ។
- ប្រជុំត្រៀមជាមួយអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍មុនពេលកិច្ចប្រជុំរួម។
- ប្រជុំរួម ដើម្បីបង្កើតផែនការរួមស្តីពីគណនេយ្យភាពសង្គម។
- ប្រជុំផ្សព្វផ្សាយផែនការសកម្មភាពរួមស្តីពីគណនេយ្យភាពសង្គម (កម្រិតសង្កាត់ និងក្រុង)។
- ប្រជុំត្រីមាសតាមដាន និងត្រួតពិនិត្យពីវឌ្ឍនភាពផែនការសកម្មភាពរួមស្តីពីគណនេយ្យភាពសង្គម។
- កិច្ចប្រជុំផ្សព្វផ្សាយកញ្ចប់ព័ត៌មានសម្រាប់ពលរដ្ឋ កម្រិតក្រុងដោយផ្ទាល់នៅតាមភូមិ។
- ប្រជុំត្រៀមជាមួយអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍មុនពេលប្រជុំដាក់ពិន្ទុសហគមន៍ កម្រិតក្រុង។
- ប្រជុំដាក់ពិន្ទុសហគមន៍កម្រិតក្រុងដោយពលរដ្ឋ។
- ប្រជុំដាក់ពិន្ទុសហគមន៍កម្រិតក្រុងដោយអ្នកផ្តល់សេវា។
- ប្រជុំត្រៀមជាមួយអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍មុនពេលប្រជុំរួមកម្រិតក្រុង។
- ប្រជុំរួម ដើម្បីបង្កើតផែនការរួមស្តីពីគណនេយ្យភាពសង្គមកម្រិតក្រុង។
- បើកវគ្គបណ្តុះបណ្តាលគណៈកម្មាធិការផែនការរួមស្តីពីគណនេយ្យភាពសង្គមកម្រិតក្រុង។
- ប្រជុំត្រីមាសតាមដាន និងត្រួតពិនិត្យពីវឌ្ឍនភាពផែនការសកម្មភាពរួមស្តីពីគណនេយ្យភាពសង្គម កម្រិតក្រុង។
- ការអប់រំតាមអនឡាញ ដោយសួរសំនួរអំពីកញ្ចប់ព័ត៌មានប្រជាពលរដ្ឋ។
- ការប្រកួតប្រជែងអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ដោយសួរសំនួរអំពីកញ្ចប់ព័ត៌មាន ប្រជាពលរដ្ឋ។
- យុទ្ធនាការផ្សព្វផ្សាយកញ្ចប់ព័ត៌មានប្រជាពលរដ្ឋតាមគេហទំព័រហ្វេសប៊ុករបស់អង្គការវិទ្យាស្ថាន តស៊ូមតិ និងគោលនយោបាយ។
- បណ្តុះបណ្តាលឡើងវិញពីការផលិតព័ត៌មានតាមទូរសព្ទដៃ។
- ផលិតវីដេអូព័ត៌មានតាមទូរសព្ទដៃ។
- ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីយុទ្ធនាការផ្សព្វផ្សាយតាមបណ្តាញសង្គម។
- រៀបចំកិច្ចប្រជុំប្រចាំឆ្នាំ។
- ជ្រើសរើសអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ដែលមានស្នាដៃគម្រូ។
- ផ្តល់រង្វាន់លើកទឹកចិត្តដល់អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ដែលមានស្នាដៃគម្រូ។
- កៀរគអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ចូលរួមកិច្ចប្រជុំប្រចាំខែជាមួយសង្កាត់ និងក្រុង។
- គាំទ្រអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ចូលរួមកិច្ចប្រជុំនានាជាមួយក្រុង និងខេត្ត។
- ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការរំលឹកឡើងវិញ ការប្រមូលទិន្នន័យមានដែលមានគុណភាព ការវិភាគទិន្នន័យ របាយការណ៍ ការសរសេរសាច់រឿងជោគជ័យ និងបញ្ហានានារបស់ប្រព័ន្ធ តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ។

## ករណីសិក្សា៖

## គណនេយ្យភាពសង្គមនាំឱ្យបរិស្ថានសង្កាត់ ប្រសើរឡើងសម្រាប់ប្រជាពលរដ្ឋមូលដ្ឋាន



**សាលាសង្កាត់រកាខ្ពស់** ស្ថិតនៅក្នុងភូមិព្រៃកសំរោង សង្កាត់រកាខ្ពស់ ក្រុងតាខ្មៅ ខេត្តកណ្ដាល។ សាលាសង្កាត់សាងសង់ពីបេតុងរឹងមាំ ប្រក់ដំបូលក្បឿង ពណ៌ក្រហម តាមស្តង់ដារក្រសួងមហាផ្ទៃ។ សង្កាត់មានសេវាជាច្រើន ដូចជាការចុះបញ្ជីអត្រានុកូលដ្ឋាន អត្តសញ្ញាណប័ណ្ណ ការអប់រំផ្សព្វផ្សាយពីសុខមាលភាពមាតា និងទារក ការប្រឆាំងនឹងអំពើហិង្សា យេនឌ័ ការទប់ស្កាត់អំពើហិង្សាលើស្ត្រី និងកុមារ ការការពារកុមារ អនាម័យទឹកស្អាត ការលើកកម្ពស់សិទ្ធិជនមានពិការភាព ជួយគ្រួសារក្រីក្រ មនុស្សចាស់ ការប្រឆាំងគ្រឿងញៀន និងគ្រឿងស្រវឹង ពង្រឹងសមភាពយេនឌ័រ និងការងារសង្គម។ កាលពីមុនទីធ្លាសង្កាត់មិនសូវជាធំទូលាយ មិនសូវមានសណ្ដាប់ធ្នាប់ល្អ មិនមានព័ត៌មានថ្មីៗនៅលើក្ដារខៀនព័ត៌មាន មានតែព័ត៌មាន ចាស់ៗនៅលើក្ដារខៀនព័ត៌មាន ការផ្ដល់សេវាមិនទាន់បានលឿនរហ័ស ហើយកិច្ចប្រជុំប្រចាំខែរបស់សង្កាត់ក៏មិនបាន អញ្ជើញអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ និងតំណាងពលរដ្ឋចូលរួមផងដែរ ។ នៅសាលាសង្កាត់មិនមានជំរាលជនមានពិការភាព ក្រុមប្រឹក្សាសង្កាត់ និងមន្ត្រីបង្គោលគណនេយ្យភាពសង្គមក៏មិនសូវបានចូលរួមសកម្មភាពនានារបស់ការងារគណនេយ្យភាពសង្គម ហើយក៏មិនមានអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ធ្វើការនៅសង្កាត់នេះដែរ។ លើសពីនេះ លោកចៅសង្កាត់ ដែលជាប្រធាន គណៈកម្មាធិការផែនការសកម្មភាពរួមស្តីពីគណនេយ្យភាពសង្គម អវត្តមានញឹកញាប់សម្រាប់កិច្ចប្រជុំគណនេយ្យភាពសង្គម និងមិនសូវបានចូលរួមកិច្ចប្រជុំនានាជាមួយគម្រោងការច្នៃប្រឌិតថ្មីសម្រាប់គណនេយ្យភាពសង្គមនៅកម្ពុជា ដូច្នេះសមាជិកគណៈកម្មាធិការផែនការសកម្មភាពរួមស្ដីពីគណនេយ្យភាពសង្គមមួយចំនួនក៏មិនបានចូលរួមពេញលេញជាមួយគម្រោងទេ។



ចាប់តាំងពីចុងឆ្នាំ២០២០មក អង្គការវិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ ដែលទទួលបានជំនួយពីពលរដ្ឋអាមេរិក តាមរយៈអង្គការសុខភាពគ្រួសារអន្តរជាតិ៣៦០ បាននិងកំពុងអនុវត្តគម្រោង “ការច្នៃប្រឌិតថ្មី សម្រាប់គណនេយ្យភាពសង្គមនៅកម្ពុជា” នៅក្រុងតាខ្មៅ ក្នុងនោះក៏មានសង្កាត់រកាខ្ពស់ផងដែរ ។ គម្រោង មានគោលបំណង គាំទ្រដល់ប្រជាពលរដ្ឋក្នុងការបង្កើនសមត្ថភាពរបស់ពួកគេ ទទួលបាននូវកញ្ចប់ព័ត៌មាន និងពង្រឹងបណ្ដាញសម្រាប់ប្រមូលសកម្មភាព ជួយគាំទ្រពួកគេក្នុងកសាងតម្រូវការសាធារណៈ និងបង្កើតដំណោះស្រាយដើម្បីលើកយកបញ្ហាអាទិភាពរបស់សហគមន៍។ អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ បានចូលរួមជាមួយបុគ្គលិកគម្រោង ធ្វើការសម្របសម្រួលកិច្ចប្រជុំផ្សព្វផ្សាយ កញ្ចប់ព័ត៌មានសម្រាប់ពលរដ្ឋ កិច្ចប្រជុំណែនាំទូទាំងសង្កាត់ កិច្ចប្រជុំបង្កើតចក្ខុវិស័យរួម កិច្ចប្រជុំដាក់ពិន្ទុ ដោយខ្លួនឯង កិច្ចប្រជុំដាក់ពិន្ទុដោយប្រជាពលរដ្ឋ កិច្ចប្រជុំរួមរវាងពលរដ្ឋ និងអ្នកផ្ដល់សេវា (ក្រុមប្រឹក្សាសង្កាត់ បុគ្គលិកមណ្ឌលសុខភាព លោកគ្រូ អ្នកគ្រូបង្រៀនសាលាបឋមសិក្សា) ។ តាមរយៈដំណើរការនេះ ប្រជាពលរដ្ឋមានឱកាសដាក់ពិន្ទុអ្នកផ្ដល់សេវា តាមស្តង់ដារការងារ ។ លើសពីនេះ បុគ្គលិកគម្រោង បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយពីការអនុវត្តក្របខណ្ឌគណនេយ្យភាពសង្គមលើការផ្តល់សេវារដ្ឋបាលក្រុង តាខ្មៅ កាលពីចុងខែមិនា ឆ្នាំ២០២៣ ហើយក៏បានចាប់ផ្ដើមអនុវត្តគណនេយ្យភាពសង្គមលើសេវារដ្ឋបាលក្រុងតាខ្មៅ។

លោក **ឈឿង ឆូ** ចៅសង្កាត់រកាខ្ពស់ បានចូលរួមសកម្មភាពមួយចំនួនរបស់គម្រោង។ បើទោះបីជាគាត់អវត្តមានខ្លះនៅក្នុងសកម្មភាពនានារបស់គម្រោងក្តី ក៏គាត់បានផ្តល់សិទ្ធិជូនមន្ត្រីបង្គោលគណនេយ្យភាពសង្គម និងក្រុមប្រឹក្សាសង្កាត់ចូល

រួមជាមួយគម្រោងផងដែរ។ មានចំនុចជាវិជ្ជមានមួយចំនួន គួរឱ្យកត់សម្គាល់ដូចជាៈ ផ្ទាំងកញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ ព័ត៌មានថវិកាសង្កាត់ លទ្ធផលផែនការសកម្មភាពរួមស្តីពីគណនេយ្យភាពសង្គមឆ្នាំ២០២២ បានបិទផ្សាយនៅលើក្តារខៀនព័ត៌មាននៅយន្តការច្រកចេញចូលតែមួយរបស់សង្កាត់។ លទ្ធផលនៃការដាក់ពិន្ទុ ដោយប្រជាពលរដ្ឋ និងអ្នកផ្តល់សេវាបានផ្សព្វផ្សាយ ដូច្នេះក្រុមប្រឹក្សាសង្កាត់ បានដឹងពីចំនុចខ្លាំង និងចំនុចខ្វះខាតរបស់គេ ។ សកម្មភាពដែលបានស្នើឡើងបានដោះស្រាយជាបន្តបន្ទាប់ តាមស្តង់ដារ និងបានផ្សព្វផ្សាយជូនគណៈកម្មាធិការផែនការសកម្មភាពរួមស្តីពីគណនេយ្យភាពសង្គម។



លោកស្រី **ឌុក ស្រីពៅ** មន្ត្រីបង្គោលគណនេយ្យភាពសង្គម បានធ្វើការយ៉ាងជិតស្និតជាមួយក្រុមប្រឹក្សា សង្កាត់ សប្បុរសជន អង្គការមិនមែនរដ្ឋាភិបាល និងមន្ត្រីក្រុងតាខ្មៅ ដើម្បីដោះស្រាយបញ្ហាសកម្មភាពអាទិភាពមួយចំនួន។ អ្នកផ្តល់សេវាទាំងអស់ ក៏បានបញ្ចូលសកម្មភាពទាំងអស់ ទៅក្នុងផែនការសកម្មភាពរួមស្តីពីគណនេយ្យភាពសង្គម។ លោកស្រី ឌុក ស្រីពៅ បានផ្សព្វផ្សាយសកម្មភាពដែលបានស្នើឡើងជាមួយប្រជាពលរដ្ឋសហគមន៍ និងអ្នកពាក់ព័ន្ធផ្សេងៗ។

នៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២២ ផែនការ សកម្មភាពរួមស្តីពីគណនេយ្យភាពសង្គមបានអនុវត្តទៅតាមផែនការ។ ជាលទ្ធផល សកម្មភាពចំនួន២២ ក្នុងចំណោម៣៧ បានអនុវត្ត។ ក្នុងនោះ មានសកម្មភាព០២ ដែលមានការគាំទ្រពីខាងក្រៅបានអនុវត្ត ដូចជា បង្គន់អនាម័យចំនួន០២បន្ទប់បានសាងសង់រួច និងបានបែងចែក ប្រុស ស្រី នៅដើមឆ្នាំ២០២៣ ដោយបានចំណាយថវិកាសង្កាត់ចំនួន ១.៥០០ដុល្លារអាមេរិក ។ លើសពីនេះ ក្រុមគ្រួសារក្រីក្រចំនួន៦៥០ គ្រួសារព្រមទាំង គ្រួសារមនុស្សចាស់ បានទទួលថវិកាសេវាសង្គមចំនួន ១៨លានរៀល ពីរាជរដ្ឋាភិបាលកម្ពុជា។ ក្តារខៀនព័ត៌មានថ្មីមួយបានផលិតដោយចំណាយថវិកា២៥០ដុល្លារអាមេរិក មានបិទផ្ទាំងកញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ ព័ត៌មានស្តីពីផែនការសកម្មភាពរួមស្តីពីគណនេយ្យភាពសង្គម និងថវិកាចំណូលចំណាយរបស់សង្កាត់ ។ បន្ថែមពីនេះទៀត លេខទូរសព្ទទំនាក់ទំនងរបស់ក្រុមប្រឹក្សាសង្កាត់ បានបិទនៅលើជញ្ជាំងសង្កាត់ ដោយបានចំណាយថវិកាចំនួន ៤ម៉ឺនរៀល។ ជម្រាលសម្រាប់ជនមានពិការភាពបានសាងសង់ បរិស្ថានសង្កាត់ត្រូវបានកែលម្អ និងរៀបចំយ៉ាងស្អាត ព្រមទាំងមានការចុះត្រួតពិនិត្យ ជាទៀងទាត់ពីសន្តិសុខភូមិ។ ម៉្យាងវិញទៀត ប័ណ្ណ សមធម៌ សម្រាប់គ្រួសារក្រីក្រត្រូវបានផ្តល់ជូន យន្តការច្រកចេញចូលតែមួយត្រូវបានរៀបចំឡើង តំណាងប្រជាពលរដ្ឋត្រូវបានអញ្ជើញចូលរួមកិច្ចប្រជុំប្រចាំខែរបស់សង្កាត់។ លើសពីនេះទៀត សង្កាត់បានរៀបចំប្រជុំយ៉ាងទៀងទាត់លើការពង្រឹងវិន័យផ្ទៃក្នុង ពេលវេលាបំពេញការងារ និងពន្លឿនក្នុងការផ្តល់សេវាសាធារណៈ ។ ជាចុងក្រោយ សាលាបឋមសិក្សាចំនួន០៣ របស់សង្កាត់បានចូលរួមសកម្មភាពជាមួយគម្រោងយ៉ាងសកម្ម ហើយភាគច្រើននៃសកម្មភាពនៃផែនការសកម្មភាពរួមគណនេយ្យភាពសង្គមដែលបានស្នើឡើងត្រូវបានអនុវត្ត។

ការផ្សព្វផ្សាយកញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ កិច្ចប្រជុំណែនាំទូទាំងសង្កាត់ កិច្ចប្រជុំបង្កើតចក្ខុវិស័យរួម កិច្ចប្រជុំដាក់ពិន្ទុដោយប្រជាពលរដ្ឋ និងអ្នកផ្តល់សេវា បានជួយលោក **ឈឿង ឆូ** បង្កើនទូវការគ្រប់គ្រងរបស់គាត់ ជំនាញភាពជាអ្នកដឹកនាំ និងការទំនាក់ទំនងជាមួយប្រជាពលរដ្ឋ។ ដំណើរការនេះ បានជួយជួយធ្វើឱ្យប្រសើរឡើងនូវឥរិយាបទបំពេញការងាររបស់ក្រុមប្រឹក្សាសង្កាត់។ បច្ចុប្បន្នប្រជាពលរដ្ឋ ពេញចិត្ត ជាមួយនឹងសេវាសង្កាត់ដែលបានផ្តល់ជូនប្រជាពលរដ្ឋ។ អ្នកស្រី **រឿន ចិន** អាយុ៥០ឆ្នាំ ជាប្រជាពលរដ្ឋ រស់នៅភូមិព្រៃកថ្មី សង្កាត់រកាខ្ពស់បានលើកឡើងថា “ខ្ញុំសប្បាយចិត្តយ៉ាងខ្លាំង ដែលលោកចៅសង្កាត់ បានធ្វើការយ៉ាងលំបាក ក្នុងការជួយបង្កើនគុណភាពសេវាសង្កាត់ ការគ្រប់គ្រង និងធ្វើឱ្យបរិស្ថានសង្កាត់បានស្អាត។

លោក **ឈឿង ឆូ** និងក្រុមប្រឹក្សាសង្កាត់ មានផែនការបន្តធ្វើការជាមួយសមាជិកគណៈកម្មាធិការផែនការ សកម្មភាពរួមស្តីពីគណនេយ្យភាពសង្គម ដើម្បីលើកឡើងផែនការថវិកាបន្ថែមទៀតសម្រាប់ដោះស្រាយបញ្ហាសកម្មភាពដែលនៅសេសសល់។

## គម្រោងទី១៣ សំឡេង និងសកម្មភាពរបស់មេដឹកនាំ និងសហគ្រិនស្ត្រីវ័យក្មេង

**គោលបំណង៖** ការពង្រឹងសមត្ថភាព និងបង្កើតបរិយាកាសអំណោយផលសម្រាប់យុវជន និងអ្នកដឹកនាំ វ័យក្មេងដែលកំពុងលេចធ្លោ និងសហគ្រិនខ្នាតតូចស្ត្រីដើម្បីអនុញ្ញាតឱ្យពួកគេចូលរួមក្នុងភាពជាសហគ្រិន និងសកម្មភាពតស៊ូមតិទាក់ទងនឹងអាជីវកម្ម និងការសន្ទនាជាមួយអាជ្ញាធរ។ នេះនឹងរួមចំណែកដល់ការធ្វើឱ្យប្រសើរឡើងនូវឱកាសស្មើគ្នា និងការពង្រឹងសិទ្ធិសេដ្ឋកិច្ចសង្គមរបស់ពួកគេ។

**មូលនិធិសម្រាប់គម្រោង៖** ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់កិច្ចអភិវឌ្ឍអន្តរជាតិ (USAID Cambodia) តាមរយៈផេកកម្ពុជា។

**ដៃគូអនុវត្ត៖** សមាគមន៍ប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ (IDEA) អង្គការសម្ព័ន្ធភាពដៃគូដើម្បីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ (CPDD)

**តំបន់គោលដៅ៖** រាជធានីភ្នំពេញ ខេត្តសៀមរាប ខេត្តបាត់ដំបង និងខេត្តព្រះសីហនុ។

***គម្រោងទី១៣៖*** ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់កិច្ចអភិវឌ្ឍអន្តរជាតិទទួលបានមូលនិធិតាមរយៈផេក (API CPDD និង IDEA) សំឡេង និងសកម្មភាពរបស់មេដឹកនាំ និងសហគ្រិនស្ត្រីវ័យក្មេងបានសម្រេចគោលដៅ របស់ខ្លួនសម្រាប់ឆ្នាំ២០១៩ - ២០២៣ ដោយជោគជ័យ។ អង្គការ API ទទួលបានរង្វាន់ទី០១ នៅក្នុង៣ន រង្វាន់ដៃគូដែលដំណើរការល្អបំផុតក្នុងចំណោមដៃគូចំនួន ៤២ ពី USAID/Pact ស្តីពីការផ្លាស់ប្តូរដ៏សំខាន់ បំផុតអំពីអង្គការ API បានអនុវត្តគម្រោង WE ACT ដោយជោគជ័យ។

## គម្រោងទី១៤ ការលើកកម្ពស់សមត្ថភាព និងប្រតិបត្តិការស្ថាប័នរបស់សមាគមថ្នាក់ខេត្តនៃក្រុមប្រឹក្សាមូលដ្ឋាន

**គោលបំណង៖** ពង្រឹងសមត្ថភាពស្ថាប័ន និងប្រតិបត្តិការរបស់សមាគមក្រុមប្រឹក្សាមូលដ្ឋានខេត្ត (PALCs) និងសមាជិករបស់ពួកគេនៅក្នុងតំបន់គោលដៅ ដើម្បីរួមចំណែកលើកកម្ពស់គណនេយ្យភាព តម្លាភាព និងការឆ្លើយតបទៅនឹងតម្រូវការរបស់សមាជិកសភាជាពិសេសសហគមន៍ដែលងាយរងគ្រោះ។

**ការផ្តល់មូលនិធិ៖** 445.031 អឺរ៉ូ នៃចំនួនសរុប 977.938 អឺរ៉ូ ត្រូវបានផ្តល់មូលនិធិ ដោយសហភាពអឺរ៉ុប ជំនួយព្រះវិហារដាណឺម៉ាក (DCA) និងអង្គការប្រ៊េដ ហ្វ័រ ឌឺ វើល (BfdW) បានផ្តល់ការគាំទ្រក្នុងគម្រោងនេះដូចគ្នា។

**ដៃគូអនុវត្ត៖** Aide et Action (AeA)និងសមាគមក្រុមប្រឹក្សាមូលដ្ឋានខេត្តពោធិ៍សាត់។

**តំបន់គោលដៅ៖** ខេត្តគោលដៅចំនួនប្រាំមួយគឺ កំពង់ស្ពឺ កណ្តាល កែប កំពង់ធំ ពោធិ៍សាត់ និងខេត្តបន្ទាយមានជ័យ។

គម្រោងនេះត្រូវបានបញ្ចប់ដោយជោគជ័យក្នុងឆ្នាំ២០២១ និងការទូទាត់ចុងក្រោយនៅឆ្នាំ២០២២។ ការចំណាយដោយប្រយោលបានចែកចាយដល់ភាគីទាំងអស់បន្ទាប់ពីកិច្ចប្រជុំផ្ទៃក្នុងជាច្រើន និងការបកស្រាយចុងក្រោយជាមួយសហភាពអឺរ៉ុប ក្នុងឆ្នាំ២០២៣។

## លទ្ធផលទី៣ ធ្វើឱ្យប្រសើរឡើងនូវការប្រើប្រាស់ និងការបង្ហាញព័ត៌មានសាធារណៈអំពីបញ្ហាសំខាន់ៗ។

## គម្រោងទី១៥ គម្រោងសិទ្ធិទទួលព័ត៌មានសម្រាប់ទាំងអស់គ្នា ការលើកកម្ពស់ លទ្ធភាពទទួលបានព័ត៌មាន នៅកម្ពុជា

**គោលបំណងនៃគម្រោង៖** គោលដៅរួមនៃគម្រោងគឺដើម្បីបង្កើនលទ្ធភាពទទួលបានព័ត៌មានឯករាជ្យ ផ្អែកលើភស្តុតាង និងលើកកម្ពស់សេរីភាពនៃការបញ្ចេញមតិនៅកម្ពុជា។

**ដៃគូអនុវត្ត៖** ក្រសួងការបរទេសសហរដ្ឋអាមេរិក (USDOS) CFDA លេខ១៩,៣៤៥ តាមរយៈគម្រោងរួមជាមួយនឹងវិទ្យាស្ថានគ្រប់គ្រងបូព៌ាបញ្ចឹម (EWMI)។

**ថវិកា៖** ៥៦៤.៩០២,៤៩ ដុល្លារសហរដ្ឋអាមេរិក

**តំបន់គោលដៅ៖** ស្រុកគោលដៅចំនួនបីស្រុក៖ ស្រុកភ្នំក្រវាញ ក្នុងខេត្តពោធិ៍សាត់ ស្រុកប្រាសាទបល្ល័ង្គ ក្នុងខេត្តកំពង់ធំ និងស្រុកចិត្របុរី ក្នុងខេត្តក្រចេះ។

### លទ្ធផល

- ប្រជាជនកម្ពុជាដែលងាយរងគ្រោះបានទទួល និងប្រើប្រាស់ព័ត៌មានចាំបាច់សម្រាប់ការចូលរួមពេញលេញក្នុងសង្គមកម្ពុជា។
- គម្រោងនេះត្រូវបានបញ្ចប់ដោយជោគជ័យ និងសម្រេចបាននូវគោលបំណងដែលបានគ្រោងទុក។
- គម្រោងនេះបានផ្តល់បណ្តុះបណ្តាល និងគាំទ្រដល់មេដឹកនាំស្ត្រីជនជាតិដើមភាគតិចកម្ពុជាដែល ងាយរងគ្រោះចំនួន ៩០នាក់ ដើម្បីទទួលបាន និងប្រើប្រាស់ព័ត៌មានចាំបាច់សម្រាប់ការចូលរួម ពេញលេញរបស់ពួកគេនៅក្នុងសង្គមកម្ពុជា។ នៅចុងបញ្ចប់នៃគម្រោងមេដឹកនាំស្ត្រីជនជាតិដើម ភាគតិចកម្ពុជាដែលងាយរងគ្រោះភាគច្រើនបានអនុវត្តចំណេះដឹងអំពីផែនការវិនិយោគឃុំ និងស្រុក (CIP/DIP) និងការប្រជុំសាធារណៈនៅតាមមូលដ្ឋានជាច្រើនដងក្នុងរយៈពេល ៣ឆ្នាំ។
- នៅក្នុងសហគមន៍មូលដ្ឋានអ្នកដឹកនាំស្ត្រី (CBO) ដែលបានទទួលការបណ្តុះបណ្តាលបានរៀន ប្រធានបទបណ្តុះបណ្តាលចំនួន ១៩ និងបានអនុវត្តប្រធានបទ ១១/១៩ (៥៧,៩០%) នៅក្នុងការងារ សហគមន៍របស់ពួកគេដូចដែលបានរាយការណ៍ដោយស្ត្រីជនជាតិដើមភាគតិច ដែលបានចូលរួមក្នុងសិក្ខាសាលាឆ្លុះបញ្ចាំងគម្រោងឆ្នាំ២០២៣។
- ការផ្លាស់ប្តូរសមត្ថភាពសហគមន៍៖ លើសពីនេះជនជាតិដើមភាគតិចបានបញ្ជាក់នៅក្នុងសិក្ខាសាលា ថា ការផ្លាស់ប្តូរជាច្រើនបានមកពីការបណ្តុះបណ្តាលគម្រោង។ ការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់ ពាក់ព័ន្ធនឹង ទិដ្ឋភាពជាច្រើននៃជីវិត រួមទាំងការកែលម្អសហគមន៍ក្នុងចំណេះដឹងទូទៅរបស់ពួកគេ និងភាពក្លាហាន ក្នុងការដោះស្រាយជាមួយអាជ្ញាធរដើម្បីការពារផលប្រយោជន៍របស់ពួកគេ ដោះស្រាយបញ្ហា កង្វល់ និងតម្រូវការរបស់ពួកគេ ទទួលស្គាល់ព័ត៌មានពិត ឬក្លែងក្លាយ ការយល់ដឹងអំពីសិទ្ធិទទួលព័ត៌មាន ការយល់ដឹងអំពីដីធ្លី។ ច្បាប់ និងបទប្បញ្ញត្តិ ហើយសរសេរសំណើ សុំព័ត៌មាន និងសុំអន្តរាគមន៍ ដើម្បីដោះស្រាយបញ្ហាសហគមន៍របស់ពួកគេ។ នេះបង្ហាញពីការអភិវឌ្ឍដ៏ល្អនៃការយល់ដឹង និងការអប់រំខ្លួនឯង ដែលជាកត្តាសំខាន់មួយនៅក្នុងជនជាតិដើមភាគតិចដើម្បីរក្សាតុល្យភាពកម្រិតទាបនៃការអប់រំផ្លូវការ។ “ការទទួលបានព័ត៌មានមានសារៈសំខាន់ខ្លាំងណាស់ចំពោះរបបប្រជាធិបតេយ្យ និងការបើកចំហរដែលជំរុញឱ្យមានការចូលរួមជាសាធារណៈការពង្រឹងសិទ្ធិអំណាចរបស់ប្រជាពលរដ្ឋ និងតម្លាភាព និងគណនេយ្យភាពរបស់រដ្ឋាភិបាល”។
- មេដឹកនាំស្ត្រីជនជាតិដើមភាគតិចកម្ពុជាដែលងាយរងគ្រោះចំនួន ៩០នាក់ បានធ្វើផែនការ តស៊ូមតិចំនួន 33ករណី ដោយជោគជ័យជាមួយមន្ត្រីថ្នាក់ឃុំ ស្រុករបស់ពួកគេ ដែលផ្តល់ផល ប្រយោជនដល់សមាជិកសហគមន៍ចំនួន 5.903។ ពួកគេបានចូលរួមយ៉ាងសកម្មក្នុងការចូលរួម ប្រជុំថ្នាក់ឃុំ ស្រុកប្រចាំខែចំនួន ៦៥កិច្ចប្រជុំ។




**ជាលទ្ធផលសំណើចំនួន ១១៦ ត្រូវបានធ្វើឡើងដែលក្នុងនោះ ៣៤ ជាសំណើសុំព័ត៌មាន និង៨២ ជាសំណើទាក់ទងនឹងបញ្ហា និងតម្រូវការ៖**

- ក្នុងចំណោមសំណើសុំព័ត៌មានចំនួន ៣៤ មាន ៨ បានទទួលការឆ្លើយតបពេញលេញ ១២ ត្រូវបានដោះ ស្រាយដោយបានខ្លះ ឬកំពុងដំណើរការ និង ១៤ មិនបានទទួលការឆ្លើយតប ណាមួយឡើយ។
- ក្នុងចំណោម ៨២ តម្រូវការវត្ថុនៃសំណើ ២៥ មិនត្រូវបានដោះស្រាយ ៣២ ត្រូវបានដោះស្រាយ មួយបានខ្លះ ឬកំពុងដោះស្រាយ (ជួសជុលផ្លូវ មុខរបរ ការពារប្រពៃណីជនជាតិដើមភាគតិច ការការពារព្រៃឈើ កង្វះថវិកាក្នុងការចុះល្បាត និងសាលាមត្តេយ្យសិក្សា) និង ២៥ បានស្នើសុំដោះស្រាយទាំងស្រុង រួមទាំងព័ត៌មានថវិកា ហេដ្ឋារចនាសម្ព័ន្ធ ជលផល ភ្លើងផ្លូវ ក្លោងទ្វារ ស្ពានផ្តល់អត្ថប្រយោជន៍ដល់សមាជិកសហគមន៍ (CBOs) ចំនួន ៥៩០៣នាក់។

**បង្កើនការយល់ដឹងអំពីសារៈសំខាន់នៃក្របខ័ណ្ឌច្បាប់ដ៏មានប្រសិទ្ធភាពដែលផ្តល់លទ្ធភាពទទួលបានព័ត៌មានសម្រាប់ប្រជាជនកម្ពុជា៖**

- តួអង្គការសង្គមស៊ីវិលចំនួន ៥២ អ្នកតំណាងប្រព័ន្ធផ្សព្វផ្សាយចំនួន ០៤ តំណាងវិស័យឯកជន និងអ្នកទទួលផលគម្រោងដែលចូលរួមក្នុងកិច្ចប្រជុំប្រចាំត្រីមាសដើម្បីពិភាក្សាអំពីសិទ្ធិទទួលបាន និងប្រធានបទទាក់ទងនឹងព័ត៌មាន។
- កសាងការគាំទ្រសហគមន៍សម្រាប់ការទទួលបានគោលការណ៍ព័ត៌មាន។ សរុប ៣០៩នាក់ (តំណាងរដ្ឋាភិបាល ១០៥នាក់ អង្គការសង្គមស៊ីវិល ១៨នាក់ និងស្ត្រីជនជាតិដើមភាគតិច ១៨៦នាក់) ដែលចូលរួមក្នុងកិច្ចប្រជុំស្តីពីស្តង់ដារអន្តរជាតិសម្រាប់ច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន។
- អ្នកចូលរួមសហគមន៍បានបញ្ជាក់ថា ៩៧% (១២៦ ក្នុងចំណោម ១៣០) បានទទួលការឆ្លើយតបជាវិជ្ជមានពីរដ្ឋាភិបាលចំពោះសំណើសុំព័ត៌មាន។
- អ្នកការពារសិទ្ធិមនុស្សចំនួន ១០៤នាក់ ត្រូវបានបណ្តុះបណ្តាលក្នុងស្ថាប័នរបស់ពួកគេបានគាំទ្រក្នុងការចូលរួមក្នុងសិក្ខាសាលាព័ត៌មាន។

## សកម្មភាព

- សមត្ថភាពស្ត្រីជនជាតិដើមភាគតិច៖ សរុបសកម្មភាព ១០០% ត្រូវបានបញ្ចប់៖ វគ្គបណ្តុះបណ្តាលចំនួន ៩ បានធ្វើឡើងដោយមានស្ត្រីជនជាតិដើមភាគតិចចំនួន ៣៦៥ នាក់ ដែលមានស្ត្រីជនជាតិដើមភាគតិច ៩០នាក់ ដែលមិនស្គួនគ្នា។ ប្រធានបទសំខាន់ៗមាន៤៖ សិទ្ធិទទួលព័ត៌មាន (ច្បាប់ A2I) អក្ខរកម្មថវិកា ការតស៊ូមតិនៅមូលដ្ឋាន និងការតស៊ូមតិលើA2I។ ព័ត៌មានលម្អិតខាងក្រោមនេះ៖

| ខេត្តគោលដៅ | ការធ្វើតេស្តជាមុន | ការធ្វើតេស្តក្រោយ | ការកើនឡើង | ស្ត្រីជនជាតិដើមភាគតិចចូលរួម |
|---|---|---|---|---|
| **សិទ្ធិទទួលព័ត៌មាន** | | | | ៩០ |
| ក្រចេះ កំពង់ធំ និង ពោធិ៍សាត់ | ២៨,៨៧% | ៩១,៥១% | ៦២,៦៤% | |
| **ចំណេះដឹងផ្នែកថវិកា** | | | | ៨៦ |
| ក្រចេះ កំពង់ធំ និង ពោធិ៍សាត់ | ៥៩,៤២% | ៩០,១១% | ៣០,៦៩% | |
| **ការតស៊ូមតិលើសិទ្ធិទទួលព័ត៌មាន** | | | | ១០៤ |
| ក្រចេះ កំពង់ធំ និង ពោធិ៍សាត់ | ៦៦,៩៦% | ៨៥,៨% | ១៨,៨៤% | |
| **ការតស៊ូមតិមូលដ្ឋាន** | | | | ៨៥ |
| ក្រចេះ កំពង់ធំ និង ពោធិ៍សាត់ | ៨៣,៣១% | ៨៧,៣១% | ៤% | |

- ផែនការតស៊ូមតិសរុបចំនួន ៣៣ ត្រូវបានបង្កើតឡើងលើប្រធានបទដូចជា៖ ជម្លោះដីធ្លីរវាងសមាជិកសហគមន៍ និងអ្នកមានអំណាចក្នុងមូលដ្ឋាន។ ការកាប់បំផ្លាញព្រៃឈើក្នុងសហគមន៍ និងការបាត់បង់ សត្វព្រៃ។ ការនេសាទខុសច្បាប់នៅក្នុងបឹងអភិរក្ស ការកើនឡើងនៃដីល្បាប់ដែលបណ្ដាលមកពីទំនប់ អាកប្បកិរិយាគ្មានវិជ្ជាជីវៈរបស់មន្ត្រីក្នុងការផ្ដល់សេវាសាធារណៈ អំពាវនាវឱ្យមានការអភិរក្ស និងជួសជុលប្រាសាទបុរាណ និងស្ពាន។ ការបាត់បង់វប្បធម៌ជនជាតិដើមភាគតិច អំពើហិង្សា ក្នុងគ្រួសារ កង្វះអណ្ដូងទឹកនិងទឹកស្អាត កង្វះការផ្គត់ផ្គង់ទឹក បច្ចេកទេសដាំដុះ និងទីផ្សារកសិផល។ កង្វះបង្គន់អនាម័យ និងបរិស្ថានកខ្វក់នៅតាមដងផ្លូវដោយសារការចោលសំរាមមិនត្រឹមត្រូវ។ កង្វះ អគារសាលាមត្តេយ្យសិក្សា និងគ្រូបង្រៀន ជនមានពិការភាពខ្វះជំនាញវិជ្ជាជីវៈ និងដើមទុន សម្រាប់អាជីវកម្មចាប់ផ្ដើម។
- អ្នកចូលរួមសរុបចំនួន ៩០នាក់ (១០០%) បានដំឡើងកម្មវិធីតេលេក្រាម (Telegram) និងស៊ិកណល (Signal) ដោយជោគជ័យនៅក្នុងទូរសព្ទដៃរបស់ពួកគេ។ ស្ត្រីជនជាតិដើមភាគតិច ៦៣នាក់ ក្នុងចំណោម ៩០នាក់ បានបង្ហោះអត្ថបទអំពីបញ្ហា ឬកង្វល់របស់ពួកគេនៅលើកម្មវិធីផ្ញើសារ ឬប្រព័ន្ធផ្សព្វផ្សាយសង្គម និងចែករំលែកព័ត៌មានជាមួយសមាជិកផ្សេងទៀត។
- អត្ថបទសរុបចំនួន ៥៩៥ ត្រូវបានបង្ហោះដោយស្ត្រីជនជាតិដើមភាគតិចដែលបានទទួលការបណ្ដុះ បណ្ដាលអំពីសកម្មភាពរបស់ពួកគេនៅក្នុងសហគមន៍ដូចជាការចូលរួមក្នុងកិច្ចប្រជុំក្រុមប្រឹក្សាឃុំ និងស្រុក ការដើរល្បាតសហគមន៍ យុទ្ធនាការចាក់ថ្នាំបង្ការជំងឺកូវីដ-១៩ និងការជួបជាមួយក្រុមការងារ គម្រោងរបស់យើងក៏ដូចជាការចូលរួមសកម្មភាពរបស់ពួកគេផងដែរ។ នៅក្នុងសកម្មភាពរបស់អង្គការ ក្រៅរដ្ឋាភិបាលផ្សេងទៀតលើការអប់រំសុខភាព ការការពារបរិស្ថាន អនាម័យ បញ្ហាប្រឈមក្នុងសហគមន៍ វប្បធម៌ និងប្រពៃណីរបស់ជនជាតិដើមភាគតិច និងការបណ្ដុះបណ្ដាល សមភាពយេនឌ័រ។ ជាលទ្ធផលមានប្រតិកម្មចំនួន ៥.៩៥៨ មតិចំនួន ៩៥១ និងការចែករំលែកចំនួន ៧០។
- គាំទ្រការតស៊ូមតិ និងការចូលរួមសហគមន៍ដោយស្ត្រីជនជាតិដើមភាគតិច។ សមាជិកសហគមន៍ (CBO) សរុបចំនួន ៦៣៥នាក់ បានចូលរួមកិច្ចប្រជុំប្រចាំខែរបស់ឃុំ និងស្រុក ដែលក្នុងនោះ មានតំណាងសហគមន៍ចំនួន ២៣៧នាក់។
- ករណីសិក្សាចំនួន ២១ ត្រូវបានប្រមូលចងក្រងដោយបង្ហាញពីការប្រើប្រាស់មេរៀនដែលបាន រៀននៅក្នុងគម្រោង និងលទ្ធផលរបស់គម្រោង។
- វេទិកាសាធារណៈសរុបចំនួន ១៨ (១០០%) ត្រូវបានបញ្ចប់ដោយមានអ្នកចូលរួមចំនួន ១.៥០៣នាក់ (ស្រី ៨២៧នាក់)។ អ្នកចូលរួមជាស្ត្រីជនជាតិដើមភាគតិច សមាជិកសហគមន៍ (CBOs) ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាស្រុក និងអភិបាលក្រុង ស្រុក និងមន្ត្រីមកពីការិយាល័យពាក់ព័ន្ធក្រុង ស្រុក និងខេត្ត។




ជាលទ្ធផលសំណួរសរុបចំនួន ៩៤ ក្នុងចំណោម ១១៦ ត្រូវបានឆ្លើយ ហើយមានការប្តេជ្ញាចិត្តក្នុងការ ស្វែងរកដំណោះស្រាយ។ ក្នុងចំណោម សំណួរទាំង ៩៤ នោះមានសំណួរ ជាច្រើនទាក់ទងនឹងចំណូល និងចំណាយ ថវិកាឃុំ សង្កាត់ ថវិកាគាំពារសង្គម ស្នើសុំថវិកាសម្រាប់ដើរល្បាតសហគមន៍ ការកាប់ បំផ្លាញព្រៃឈើ និងជំនួយថវិកាមួយចំនួនក្នុងក្រុម សន្សំប្រាក់ ព្រំប្រទល់ព្រៃឈើ បទល្មើសទន្រ្ទាន សហគមន៍ដី និងព្រៃឈើ បញ្ហាថវិកា សេវាសាធារណៈ និងអគារសិក្សា។ ក្នុងចំណោម សំណួរទាំងនោះ 22 មិនបានទទួលការឆ្លើយតប ឬមិនត្រូវបានឆ្លើយតបភ្លាមៗទេ ហើយ ត្រូវការការពិភាក្សាបន្ថែម។

**បានបង្កើនការយល់ដឹងអំពីសារៈសំខាន់នៃក្របខ័ណ្ឌច្បាប់ដ៏មានប្រសិទ្ធភាពដែលផ្តល់នូវការទទួលបានព័ត៌មានសម្រាប់ប្រជាជនកម្ពុជា ។**

- យ៉ាងហោចណាស់ 97% (126 នៃ 130) ឆ្លើយតបទៅនឹងសំណើសុំព័ត៌មាន។

| សំណើ | ការប្រជុំឃុំ សង្កាត់ | វេទិកាសាធារណៈ | ការប្រជុំ ពហុភាគី | សរុប | បានឆ្លើយតប | មិនបានឆ្លើយតប |
|---|---|---|---|---|---|---|
| ស្នើសុំតម្រូវការ បញ្ហា | ៨២ | ១១៦ | ១២ | ១៦២ | ១២៦ | ៣៦ |
| ស្នើសុំព័ត៌មាន | ៣៤ | | | ៨២ | ៥៧ | ២៥ |

- អង្គការចំនួន ៩៧ បានចូលរួមក្នុងសិក្ខាសាលាជាតិស្តីពីសិទ្ធិទទួលបានព័ត៌មាន។
- បានរៀបចំសិក្ខាសាលាថ្នាក់ជាតិចំនួន ០៤ ប្រចាំឆ្នាំ ដែលមានអ្នកចូលរួមចំនួន ៧០៦នាក់ ស្រី ៣២៦ នាក់។
- បានជំរុញសកម្មភាពវីដេអូ A2I នៅលើ Facebook អំពីធាតុចូលរួមរបស់អង្គការសង្គមស៊ីវិល ចំពោះច្បាប់សិទ្ធិទទួលព័ត៌មាន។
- សហការរៀបចំការប្រកួត Vlog យុវជនស្តីពីសារៈសំខាន់នៃការទទួលព័ត៌មានក្នុងការអភិវឌ្ឍ អាជីវកម្ម និងសេដ្ឋកិច្ច។
- សហការរៀបចំរាំកម្សាន្ត A2I Fun Dance ជាមួយអង្គការសង្គមស៊ីវិល និងបុគ្គលិកប្រព័ន្ធ ផ្សព្វផ្សាយ អ្នកសារព័ត៌មាន យុវជន និងសាធារណជនដើម្បីរួមគ្នាអបអរសាទរទិវា សិទ្ធិទទួលព័ត៌មាន (ថ្ងៃទី ២៨ ខែកញ្ញា ឆ្នាំ២០២៣)។ សេចក្តីប្រកាសព័ត៌មាន មនុស្សប្រហែល ៣៥,៥០០ បានមើលព្រឹត្តិការណ៍នេះផ្ទាល់ https://fb.watch/nCij8iqH4J/?mibextid=cr9u03
- ការប្រជុំប្រចាំខែរបស់សមាជិកក្រុមការងារសិទ្ធិទទួលព័ត៌មាន (A2IWG) ត្រូវបានធ្វើឡើងចំនួន ១៧ ដង អ្នកចូលរួមចំនួន ២១នាក់ រួមទាំងតំណាងស្ត្រីជនជាតិដើមភាគតិចចំនួន ១៤ នាក់ បានចូលរួម ដោយផ្ទាល់ និងតាមអ៊ីនធឺណិត។ ក្នុងអំឡុងពេលកិច្ចប្រជុំយើងបានពិភាក្សា និងធ្វើបច្ចុប្បន្នភាព អ្នកចូលរួមអំពីវឌ្ឍនភាព និងបញ្ហាប្រឈមនានាទាក់ទងនឹងការទទួលបាន ព័ត៌មាន និងផ្លាស់ប្តូរព័ត៌មានថ្មីៗអំពីសកម្មភាពរបស់សមាជិកនីមួយៗក្នុងកិច្ចខិតខំប្រឹងប្រែងរួមគ្នា ដើម្បីលើកកម្ពស់ការ ទទួលបានព័ត៌មានសម្រាប់ទាំងអស់គ្នា។ ការធ្វើបច្ចុប្បន្នភាពលើសេចក្តី ព្រាងច្បាប់ ស្តីពី សិទ្ធិទទួលព័ត៌មានបានចែករំលែកហើយកំណត់ចំណាំគោលគំនិតសម្រាប់សន្និសីទ ជាតិយុទ្ធនាការ ផែនការ និងយុទ្ធនាការប្រព័ន្ធផ្សព្វផ្សាយជាមួយក្រុមការងារសិទ្ធិទទួលព័ត៌មាន។
- លិខិតរបស់អង្គការសង្គមស៊ីវិលចំនួន ៦ ត្រូវបានទទួលដោយក្រសួងព័ត៌មាន និងរដ្ឋសភាដើម្បី នាំយកបញ្ហាសហគមន៍ទៅកាន់អ្នកបង្កើតគោលនយោបាយជាតិ។
- ក្នុងក្របខ័ណ្ឌ នៃយុទ្ធនាការតស៊ូមតិដើម្បីដាក់លិខិតទៅនាយករដ្ឋមន្ត្រី និងអ្នកធ្វើគោលនយោបាយ យើងបានសរសេរអត្ថបទសម្រាប់ប្រព័ន្ធផ្សព្វផ្សាយសង្គមវិទ្យុ និងព័ត៌មានអនឡាញ សម្រាប់ប្រព័ន្ធ ផ្សព្វផ្សាយល្បីៗដូចជា វិទ្យុវីអូអេ វិទ្យុវីអូឌី ខេមបូចាភ្នំពេញប៉ុស្តិ៍ ខ្មែរថាម វិទ្យុអាស៊ីសេរី ថ្មីថ្មី វិទ្យុបារាំង ខេមបូឌាដេលី អាដហុក វ៉ាយអូ និងផ្សេងៗទៀត។

- សមាជិក ក្រុមការងារសិទ្ធិទទួលព័ត៌មាន (A2IWG) បានចាប់ផ្តើមយុទ្ធនាការប្រព័ន្ធផ្សព្វផ្សាយ សង្គមដែលមានវីដេអូផលិតដោយខ្លួនឯងចំនួន 4មាតិកា Facebook រួមទាំងការផ្សាយបន្តផ្ទាល់ចំនួន 3 របស់សមាជិកនៅក្នុងកម្មវិធីជជែកតាមវិទ្យុ។ មាតិកា Facebook ជាច្រើន ដែលបានបង្ហោះជាផ្នែក នៃយុទ្ធនាការឈានដល់ចំនួនសរុប ២១.០៦៧ គណនី និងទទួលបាន ៧២៤ ប្រតិកម្ម។ ខ្លឹមសារ និងសារទាំងអស់នៅក្នុងយុទ្ធនាការប្រព័ន្ធផ្សព្វផ្សាយសង្គមផ្តោតលើសារៈសំខាន់នៃ A2I ការបង្ហាញជាសាធារណៈ និងការប្រារព្ធទិវាសិទ្ធិដើម្បីដឹង។
- តំណាងអង្គការមិនមែនរដ្ឋាភិបាលចំនួន ១២ បានដើរដាក់លិខិតរួមគ្នារបស់យើងទៅកាន់ ការិយាល័យនាយករដ្ឋមន្ត្រី។ ហើយបណ្តាញប្រព័ន្ធផ្សព្វផ្សាយចំនួន ១១ បានផលិតអត្ថបទនៅលើការ ដើរនេះសម្រាប់ព័ត៌មានប្រព័ន្ធផ្សព្វផ្សាយសង្គម ព័ត៌មានវិទ្យុ កម្មវិធីវិទ្យុ និងការផ្សាយផ្ទាល់លើ ហ្វេសប៊ុកដោយខេបូចា វិទ្យុវីអូឌី ស៊ីស៊ីអាយអ៊ឹម ភ្នំពេញប៉ុស្តិ៍ ខ្មែរថាមស៍ វិទ្យុវីអូអេ វិទ្យុអាស៊ីសេរី សារព័ត៌មានថ្មីថ្មី វិទ្យុបារាំង សារព័ត៌មានខេបូឌាដេលីអាដហុក និងវ៉ាយអូ។
- សេចក្តីថ្លែងការណ៍សរុបចំនួន 5 បានដាក់ទៅកាន់រដ្ឋាភិបាលជាពិសេសទៅក្រសួងព័ត៌មាន ត្រូវបាន រាយការណ៍ដោយប្រព័ន្ធផ្សព្វផ្សាយដើម្បីជំរុញឱ្យរដ្ឋាភិបាលអនុម័តច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន។ ជាលទ្ធផលនាយករដ្ឋមន្ត្រី បានប្តេជ្ញាអនុម័តច្បាប់ A2I នៅឆ្នាំ២០២៤ ឬឆ្នាំ២០២៥។ នៅខែវិច្ឆិកា ឆ្នាំ ២០២៣ តំណាងក្រសួងព័ត៌មាន បានឆ្លើយតបថា ក្រសួងនឹងព្យាយាមធ្វើការជាមួយក្រសួង ផ្សេងទៀត ជាពិសេសទីស្តីការគណៈរដ្ឋមន្ត្រី លើសេចក្តីព្រាងច្បាប់នេះ ដើម្បីពន្លឿនសេចក្តីព្រាងច្បាប់ស្តីពីសិទទួលព័ត៌មានទៅមុខឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន។
- របាយការណ៍ត្រួតពិនិត្យជាសកល (UPR) ស្តីពីបញ្ហាសិទ្ធិទទួលបានព័ត៌មាននៅកម្ពុជា ត្រូវបានដាក់ ជូនជាឌីជីថលទៅកាន់ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ។ របាយការណ៍ នៃការត្រួតពិនិត្យតាមកាលកំណត់ជាសកលត្រូវបានបង្ហាញដល់ដៃគូអភិវឌ្ឍន៍របស់ USAID EU ស្ថានទូតចក្រភពអង់គ្លេស UNOCHR EWMI FHI-360 GIZ ដោយវិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ (API) និងសមាជិកនៃក្រុមការងារទទួលបានព័ត៌មាន(A2IWG)។
- ព័ត៌មានសំខាន់ៗស្តីពីសម្បទានដីសេដ្ឋកិច្ច (ELC) និងការវាយតម្លៃផលប៉ះពាល់សង្គមបរិស្ថានរបស់ (ESIA) នៅតែមិនអាចទទួលបានពេញលេញ។ រដ្ឋាភិបាលក្នុងតំបន់មានអំណាចកំណត់ក្នុងការផលិត និងចែកចាយព័ត៌មានសំខាន់ៗស្តីពីសម្បទានដីសេដ្ឋកិច្ច (ELC) និងការវាយតម្លៃផលប៉ះពាល់សង្គម និងបរិស្ថាន (ESIA)។ អាជ្ញាធរឃុំ និងស្រុកមានការស្ទាក់ស្ទើរក្នុងការឆ្លើយតប និងចែករំលែកព័ត៌មានជាមួយសហគមន៍របស់ពួកគេ។
- ភាពស្មុគស្មាញនៃចំណេះដឹងផ្នែកថវិកាសាធារណៈ៖ ចំណេះដឹងផ្នែកថវិកាមានភាពស្មុគស្មាញ សម្រាប់ស្ត្រីជនជាតិដើមភាគតិចក្នុងការយល់ ហើយពួកគេមិនយល់ថាវាប៉ះពាល់ដោយផ្ទាល់ដល់ សេដ្ឋកិច្ចរបស់គ្រួសារនោះទេ។
- មន្ត្រីមូលដ្ឋានមានទំនួលខុសត្រូវ ប៉ុន្តែមិនត្រូវបានផ្តល់សិទ្ធិអំណាចពេញលេញនោះទេ៖ មានការបែងចែករវាងផលប្រយោជន៍នៅលើកការធ្វើវិមជ្ឈការរបស់រដ្ឋាភិបាលកម្ពុជាជាមួយ និងស្ថានភាពជាក់ ស្តែងនៃរចនាសម្ព័ន្ធរដ្ឋាភិបាលកណ្តាលពីកំពូលចុះមកដល់ថ្នាក់ក្រោមជាតិ។ មន្ត្រីមូលដ្ឋានគួរតែ ទទួលខុសត្រូវក្នុងសហគមន៍របស់ពួកគេ និងលើកទឹកចិត្តឱ្យបម្រើសហគមន៍កាន់តែច្រើន។

## មេរៀនដែលបានរៀន៖

- សិក្ខាសាលាពហុភាគីថ្នាក់ខេត្ត និងវេទិកាសាធារណៈរបស់ស្រុកបានផ្តល់កន្លែងបន្ថែមទៀតសម្រាប់ តំណាងសហគមន៍ យុវជន អង្គការសង្គមស៊ីវិល និងមន្ត្រីរដ្ឋាភិបាលថ្នាក់ក្រោមជាតិ ដើម្បីចែករំលែក និងពិភាក្សាដោយស្មោះត្រង់អំពីការយល់ដឹង ការអនុវត្តល្អបំផុត កិច្ចសហការ និងបញ្ហាប្រឈម សម្រាប់ការទទួលបានព័ត៌មានសាធារណៈ។
- ការធ្វើការលើការទទួលបានព័ត៌មានស្តីពីការវាយតម្លៃផលប៉ះពាល់សង្គមបរិស្ថាន (ESIA) និងសម្បទានដីសេដ្ឋកិច្ច (ELC) ទាមទារចំណេះដឹងបច្ចេកទេសរឹងមាំការយល់ដឹងអំពីក្របខ័ណ្ឌច្បាប់ និងការប្តេជ្ញាចិត្តនយោបាយ។
- ការបែងចែកថវិកាសម្រាប់សហគមន៍ហាក់ដូចជាមានភាពស្មុគស្មាញជាងលើការអនុលោមតាមនីតិវិធី និងការណែនាំអំពីបទប្បញ្ញត្តិ។ ដូច្នេះការតស៊ូមតិសម្រាប់ការរៀបចំថវិកាទាមទារការប្តេជ្ញាចិត្តជា អ្នកដឹកនាំ ហើយត្រូវការវិធីសាស្ត្រ និងការគាំទ្រពីកំពូលជាមួយទាំងក្រសួងហិរញ្ញវត្ថុទទួលបន្ទុក និងក្រសួងបច្ចេកទេសផ្សេងទៀត។

- ការបោះពុម្ពបានបញ្ចប់។
- វីដេអូចំនួន ប្រាំមួយនៅលើ A2I ត្រូវបានផលិតដោយយុវជន។
- វីដេអូចំនួន បួនស្តីពីការអប់រំថវិកា។
- វីដេអូចំនួន បួននៃករណីសិក្សាជោគជ័យ។
- វីដេអូចំនួន ប្រាំមួយអំពីសិក្ខាសាលាថ្នាក់ជាតិ A2I។
- ការបោះពុម្ពដែលបានគ្រោងទុក
- វីដេអូស្តីពីឯកសារ និងគំនូរជីវចលរបស់គម្រោង។

## ករណីសិក្សា៖

- ***ករណីសិក្សាទី០១៖*** សហគមន៍ព្រៃឈើអូរបញ្ញា (CPA)
- ***ករណីសិក្សាទី០២៖*** សហគមន៍ព្រៃឈើសាលាឆ្កោរ (CF)
- ***ករណីសិក្សាទី០៣៖*** ការទទួលបានព័ត៌មានធ្វើឱ្យមានផលប៉ះពាល់ជាវិជ្ជមានដល់សហគមន៍របស់ខ្ញុំ
- ***ករណីសិក្សាទី០៤៖*** ប្រជាពលរដ្ឋអាចជួយអ្នកកាន់កាតព្វកិច្ចឱ្យកាន់តែមានគណនេយ្យភាព
- ***ករណីសិក្សាទី០៥៖*** ពីគ្មានអ្វីក្លាយជាស្ត្រីជនជាតិដើមភាគតិចក្លាហាន
- ***ករណីសិក្សាទី០៦៖*** ការផ្លាស់ប្តូរអាកប្បកិរិយាសហគមន៍ក្នុងសហគមន៍អូរដារ

***ករណីសិក្សាទី១៖*** សហគមន៍ព្រៃឈើព្រងិល



**សហគមន៍ព្រៃឈើព្រងិល** ស្ថិតនៅ ឃុំព្រងិល ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់។ សហគមន៍បានបង្កើតឡើងក្នុងឆ្នាំ ១៩៩៤ ដោយប្រជាពលរដ្ឋមូលដ្ឋាន ភូមិ ឃុំ ស្រុក និងរដ្ឋបាលព្រៃឈើខេត្ត និងដោយមានការជួយជ្រោមជ្រែងពីអង្គការអភិវឌ្ឍន៍ស្ត្រីខ្មែរ និងអង្គការវើលហ្វីស។សហគមន៍ព្រៃឈើព្រងិល មានផ្ទៃដី ២៤៩ ហិកតាសរុប ២១៦ គ្រួសារ (សមាជិក ៩៤៥ នាក់ ស្រី ៤៤៥ នាក់)។ សហគមន៍ព្រៃឈើគ្រប់គ្រងដោយសមាជិកគណៈកម្មាធិការ សហគមន៍ចំនួន ១៥នាក់ ស្រី ៤នាក់។

អ្នកស្រី **វង្ស ចន្ថា** អាយុ ៤០ឆ្នាំ រស់នៅឃុំព្រងិល បានរៀបរាប់ថា គាត់ពិតជាព្រួយបារម្ភចំពោះការកាប់ បំផ្លាញព្រៃឈើ និងការដុតបំផ្លាញព្រៃឈើលើផ្ទៃដីប្រមាណ ១០ ហិកតា ដោយសារតែគ្រួសារ និងសហគមន៍ អាស្រ័យផល និងទទួលបានប្រាក់ចំណូលពីព្រៃសហគមន៍នេះ។



បន្ទាប់ពីកិច្ចប្រជុំពិភាក្សាថ្នាក់ស្រុកប្រធានសហគមន៍បានលើកឡើងថា ក្រុមប្រឹក្សាឃុំបានរៀបចំប្រជុំ រវាងក្រុមអ្នកកាប់ព្រៃឈើ និងសមាជិកសហគមន៍ (CBO) ដើម្បីពិភាក្សាអំពីបញ្ហាការទន្ទ្រានយកដីខុសច្បាប់។ ជាលទ្ធផលក្រុមអ្នកកាប់បំផ្លាញព្រៃឈើបានយល់ព្រមដកសម្ភារប្រើប្រាស់ដែលបានកាប់បំផ្លាញព្រៃឈើ ហើយបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងក្នុងការបញ្ឈប់ការកាប់ព្រៃឈើ។ បន្ថែមពីលើនេះក្រុមប្រឹក្សាឃុំបានបន្តដោះស្រាយបញ្ហានេះ ដោយទទួលបានលទ្ធផលល្អហើយក្រុមប្រឹក្សាឃុំ (CC) បានបន្តតាមដានជាមួយ សហគមន៍(CBO) អំពីការកាប់បំផ្លាញព្រៃឈើដោយសារតែបារម្ភថាអាចនឹងកើតឡើងម្តងទៀត។ ក្រុមប្រឹក្សាឃុំ ក៏មានកិច្ចសហប្រតិបត្តិការល្អជាមួយនិងគាំទ្រសហគមន៍ផងដែរ។ គណៈកម្មាការ និងសមាជិកសហគមន៍ បានស្នើសុំប្រធានក្រុមប្រឹក្សាស្រុក អភិបាលស្រុក និងមេឃុំ ព្រមទាំងស្ថាប័នពាក់ព័ន្ធទាំងអស់ជួយអន្តរាគមន៍ និងផ្តល់ថវិកាសម្រាប់ដើរល្បាត។



អ្នកស្រី **សយ សួរ** អាយុ ៤៥ឆ្នាំ រស់នៅឃុំព្រងិល មានប្រសាសន៍ថា៖ “ខ្ញុំសប្បាយចិត្តណាស់នៅ ពេលដែលគ្រួសារទាំងអស់បញ្ឈប់ការកាប់ព្រៃឈើហើយអ្នកចូលរួមបានការពារព្រោះសមាជិកសហគមន៍ទទួលបានអត្ថប្រយោជន៍ច្រើនពីសហគមន៍ព្រៃឈើ។ និងទទួលបានប្រាក់ចំណូលសម្រាប់សមាជិករបស់យើង”។ លោកស្រី ប្តេជ្ញាថានឹងបន្តកិច្ចខិតខំប្រឹងប្រែងចូលរួមជាមួយសហគមន៍ និងសហការជាមួយអាជ្ញាធរពាក់ព័ន្ធទាំងអស់ដើម្បីថែរក្សាព្រៃសហគមន៍។

***ករណីសិក្សាទី២៖*** សហគមន៍ព្រៃឈើកន្សែងរាល





**សហគមន៍ព្រៃឈើកន្សែងរាល** ស្ថិតនៅភូមិអូរក្រូច ឃុំសាលាវិស័យ ស្រុកប្រាសាទបល្ល័ង្ក ខេត្តកំពង់ធំ។ វាត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០០៤ ដោយរដ្ឋបាលព្រៃឈើថ្នាក់ខេត្ត សហការជាមួយអាជ្ញាធរឃុំ និងស្រុក។ សហគមន៍នេះមានចំនួន ១២០ គ្រួសារដែលមានផ្ទៃដី ៧៩០ហិកតា។ កាលពីខែសីហា ឆ្នាំ២០២១ ប្រជាពលរដ្ឋមួយក្រុមបានចូលមកកាប់បំផ្លាញព្រៃឈើនៅតំបន់ដែលជាកម្មសិទ្ធិរបស់ សហគមន៍ព្រៃឈើកន្សែងរាលដែលធ្វើឱ្យប៉ះពាល់ដល់ព្រៃអរក្ស អ្នកតា ព្រៃគោរពបូជា ជម្រកសត្វព្រៃ និងបណ្តាលឱ្យមានការថយចុះនូវអនុផលព្រៃឈើ។ ប្រសិនបើ មានការទប់ស្កាត់ និងដោះស្រាយទាន់ពេលវេលាព្រៃឈើខាងលើអាចត្រូវបានរក្សាទុកសម្រាប់សមាជិកសហគមន៍ នោះពួកគេនឹងមានភាពសប្បាយរីករាយ និងអាចប្រារព្ធពិធីវប្បធម៌របស់ពួកគេសម្រាប់ជនជាតិដើមភាគតិច និងធ្វើមានជីវភាពរស់នៅស្ថិរភាពសម្រាប់សមាជិកសហគមន៍ និងមនុស្សជំនាន់ក្រោយ។ **សហគមន៍** បានស្នើឱ្យក្រុមប្រឹក្សាឃុំ និងក្រុមប្រឹក្សាស្រុក ដោះស្រាយបញ្ហានេះសម្រាប់សហគមន៍ដើម្បីគាំទ្រដល់សហគមន៍។ គម្រោងរបស់យើងបានធ្វើការប្រជុំពិភាក្សាថ្នាក់ស្រុកជាមួយក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាឃុំ ដើម្បីបង្កើតឱកាសសម្រាប់សហគមន៍ដើម្បីលើកនូវបញ្ហារបស់ពួកគេទៅអាជ្ញាធរពាក់ព័ន្ធ។ អ្នកស្រី **ពៅ អ៊ាន** តំណាងសហគមន៍ព្រៃកន្សែងរាល បានស្នើសុំរួចហើយនៅឆ្នាំ ២០២១ ឱ្យប្រធានក្រុមប្រឹក្សាស្រុកប្រាសាទបល្ល័ង្ក អភិបាលស្រុកប្រាសាទបល្ល័ង្ក និងមេឃុំសាលាវិស័យ ព្រមទាំងអ្នកពាក់ព័ន្ធទាំងអស់ ជួយសហគមន៍ និងរកដំណោះស្រាយ។



អ្នកស្រី **ពៅ អ៊ាន** អាយុ ៤៣ ឆ្នាំ រស់នៅឃុំសាលាវិស័យ ស្រុកប្រសាទបល្ល័ង្គ ខេត្តកំពង់ធំ បាននិយាយថា គាត់ពិតជាព្រួយបារម្ភចំពោះការកាប់បំផ្លាញព្រៃឈើ និងការដុតបំផ្លាញព្រៃឈើក្នុងព្រៃគោរពបូជាព្រោះក្រុមគ្រួសារ និងសហគមន៍ របស់គាត់តែងតែមានជំនឿ និងប្រារព្ធទិវាវប្បធម៌របស់ពួកគេនៅក្នុងព្រៃនេះ។

បន្ទាប់ពីកិច្ចប្រជុំជាមួយរដ្ឋបាលស្រុកប្រាសាទបល្ល័ង្គ លោកស្រី **ពៅ អ៊ាន** តំណាងសហគមន៍ ព្រៃកន្សែងវាលបានរាយការណ៍ថាដោយមានការសម្របសម្រួលរវាងអាជ្ញាធរស្រុក រដ្ឋបាលព្រៃឈើ និងក្រុមប្រឹក្សាឃុំ បានរៀបចំកិច្ចប្រជុំមួយរវាងក្រុម អ្នកកាប់បំផ្លាញព្រៃឈើ និងសមាជិកសហគមន៍ ដើម្បីពិភាក្សាអំពីការកាប់បំផ្លាញព្រៃឈើខុសច្បាប់នៅក្នុងសហគមន៍។ ប៉ះពាល់ដល់ព្រៃឈើដែលជាព្រៃគោរពបូជាសម្រាប់ជនជាតិដើមភាគតិច។

ជាលទ្ធផលក្រុមអ្នកកាប់ព្រៃឈើបានយល់ព្រមប្រគល់ដើមឈើចំនួន ៣ ដើមជូនសហគមន៍វិញ និងបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងផ្តល់ភស្តុតាង និងដើមឈើដល់សហគមន៍វិញដើម្បីឈប់បំផ្លាញព្រៃឈើ។ បន្ថែមពីលើនេះ ក្រុមប្រឹក្សាឃុំ និងរដ្ឋបាលព្រៃឈើបានបន្តតាមដានជាមួយសហគមន៍ អំពីបញ្ហានេះ ដើម្បីព្យាយាមទប់ស្កាត់កុំឱ្យកើតមានរឿងបែបនេះទៀត។ រហូតមកដល់ពេលនេះក្រុមប្រឹក្សាឃុំនៅតែបន្តរក្សា កិច្ចសហប្រតិបត្តិការល្អជាមួយសហគមន៍។

***ករណីសិក្សាទី៣៖*** សហគមន៍ព្រៃឈើអូរបញ្ញា





គម្រោងនេះបានដំណើរការតាំងពីឆ្នាំ 2020 មកក្នុងគោលបំណលើកកម្ពស់សមត្ថភាពស្ត្រីជនជាតិ ដើមភាគតិចលើចំណេះដឹងផ្នែកថវិកា ការតស៊ូមតិសិទ្ធិមនុស្ស សម្បទានដីសេដ្ឋកិច្ច ការវាយតម្លៃផលប៉ះពាល់ បរិស្ថាន និងសង្គម ច្បាប់ស្តីពីធនធានធម្មជាតិ និងបរិស្ថាន។ **អ្នកស្រី យុត ធីន** ជាសមាជិកនៃ សហគមន៍ព្រៃឈើអូរបញ្ញាបានចូលរួមយ៉ាងសកម្មក្នុងគម្រោងសិទ្ធិទទួលព័ត៌មានសម្រាប់ទាំងអស់គ្នា។

អ្នកស្រីបានបញ្ជាក់ថា៖ **“ខ្ញុំរីករាយណាស់ដែលបានចែករំលែកចំណេះដឹងរបស់ខ្ញុំ និងផ្សព្វផ្សាយដល់ សហគមន៍របស់ខ្ញុំពីវិធីការពារព្រៃឈើ និងដីដែលក្រសួងទទួលស្គាល់”**។ មានប្រកាសលេខ៖ ១៨៩ ស្តីពីការគ្រប់គ្រង សហគមន៍អូរបញ្ញាជាតំបន់ការពារ ដែលស្ថិតក្នុងភូមិកន្ទួត ភូមិព្រិច ភូមិវាលចាស់ និងភូមិស្រែវាល ឃុំសាគ្រាម ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ ក្នុងដែនជម្រកសត្វព្រៃបឹងពែរ។ តំបន់ការពារសហគមន៍អូរបញ្ញា មានផ្ទៃដី ៥,៦១៨ ហិកតា ហើយខ្ញុំបានចូលរួមយ៉ាងសកម្ម ក្នុងគម្រោងសិទ្ធិទទួលព័ត៌មានសម្រាប់ទាំងអស់គ្នា (A4A)។ បន្ទាប់ពីទទួលបានការបណ្តុះបណ្តាល និងបង្វឹក ពីគម្រោង A4A អ្នកស្រី **យុត ធីន** បានចែករំលែកចំណេះដឹងថ្មីៗ និងផ្សព្វផ្សាយដល់សហគមន៍របស់ខ្លួន អំពីការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន។ លោកស្រី បាននឹងកំពុងកៀងគរ និងសម្របសម្រួលការ ចូលរួមរបស់សមាជិកសហគមន៍ក្នុងការការពារព្រៃឈើសហគមន៍តាមរយៈ ការចុះពិនិត្យជាក់ស្តែង និងកិច្ច ប្រជុំប្រចាំខែ មិនត្រឹមតែជាមួយសហគមន៍ប៉ុណ្ណោះទេ ថែមទាំងជាមួយមន្ត្រីរដ្ឋបាលឃុំ ដើម្បីលើកពីកង្វល់ របស់សហគមន៍អំពីការកាប់បំផ្លាញដែលបង្ករឡើងដោយអ្នកមានអំណាច និងស្នើឱ្យមន្ត្រីបរិស្ថាន និងស្រុក ជួយបណ្តុះបណ្តាល និងផ្សព្វផ្សាយដល់ប្រជាពលរដ្ឋអំពីផលប្រយោជន៍ព្រៃឈើ និងដីធ្លី។

> អ្នកស្រី **យុត ធីន** ប្រាប់ឱ្យដឹងថា “បញ្ហាប្រឈមចម្បងដែលសហគមន៍តំបន់ការពារ (CPA) មានបញ្ហាប្រឈមមុខគឺមិនមានកម្មសិទ្ធិដីធ្លី។ នៅក្រោមក្របខ័ណ្ឌច្បាប់ CPA សហគមន៍មានសិទ្ធិកាន់កាប់ដីធ្លីដោយផ្នែក ដែលក្នុងនោះ ជាទូទៅពួកគេមានសិទ្ធិចូលប្រើប្រាស់ សិទ្ធិដកហូតព្រៃឈើសម្រាប់ប្រើប្រាស់ និងសិទ្ធិគ្រប់គ្រងព្រៃឈើ។ ទោះជាយ៉ាងណាក៏ដោយ សហគមន៍ព្រៃឈើអូរបញ្ញា មិនមានសិទ្ធិផ្តាច់មុខ ឬសមត្ថភាពក្នុងការហាមឃាត់ប្រជាពលរដ្ឋដែលមិនមែនជាសមាជិកសហគមន៍ក្នុងការចូលប្រើប្រាស់ព្រៃ ឬដីសហគមន៍នោះទេ។ ដែលធ្វើឱ្យសិទ្ធិកាន់កាប់ គ្រប់គ្រងដីធ្លីរួមរបស់សហគមន៍មានការចុះខ្សោយ។ ធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំង ដល់ការធ្វើផែនការរយៈពេលវែងពីជីវភាពរស់នៅ និងការសម្រេចចិត្តអភិរក្សថែរក្សាព្រៃឈើរបស់ពួកគេ”។

ការកែសម្រួលក្របខ័ណ្ឌច្បាប់សហគមន៍តំបន់ការពារ (CPA) ដើម្បីអនុញ្ញាតឱ្យសហគមន៍ទទួលបានសិទ្ធិកាន់កាប់ គ្រប់គ្រងដីធ្លីដែលសមស្របជាងមុនរួមទាំងសិទ្ធិក្នុងការដកចេញពីអ្នកខាងក្រៅ នឹងបង្កើនប្រសិទ្ធ ភាពយ៉ាងខ្លាំងនៃក្របខ័ណ្ឌច្បាប់ដែលមានស្រាប់។ លើសពីនេះទៀត ការពង្រីករយៈពេលនៃការកាន់កាប់តំបន់ ការពារ (CPA) នឹងអនុញ្ញាតឱ្យសហគមន៍ចូលរួមយ៉ាងពេញលេញនៅក្នុងសកម្មភាពគ្រប់គ្រងជាប់លាប់ក្នុង រយៈពេលយូរ។ លោកស្រី **យុត ធីន** មានប្រសាសន៍ថា **“ជាមួយនឹងការអនុវត្តសកម្មភាពខ្ញុំតែងតែកៀងគរ និងសម្របសម្រួលសហគមន៍របស់ខ្ញុំ ដើម្បីចូលរួមកិច្ចប្រជុំដៃគូពាក់ព័ន្ធ និងមន្ត្រីឃុំ និងស្រុក”**។ “នៅរាល់ការប្រជុំ ខ្ញុំបានបង្ហាញពីតម្រូវការរបស់សមាជិកក្នុងតំបន់ការពារ (CPA) ទាំងអស់ដែលតស៊ូមតិ ដល់អ្នកដែលមានកត្តាកិច្ច។ ការគ្រប់គ្រងតំបន់ការពារ (CPA) បច្ចុប្បន្នគឺភាគច្រើនជាបុរស ហើយការដាក់ បញ្ចូលស្ត្រី យុវជន និងសមាជិកសហគមន៍ក្រីក្រ ចាំបាច់ត្រូវមានការលើកទឹកចិត្តបន្ថែមទៀត។ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ក្រុមគម្រោងសិទ្ធិទទួលព័ត៌មាន (A4A) ដែលតែងតែគាំទ្រ ពួកយើង និងផ្តល់ការបណ្តុះបណ្តាល និងការបង្វឹកដល់សហគមន៍របស់ខ្ញុំ ដើម្បីយល់ពីរបៀបគ្រប់គ្រងសហគមន៍តំបន់ការពារ (CPA) ការតស៊ូមតិ និងទាមទារសិទ្ធិ និងការទទួល ព័ត៌មានសម្រាប់សហគមន៍។

***ករណីសិក្សាទី៤៖*** សហគមន៍ព្រៃឈើសាលាឆ្តោរស្ត្រីជនជាតិដើមភាគតិច

បន្ទាប់ពីគម្រោងបានកសាងសមត្ថភាពដល់ សហគមន៍ព្រៃឈើសាលាឆ្តោរ ស្ត្រីជនជាតិ ដើមភាគតិច ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ ស្ត្រីភាគច្រើនទទួលបានចំណេះដឹងផ្នែកថវិកា និងច្បាប់ទាក់ទង នឹងការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន។ អ្នកស្រី **ហ៊ិន គីម** សមាជិកសហគមន៍ព្រៃឈើ បានមានប្រសាសន៍ថា៖ **“ពីមុនខ្ញុំខ្លាចក្នុងការនិយាយជាមួយអាជ្ញាធរមូលដ្ឋាននៅក្នុងវេទិកាសាធារណៈ និងកិច្ចប្រជុំផ្សេងទៀត អំពីការបំផ្លាញព្រៃឈើសហគមន៍ និងបញ្ហាថវិកាស្រុក។ ឥឡូវនេះ ខ្ញុំមានមោទនភាព និងមានទំនុកចិត្តយ៉ាងខ្លាំងក្នុងការរាយការណ៍អំពីអត្ថប្រយោជន៍នៃព្រៃឈើ និងផែនការថវិការបស់ស្រុក ជាមួយអាជ្ញាធរមូលដ្ឋានទាំងផ្ទាល់មុខ និងតាមរយៈការប្រជុំផ្សេងទៀតនៅថ្នាក់ឃុំ ស្រុក និងខេត្ត”**។



ក្នុងវេទិកាសាធារណៈស្រុកនៅថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៣ លោកស្រី **ហ៊ិន គីម** បានលើកឡើងពី កង្វល់អំពីព្រៃឈើសហគមន៍ត្រូវបានបំផ្លាញដោយវិស័យឯកជន និងអ្នកមានអំណាចក្នុង សហគមន៍ព្រៃឈើសាលាឆ្តោរ ក្នុងស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ។ លើសពីនេះ លោកស្រី បានចែករំលែកព័ត៌មាន អំពីចំណេះដឹងផ្នែកថវិកា និងធនធានធម្មជាតិ។ ជាពិសេស ទាក់ទងនឹងសម្បទានដីសេដ្ឋកិច្ច (ELC) និងការវាយតម្លៃផល ប៉ះពាល់បរិស្ថាន និងសង្គម លោកស្រី បានប្រាប់ឱ្យដឹងថា **“អាជ្ញាធរ មូលដ្ឋានដែលពាក់ព័ន្ធ មិនបានផ្តល់ ឬផ្សព្វផ្សាយព័ត៌មាន ដល់សហគមន៍របស់ខ្ញុំទេ ធ្វើឱ្យមានជម្លោះរវាងសមាជិកសហគមន៍ និងក្រុមហ៊ុនឯកជន”**។

បន្ទាប់ពី លោកស្រី បានចែករំលែកចំណេះដឹងដែលទើបទទួលបានថ្មីជាមួយអ្នកភូមិពួកគាត់ ភាគច្រើនទទួលបានការយល់ដឹងអំពីសិទ្ធិទទួលបានព័ត៌មាននៅក្នុងរដ្ឋបាលស្រុក និងឃុំបានចូលរួមក្នុងការអនុវត្តគម្រោងឃុំ ស្រុក និងរបាយការណ៍ហិរញ្ញវត្ថុ និងនិយាយដោយក្លាហានចំពោះអ្នកពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន ដើម្បីទាមទារការគោរពសិទ្ធិរបស់ពួកគេ។

លោកស្រី **លួន ស៊ីនួន** សមាជិកគណៈកម្មាការ សហគមន៍ព្រៃឈើសាលាឆ្តោរមានប្រសាសន៍ថា៖ ស្ត្រីជនជាតិដើមភាគតិចដែលប្រមូលផ្តុំគ្នានៅក្នុងគណៈកម្មាការបាននិងកំពុងដាក់ពាក្យបណ្តឹងទៅកាន់តុលាការដើម្បីការពារសិទ្ធិរបស់ពួកគេប្រឆាំងនឹងក្រុមហ៊ុន និងអ្នកមានអំណាចក្នុងអំឡុងពេល ជម្លោះព្រៃឈើសហគមន៍។ **“នៅក្នុងសហគមន៍របស់ខ្ញុំ បញ្ហាចម្បងដែលស្ត្រីជនជាតិដើមភាគតិចជួបប្រទះ គឺបញ្ហាដីធ្លី យើងជាប់ពាក់ព័ន្ធនឹងវិវាទដីធ្លីរបស់សហគមន៍ព្រៃឈើជាមួយក្រុមហ៊ុនឯកជនដែលបានទទួលសម្បទានដីសេដ្ឋកិច្ចពីរដ្ឋាភិបាល និងអ្នកមានអំណាចក្នុងតំបន់”**។ គម្រោងនេះ បានកត់សម្គាល់ លោកស្រី **លួន ស៊ីនួន** **“បានប្រមូលផ្តុំ និងសម្របសម្រួលការចូលរួមរបស់ស្ត្រីជនជាតិដើមភាគតិចជាសមាជិកសហគមន៍ព្រៃឈើដើម្បីចូលរួមកិច្ចប្រជុំនៅថ្នាក់ឃុំ និងស្រុកដើម្បីលើកឡើងពីកង្វល់របស់ពួកគេអំពីសហគមន៍ ព្រៃឈើត្រូវបានបំផ្លាញដោយក្រុមហ៊ុន និងអ្នកមានអំណាច”**។

## គម្រោងទី១៦ គម្រោងត្រួតពិនិត្យ និងសកម្មភាពអ៊ីនធឺណិត

**គោលបំណងនៃគម្រោង៖** លើកកម្ពស់ និងការពារសេរីភាពអ៊ីនធឺណិត តាមរយៈសង្គមស៊ីវិលទទួល បានយល់ដឹងកាន់តែប្រសើរឡើងពីអំពីការត្រួតពិនិត្យអ៊ីនធឺណិត សិទ្ធិឌីជីថល និងសុវត្ថិភាពក្នុងការតស៊ូមតិ។ សង្គមស៊ីវិល និងប្រជាពលរដ្ឋសកម្មត្រូវបានបណ្តុះបណ្តាលអំពីសេរីភាពអ៊ីនធឺណិត សិទ្ធិឌីជីថល និងសុវត្ថិភាព ឌីជីថលជាការបំពេញបន្ថែមដល់ការតស៊ូមតិរបស់អង្គការវិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ (API) និងការបណ្តុះបណ្តាលអភិវឌ្ឍន៍សមត្ថភាពក្នុងការទទួលយកពត៍មាន (A2I)។

**ដៃគូអនុវត្ត៖** វិទ្យាស្ថានគ្រប់គ្រងបូព៌ា-បស្ចឹម (EWMI)

**មូលនិធិ៖** US DoS តាមរយៈ EWMI បានផ្តល់មូលនិធិ ៥០,២៨០ ដុល្លារសហរដ្ឋអាមេរិក។

**តំបន់គោលដៅ៖** រាជធានីភ្នំពេញ





### លទ្ធផល

របាយការណ៍ត្រួតពិនិត្យអ៊ីនធឺណិត iMAP Cambodia 2023 ត្រូវបានសរសេរ និងចែកចាយនៅលើគេហទំព័រ API និងSINA។ របាយការណ៍នេះត្រូវបានផ្សព្វផ្សាយទៅកាន់បណ្តាញ អង្គការសង្គមស៊ីវិលចំនួន 35 ដែលមានតំណាងចំនួន 140 នាក់ (ស្រី 55នាក់) នៃដៃគូអភិវឌ្ឍន៍ (DPs) អង្គការសង្គមស៊ីវិល និងប្រព័ន្ធផ្សព្វផ្សាយ។ របាយការណ៍នេះត្រូវបានប្រើប្រាស់ជាឯកសាយោងសម្រាប់ សរសេររបាយការណ៍ត្រួតពិនិត្យតាមកាលកំណត់ជាសកលឆ្នាំ2023 ស្តីពីសេរីភាពនៃការបញ្ចេញមតិ តាមរយៈប្រព័ន្ធផ្សព្វផ្សាយ និងប្រព័ន្ធផ្សព្វផ្សាយសង្គម និងរបាយការណ៍ត្រួតពិនិត្យព័ត៌មានពីប្រទេសកម្ពុជា។ របាយការណ៍ត្រួតពិនិត្យអ៊ីនធឺណិតសម្រាប់ប្រទេសកម្ពុជា ត្រូវបានដាក់ឱ្យប្រើប្រាស់ជារៀងរាល់ឆ្នាំក្នុងឆ្នាំ2022 2023 ហើយត្រូវបានប្រើប្រាស់ដើម្បីជូនដំណឹងអំពីសកម្មភាពសង្គមស៊ីវិល និងការតស៊ូមតិរបស់ ក្រុមការងារសិទ្ធិឌីជីថល។

### សកម្មភាព៖

- ពង្រឹងសមត្ថភាពរបស់អង្គការសង្គមស៊ីវិល លើសិទ្ធិឌីជីថល និងការត្រួតពិនិត្យអ៊ីនធឺណិតដោយ ត្រួតពិនិត្យគេហទំព័រជាង 2.000 គេហទំព័រ។ របាយការណ៍ត្រួតពិនិត្យអ៊ីនធឺណិត បានរកឃើញថា គេហទំព័រចំនួន 43 ត្រូវបានរាំងដោយអ្នកផ្តល់សេវាអ៊ីនធឺណិតក្នុងឆ្នាំ2022 និងគេហទំព័រចំនួន 36 ត្រូវបានបិទនៅឆ្នាំ2023 ដែលភាគច្រើនជាកម្មសិទ្ធិរបស់ក្រុមហ៊ុនវៀតណាម និងកចិន។ ការបិទគេហទំព័រត្រូវបានការណែនាំពីរដ្ឋាភិបាលដូចជា ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យដូចជា វិទ្យុវីអូឌី វិទ្យុអាស៊ីសេរីខ្មែរ និងផ្សេងៗទៀត។

- បានផ្សព្វផ្សាយកម្មវិធីត្រួតពិនិត្យការរិតត្បិតអ៊ីនធឺណិត (iMAP) ឈ្មោះកម្មវិធី OONI Probe មានក្នុងប្រព័ន្ធប្រតិបត្តិការអ៊ិនធឺណិតរបស់ Appstore(IOS) Android និងWindows។ អ្នកស្ម័គ្រចិត្តដែលលើកកម្ពស់សិទ្ធិឌីជីថលអនឡាញ និងសេរីភាពអ៊ីនធឺណិតបានប្រើកម្មវិធីOONI នេះជារៀងរាល់ថ្ងៃដើម្បីត្រួតពិនិត្យការរិតត្បិតគេហទំព័រ។ ចាប់ពីខែមិថុនា ឆ្នាំ2022 ដល់ខែកក្កដា ឆ្នាំ2023 ការវាស់វែងខ្ពស់បំផុតគឺនៅខែមីនា ឆ្នាំ2023 (338.699) ទីពីរ គឺនៅក្នុងខែឧសភា 2023 (288.616) ហើយអប្បបរមាគឺនៅក្នុងខែកក្កដា (20.222)។ លទ្ធផល បានកើនឡើងយ៉ាងខ្លាំងបន្ទាប់ពីការបណ្តុះបណ្តាល iMAP សម្រាប់ក្រុមអង្គការសង្គមស៊ីវិល មួយចំនួន។




- ក្រាហ្វខាងក្រោមបង្ហាញពីតួលេខប្រចាំខែ៖
- របាយការណ៍ត្រួតពិនិត្យអ៊ីនធឺណិតឆ្នាំ2022 ត្រូវបានអនុម័ត។
- សហការជាមួយក្រុមការងារសិទ្ធិឌីជីថលរៀបចំវេទិកាអ៊ីនធឺណិតភ្នំពេញ (PPIF)។
- បានធ្វើបទបង្ហាញរបាយការណ៍ត្រួតពិនិត្យការត្រួតពិនិត្យអ៊ីនធឺណិតដល់អង្គការយូណេស្កូកម្ពុជា។
- មានកិច្ចប្រជុំដើម្បីពិនិត្យសេចក្តីព្រាងរបាយការណ៍ត្រួតពិនិត្យការរិតត្បិតអ៊ីនធឺណិត ឆ្នាំ2023។
- ចេញរបាយការណ៍ត្រួតពិនិត្យការរឹតត្បិតអ៊ីនធឺណិតឆ្នាំ2023 ដែលផ្សព្វផ្សាយនៅលើគេហទំព័រ API SINA Facebook និងប្រព័ន្ធផ្សព្វផ្សាយសង្គម តាមវិទ្យុសម្លេងអាមេរិក (VoA) និងទៅកាន់បណ្តាញអង្គការសង្គមស៊ីវិល និងអ្នកកាសែតផងដែរ។
- សម្របសម្រួលការបណ្តុះបណ្តាលសន្តិសុខឌីជីថល និងពិគ្រោះយោបល់លើសេចក្តីព្រាងសេចក្តី ណែនាំស្តីពីសិទ្ធិឌីជីថល និងសេរីភាពអ៊ីនធឺណិតសម្រាប់សង្គមស៊ីវិលកម្ពុជា។
- បានបញ្ចប់សកម្មភាពបន្ថែមដូចជា៖
    - ផែនការសកម្មភាពត្រួតពិនិត្យអ៊ីនធឺណិតប្រចាំថ្ងៃ (iMAP)
    - ផ្សព្វផ្សាយរបាយការណ៍ត្រួតពិនិត្យអ៊ីនធឺណិតឆ្នាំ2022
    - សហការជាមួយក្រុមការងារសិទ្ធិឌីជីថល រៀបចំវេទិកាអ៊ីនធឺណិតភ្នំពេញ (PPIF)
    - ធ្វើបានធ្វើបទបង្ហាញរបាយការណ៍ត្រួតពិនិត្យការត្រួតពិនិត្យអ៊ីនធឺណិតដល់អង្គការយូណេស្កូកម្ពុជា
    - សម្របសម្រួលការបណ្តុះបណ្តាលសន្តិសុខឌីជីថល និងពិគ្រោះយោបល់លើសេចក្តីព្រាងសេចក្តី ណែនាំស្តីពីសិទ្ធិឌីជីថល និងសេរីភាពអ៊ីនធឺណិតសម្រាប់សង្គមស៊ីវិលកម្ពុជា
    - បានចូលរួមសិក្ខាសាលាអាស៊ីប៉ាស៊ីហ្វិកសិទ្ធឌីជីថលថ្នាក់តំបន់នៅប្រទេសថៃ
    - បានចូលរួមកិច្ចប្រជុំផែនការសកម្មភាពត្រួតពិនិត្យអ៊ីនធឺណិតក្នុងតំបន់ (IMAP) ដើម្បីលើកបញ្ហាប្រឈម និងចំណុចដែលត្រូវកែលម្អ
    - ការប្រជុំគម្រោងប្រចាំខែជាមួយក្រុមគម្រោង SINA។

## បញ្ហាប្រឈម៖

- ប្រជាជនអាចចូលប្រើអ៊ីនធឺណិតបាន ប៉ុន្តែពួកគេមិនយល់ថាសេរីភាពនៃការបញ្ចេញមតិ ឬសិទ្ធិឌីជីថលជាអ្វីនោះទេ។
- ប្រជាជនមានការភ័យខ្លាចចំពោះការបញ្ចេញគំនិតទាក់ទងនឹងនយោបាយ ឬការបង្ហោះព័ត៌មានពិតនៅលើបណ្តាញសង្គម។
- ក្រុមហ៊ុនផ្តល់សេវាអ៊ិនធឺណែតនៅកម្ពុជាគ្រប់គ្រងដោយក្រុមហ៊ុនវៀតណាម និងក្រុមហ៊ុនចិន។ ខណៈពេលដែលរាល់ទិន្នន័យឯកជន និងទិន្នន័យគម្រោងកំពុងប្រើប្រាស់អ៊ិនធឺណែតរបស់ក្រុមហ៊ុន អ៊ិនធឺណិត និងក្រុមហ៊ុនទូរសព្ទចល័ត។
- ចំណេះដឹងរបស់ប្រជាជនផ្នែក សុវត្ថិភាពឌីជីថលមានកំរិត ដូច្នេះមានការព្រួយបារម្ភពីអសន្តិសុខក្នុងការប្រើប្រាស់បច្ចេកវិទ្យាពត៌មានវិទ្យា (Hacker attacking)។

## ផែនការបន្ទះ

- ទិន្នន័យត្រួតពិនិត្យការរឹតត្បិតអ៊ិនធឺណែតដោយប្រើកម្មវិធី ត្រួតពិនិត្យដោយបើកចំហរនៃការជ្រៀត ជ្រែកបណ្តាញ(OONI)
- របាយការណ៍ត្រួតពិនិត្យការរឹតត្បិតអ៊ិនធឺណែត និងបែបផែននៃបទប្បញ្ញត្តិ
- សម្របសម្រួលដល់ការប្រជុំបណ្តាញ ការត្រួតពិនិត្យដោយបើកចំហនៃការជ្រៀតចូលបណ្តាញ (OONI) ថ្នាក់ជាតិ ពាក់កណ្តាលឆ្នាំជាមួយសមាជិក 25នាក់។
- របាយការណ៍ប្រចាំឆ្នាំរបស់ប្រទេសកម្ពុជា ស្តីពីត្រួតពិនិត្យការរឹតត្បិតអ៊ីនធឺណិត និងផ្សព្វផ្សាយ របាយការណ៍ដល់ក្រុមការងារសង្គមស៊ីវិលដែលពាក់ព័ន្ធសម្រាប់ការតស៊ូមតិរួមគ្នា។
- រៀបចំ និងសម្របសម្រួលសិក្ខាសាលាដៃគូក្នុងស្រុក។
- ធ្វើបច្ចុប្បន្នភាពបញ្ជីគេហទំព័ររបស់ប្រទេស
- បង្កើតម៉ូឌុលបណ្តុះបណ្តាលស្តីពីសេរីភាពអ៊ីនធឺណិត សិទ្ធិឌីជីថល និងសុវត្ថិភាពដែលបំពេញបន្ថែម លើការតស៊ូមតិ និងកម្មវិធីសិក្សា A2I សម្រាប់អង្គការសង្គមស៊ីវិល និងប្រជាពលរដ្ឋសកម្ម។
- បណ្តុះបណ្តាលទៅលើគោលនយោបាយតស៊ូមតិដើម្បីជ្រើសរើសតួអង្គសង្គមស៊ីវិល និងប្រជាពល រដ្ឋសកម្ម។
- បណ្តុះបណ្តាលទៅលើសិទ្ធឌីជីថល សេរីភាពក្នុងកាបញ្ចេញមតិ សុវត្ថិភាពលើប្រព័ន្ធអនឡាន រយៈពេលពីរថ្ងៃនឹងធ្វើឡើងជារៀងរាល់ឆ្នាំសម្រាប់អ្នកចូលរួមចំនួន ២៥នាក់។

## គម្រោងទី១៧ ឆ្ពោះទៅរកតម្លាភាពលទ្ធកម្មសាធារណៈ (PPT)

**គោលបំណងនៃគម្រោង៖** លើកកម្ពស់ការទទួលព័ត៌មាន និងតម្លាភាពនៅក្នុងច្បាប់លទ្ធកម្មសាធារណៈ ឆ្នាំ២០២៣
**ដៃគូអនុវត្ត៖** អង្គការតម្លាភាពកម្ពុជា
**ការផ្តល់មូលនិធិ៖** EU/SIDA-ផ្តល់មូលនិធិតាមរយៈអង្គការតម្លាភាពកម្ពុជា
**តំបន់គោលដៅ៖** រាជធានីភ្នំពេញ






### លទ្ធផល

ច្បាប់លទ្ធកម្មសាធារណៈត្រូវបានអនុម័តក្នុងឆ្នាំ ២០២៣ និងទទួលយកធាតុចូលរបស់អង្គការ API ដែលបានកែសម្រួលមាត្រាមួយចំនួន។

### សកម្មភាព

របាយការណ៍ការវិភាគសេចក្តីព្រាងច្បាប់ ស្តីពីលទ្ធកម្មសាធារណៈត្រូវបានធ្វើបទបង្ហាញដើម្បីតស៊ូមតិ ជាមួយរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ក្នុងកិច្ចប្រជុំក្រុមការងារបច្ចេកទេសឆ្នាំ២០២៣ ដែលសម្របសម្រួលដោយ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## គម្រោងទី១៨ សំឡេងពលរដ្ឋដើម្បីសេវាគាំពារសង្គមកាន់តែប្រសើរឡើង តាមរយៈការអនុវត្តផែនការគណនេយ្យភាពសង្គម I-SAF

**ដៃគូអនុវត្ត៖** Epic Arts សមាគមតន្ត្រីសំនៀងជនពិការ (MAPD) មជ្ឈមណ្ឌលជីវិតរស់នៅដោយ ឯករាជ្យនៃជនពិការភ្នំពេញ (PPCIL) និងសមាគមមនុស្សចាស់ (OAA)

**ការផ្តល់មូលនិធិ៖** Voice Grant Faciality ផ្តល់មូលនិធិដោយរដ្ឋាភិបាលប្រទេសហូឡង់ តាមរយៈអង្គការអុកស្វាម

**តំបន់គោលដៅ៖** រាជធានីភ្នំពេញ





### លទ្ធផល៖

- គម្រោងនេះបានកៀរគរ ១១០% នៃសមាជិកគោលដៅរបស់សមាគមនៅក្នុងសហគមន៍ (CBO) ដែលជាមនុស្សវ័យចាស់និងជនមានពិការភាព។ ពួកគេបានផ្តល់មតិកែលម្អដើម្បីកែលម្អការផ្តល់សេវា គាំពារសង្គម។ អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ (CAFs) ចំនួន ៥០នាក់ ដែលមានស្ត្រីស្មើនឹង ៥០% មានទំនុកចិត្តយ៉ាងខ្លាំង និងអាចសម្របសម្រួលកញ្ចប់ព័ត៌មានសម្រាប់ ប្រជាពលរដ្ឋ(I4C) និងសម្របសម្រួលកិច្ចប្រជុំនានា។ អ្នកផ្តល់សេវាបានអនុវត្ត ៧៩% នៃ JAAP ក្នុងឆ្នាំ ២០២៣ (សង្កាត់ថ្មីចំនួន ៣)។ ពួកគេបានរៀបចំផែនការសកម្មភាពរួមគណនេយ្យភាពសង្គម (JAAP) ជាមួយនឹងសកម្មភាពដែលបានស្នើឡើងដើម្បីធ្វើឱ្យប្រសើរឡើងចំនួន ២៣៦ រួមមានសកម្មភាពទាក់ទងនឹងកិច្ចគាំពារសង្គមចំនួន ៣៦ ដើម្បីកែលម្អសេវាសាធារណៈនៅក្នុងសាលាបឋមសិក្សាចំនួន ១០ មណ្ឌលសុខភាពចំនួន ០៥ សង្កាត់ ០៦ និងខណ្ឌចំនួន ០១។
- គម្រោងនេះបានជួយដល់ជនមានពិការភាពចំនួន ២៥៩ ឱ្យទទួលបានប័ណ្ណអត្តសញ្ញាណកម្មជនមាន ពិការភាព សមាជិកសមាគមមនុស្សវ័យចាស់ទទួលបានប័ណ្ណសមធម៌ចំនួន ៧៥ គ្រួសារ និង ៣០ គ្រួសារដែលត្រូវបានកំណត់ថាជាគ្រួសារងាយរងហានិភ័យ និងជាសមាជិក សមាគមមនុស្សវ័យចាស់ នៅសង្កាត់ភ្នំពេញថ្មីបានទទួលជំនួយជាសាច់ប្រាក់ប្រចាំខែពីរដ្ឋាភិបាលក្នុងឆ្នាំ២០២៣ ។ ជាលទ្ធផល នៃគម្រោង ពួកគេបានប្រើសិទ្ធិរបស់ពួកគេដើម្បី កែលម្អឱ្យការផ្តល់សេវាសាធារណៈឱ្យកាន់តែប្រសើរ ឡើងពីអ្នកផ្តល់សេវានៃរដ្ឋបាលសង្កាត់ ភ្នំពេញថ្មីក្នុងឆ្នាំ ២០២៣។
- ការវាយតម្លៃគម្រោងរបស់សមាគមមនុស្សវ័យចាស់៖ មនុស្សវ័យចាស់ចំនួន ១,៣៨៣នាក់ ក្នុងនោះ ៨៤៧នាក់ ជាស្ត្រីដែលត្រូវបានធ្វើការសម្ភាសនៅតំបន់គោលដៅក្នុងឆ្នាំ២០២៣។
    - ជាលទ្ធផល អ្នកឆ្លើយតបសំណួរសរុបចំនួន ៣៥% (៤៧៥នាក់ ក្នុងចំណោម ១.៣៨៣នាក់) បានឆ្លើយថាបានចូលរួមក្នុងសកម្មភាពគម្រោងហើយ ៦៦% នៃអ្នកឆ្លើយតប ចំនួន ៤៧៥នាក់ បានចូលរួម ០៥ដង នៃសកម្មភាពគម្រោង។ អ្នកឆ្លើយតបសំណួរភាគច្រើន ចូលរួមនៅក្នុងការប្រជុំកៀរគរនៅក្នុងសហគមន៍ការចូលរួមកិច្ចប្រជុំដើម្បីយល់ដឹងអំពីការអប់រំសម្រាប់ប្រជាពលរដ្ឋប្រជុំផ្សព្វផ្សាយកញ្ចប់ព័ត៌មាន និងការដាក់ប័ណ្ណពិន្ទុសហគមន៍តាមឌីជីថល។ មនុស្សវ័យចាស់បានលើក ឡើងពី បញ្ហាសុខភាព និងការសិក្សាសម្រាប់កុមារ។
    - បន្ទាប់ពីការជួយអន្តរាគមន៍របស់គម្រោង ៦០% នៃមនុស្សវ័យចាស់ ១.៣៨៣នាក់ បានលើកឡើងថាពួកគេទទួលបាននូវការផ្តល់សេវាសាធារណៈលឿនរហ័សជាងមុននៅឆ្នាំ២០២៣។

  - ៤៣% នៃមនុស្សវ័យចាស់ ១.៣៨៣នាក់ បានរាយការណ៍ពីភាពប្រសើរឡើងនៃ អាកប្បកិរិយារបស់អ្នកផ្តល់សេវានៅរដ្ឋបាលថ្នាក់ក្រោមជាតិ។
  - ប្រហែល១០% នៃមនុស្សវ័យចាស់ចំនួន ១.៣៨៣នាក់ បាននិយាយថាមានការកែលម្អខ្លះៗ ក្នុងការឆ្លើយតបរបស់រដ្ឋាភិបាលចំពោះតម្រូវការរបស់មនុស្សវ័យចាស់តាមរយៈការផ្តល់ប័ណ្ណសមធម៌ និងប័ណ្ណគ្រួសារដែលងាយរងហានិភ័យខ្ពស់ការកែលម្អលទ្ធភាព ទទួលបានព័ត៌មាន សាធារណៈការកែលម្អបញ្ហាសន្តិសុខ និងបរិស្ថាន។
  - ២៦% នៃមនុស្សវ័យចាស់ចំនួន ១,៣៨៣នាក់ បានបញ្ជាក់ថាពួកគេយល់អំពីសិទ្ធិ និងសិទ្ធិទទួលបានសេវាសាធារណៈនៅរដ្ឋបាលសង្កាត់ និងខណ្ឌ។
  - ១៤% នៃមនុស្សវ័យចាស់ចំនួន ១.៣៨៣ នាក់បាននិយាយថាទទួលបានអាហារ និងសំភារៈបន្ថែមពីរដ្ឋាភិបាល។
  - ២៤% នៃមនុស្សវ័យចាស់ចំនួន ១.៣៨៣ នាក់ បានបញ្ជាក់ថា នៅពេលដែលពួកគេ ទទួលបានប័ណ្ណសមធម៌ ប័ណ្ណងាយរងហានិភ័យ ឬប័ណ្ណអត្តសញ្ញាណកម្មជនមានពិការភាព គឺការប្រើប្រាស់សេវាសាធារណៈដោយមិនគិតថ្លៃពីរដ្ឋាភិបាលហើយបានសង្កេតឃើញថាការឆ្លើយតបលឿនជាងមុន ដោយអ្នកផ្តល់សេវានៅពេលទៅប្រើសេវាសាធារណៈ។
- លើសពីនេះ តំណាងសហគមន៍ ចំនួន ១៩នាក់ (ស្រី ១៣នាក់) បានបន្តលើកឡើងនូវ បញ្ហានានានៅក្នុងផែនការសកម្មភាពរួមគណនេយ្យភាពសង្គម (JAAP) ដូចជា ប.ស.ស. ប្រាក់សោធននិវត្តន៍ប័ណ្ណអត្តសញ្ញាណកម្មជនមានពិការភាព សេវាគាំពារសង្គមសម្រាប់ប្រជាពលរដ្ឋងាយរងគ្រោះក្រីក្រ ផ្លូវជម្រាល អាហារូបករណ៍សម្រាប់សិស្សក្រីក្រ និងបញ្ហាទាក់ទងនឹងសេវាសង្គមនៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាសង្កាត់ និងខណ្ឌសែនសុខ និង សិក្ខាសាលាថ្នាក់ជាតិចំនួន ១៥។
- សរុបជារួមសមាជិក និងតំណាងសហគមន៍ចំនួន ១២០នាក់ (ស្រី ៩៨នាក់) បានលើកជាសំណួរ និងបញ្ហាចំនួន ១៣០ នៅក្នុងវេទិកាសាធារណៈចំនួន ១២។ ជាលទ្ធផលអាជ្ញាធរបានឆ្លើយតប និងបកស្រាយរាល់ចម្ងល់ និងសំណូមពរភ្លាមៗ ហើយបញ្ហាមួយចំនួនទាក់ទងនឹងការស្នើសុំប័ណ្ណសមធម៌ ប័ណ្ណអត្តសញ្ញាណកម្មជនមានពិការភាព (PWD Cards) ប័ណ្ណងាយរងហានិភ័យ និងការស្នើសុំជំនួយសម្រាប់ប្រជាពលរដ្ឋ ងាយរងគ្រោះក្រីក្រ និងជនមានពិការភាពត្រូវបានឆ្លើយតប។

## សកម្មភាព៖

- កសាងសមត្ថភាពដល់ CBOs និងមន្រ្តីរដ្ឋាភិបាល។ សមាជិក CBO សរុបចំនួន ៦៥៦ នាក់ (ស្រី ៣៦៣ នាក់) ដែលរួមមានជនមានពិការភាព មនុស្សវ័យចាស់ និងគ្រួសារក្រីក្រស្មើនឹង ១០៩,៣៣% បើធៀបនឹងសមាជិកចំនួន ៦០០ នាក់ដែលបានគ្រោងទុកសម្រាប់រយៈពេល ២ ឆ្នាំត្រូវបានកៀរគរ និងយល់ដឹងពីគោលគំនិតសំខាន់ៗអំពីសិទ្ធិរបស់ពួកគេក្នុងការប្រើប្រាស់សេវា សាធារណៈរួមទាំង សេវាគាំពារសង្គមតាមរយៈកិច្ចប្រជុំផ្សព្វផ្សាយ។
- CBOs បានអនុវត្តចំណេះដឹងរបស់ពួកគេនិងការស្វែងរកមតិគាំទ្រ។ សមាជិក CBO សរុបចំនួន ៥៥០ នាក់ (ស្ត្រី ៣០១ នាក់) បានអនុវត្ត ឬប្រើប្រាស់ចំណេះដឹងរបស់ពួកគេហើយបានលើកឡើងអំពីបញ្ហា និងសំណើចំនួន ៣៣០ (៩៤ បញ្ហាដែលបានស្នើនៅក្នុងឆ្នាំ២០២២ និង ២៣៦បញ្ហា ត្រូវបានស្នើ នៅក្នុងឆ្នាំ២០២៣) លើកិច្ចការពារសង្គមដើម្បីស្វែងរកការអន្តរាគមន៍ពីអ្នកផ្តល់សេវាតាមរយៈ ការដាក់ពិន្ទុសហគមន៍តាមប្រព័ន្ធឌីជីថល។ ជាលទ្ធផល ៧៩% (៧៤ ក្នុងចំណោម ៩៤ បញ្ហា ឬសកម្មភាព) នៅក្នុងផែនការសកម្មភាពរួមគណនេយ្យភាពសង្គម (JAAP) ក្នុងឆ្នាំ២០២២ ត្រូវបានអនុវត្តន៍នៅឆ្នាំ២០២៣ ដោយសង្កាត់ចំនួន ៣ ដូចជា សង្កាត់អូរបែកក្អម សង្កាត់ក្រាំងធ្នង់ សង្កាត់ភ្នំពេញថ្មី និងខណ្ឌសែនសុខ។

**តារាង JAAP បានឆ្លើយតប៖**

| ឆ្នាំ | សកម្មភាពរបស់ JAAP | JAAP បានឆ្លើយតប |
|---|---|---|
| ២០២២ | ៩៤ សកម្មភាព | សកម្មភាពចំនួន ៧៤ បានទទួលការឆ្លើយតប និងត្រូវបានអនុវត្តនៅឆ្នាំ២០២៣ |
| ២០២៣ | ២៣៦ សកម្មភាព | ដើម្បីតាមដានលទ្ធផលនៅឆ្នាំ២០២៤ |

- អ្នកចូលរួមសរុបចំនួន ៥០ នាក់ (ស្រី ២៥ នាក់) មកពីផ្នែកផ្គត់ផ្គង់ និងផ្នែកតម្រូវការស្មើនឹង ១០០% បើធៀបនឹងអ្នកចូលរួមចំនួន ៥០ នាក់ ដែលបានគ្រោងទុកសម្រាប់រយៈពេល ២១ខែ។ ជាលទ្ធផល អ្នកចូលរួមបានបង្កើនសមត្ថភាពរបស់ខ្លួនចំនួន ៦៣% លើគោលគំនិតនៃកិច្ចការពារសង្គម គណនេយ្យភាពសង្គមក្នុងគ្រប់វដ្តនៃសកម្មភាព ISAF នៃផ្នែកតម្រូវការ និងផ្នែកផ្គត់ផ្គង់ ផែនការ យុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជា (RGC) ISAF គោលគំនិតនៃការស្វែងរកមតិគាំទ្រ ឬការតស៊ូមតិ ជំនាញសម្របសម្រួល និងជំនាញទន់ផ្សេងៗទៀត។

**តារាង៖ ការធ្វើតេស្តមុន និងក្រោយនៃវគ្គបណ្តុះបណ្តាលក្នុងឆ្នាំ២០២២ - ២០២៣**

| ការបណ្តុះបណ្តាល | ការធ្វើតេស្តជាមុន | ការធ្វើតេស្តក្រោយ | លទ្ធផល |
|---|---|---|---|
| ការផ្តល់វគ្គបណ្តុះបណ្តាលសម្រាប់អ្នក តំណាងមកពីផ្នែកតម្រូវការ (ដៃគូអង្គការមិនមែនរដ្ឋាភិបាល និង CAFs) ឆ្នាំ២០២២ | ២១% | ៩២% | ៧១% |
| ការផ្តល់វគ្គបណ្តុះបណ្តាលសម្រាប់អ្នក តំណាងមកពីផ្នែកតម្រូវការ (ដៃគូអង្គការមិនមែនរដ្ឋាភិបាល និងCAFs) ឆ្នាំ២០២៣ | ៣៨,៥% | ៩៧% | ៥៨.៥% |
| ការផ្តល់វគ្គបណ្តុះបណ្តាលសម្រាប់អ្នកតំណាងមកពីផ្នែកផ្គត់ផ្គង់(ខណ្ឌ សង្កាត់ មណ្ឌលសុខភាព សាលាបឋមសិក្សា) ២០២២ | ២៦% | ៨៦% | ៦០% |
| **មធ្យម** | **២៨,៥%** | **៩១,៥%** | **៦៣%** |

- អ្នកចូលរួមសរុបចំនួន ៥០ នាក់ (ស្រី ២៥ នាក់) មកពីផ្នែកផ្គត់ផ្គង់ និងផ្នែកតម្រូវការស្មើនឹង ១០០% បើធៀបនឹងអ្នកចូលរួមចំនួន ៥០ នាក់ ដែលបានគ្រោងទុកសម្រាប់រយៈពេល ២១ខែ។ ជាលទ្ធផល អ្នកចូលរួមបានបង្កើនសមត្ថភាពរបស់ខ្លួនចំនួន ៦៣% លើគោលគំនិតនៃកិច្ចការពារសង្គម គណនេយ្យភាពសង្គមក្នុងគ្រប់វដ្តនៃសកម្មភាព ISAF នៃផ្នែកតម្រូវការ និងផ្នែកផ្គត់ផ្គង់ ផែនការ យុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជា (RGC) ISAF គោលគំនិតនៃការស្វែងរកមតិគាំទ្រ ឬការតស៊ូមតិ ជំនាញសម្របសម្រួល និងជំនាញទន់ផ្សេងៗទៀត។

**តារាងសកម្មភាព**

| ក្រមច្បាប់ | សកម្មភាព | បុរស | ស្រី | សរុប | ចំនួនប្រជុំ |
|---|---|---|---|---|---|
| ១.១ | កំណត់អត្តសញ្ញាណ និងការកៀរគរ សមាជិកថ្មី នៃជនមានពិការភាព មនុស្ស វ័យចាស់ | ២៩៣ | ៣៦៣ | ៦៥៦ | ២០ដង |
| ១.២ | ការកសាងសមត្ថភាពសម្រាប់ផ្នែកតម្រូវការ និងផ្នែកផ្គត់ផ្គង់ | ២៥ | ២៥ | ៥០ | ០៦ដង |
| ១.៣ | លើកកម្ពស់ការយល់ដឹង និងការពង្រឹង អំណាច ឬការផ្សព្វផ្សាយកញ្ចប់ព័ត៌មាន (I4C) | ៣០៤ | ៤២៣ | ៧២៧ | ១២ដង |
| ២.១.១ | ការដាក់ពិន្ទុសហគមន៍សម្រាប់ប្រជាពលរដ្ឋតាមប្រព័ន្ធដាក់ពិន្ទុឌីជីថល | ២៤៩ | ៣០១ | ៥៥០ | ៣២ដង |
| ២.១.២ | ការប៉ាន់ប្រមាណលើការបំពេញការងារខ្លួនឯង ដោយអ្នកផ្តល់សេវា | ២៤០ | ៣០០ | ៥៤០ | ៣២ដង |
| ២.២ | ការប្រជុំរួម (តាមវិស័យ និងពហុវិស័យ) | ១៨៦ | ១៥០ | ៣៣៦ | ១២ដង |
| ២.៣.៤ | ការសម្តែងរបស់ Epic Arts និង MAPD | ៣០៨ | ៥៩៩ | ៩០៧ | ១៣ ការសម្តែង |

| | | | | | |
|---|---|---|---|---|---|
| ១.៤ | ផលិតវីដេអូអំពីការអនុវត្តគម្រោងដោយជោគជ័យ | | | | ០២វីដេអូ |
| ១.៤ | ការសរសេរករណីសិក្សាអំពីគម្រោង | | | | ១៤ករណី |
| ២.៣.២ | វេទិកាសាធារណៈ | ៣៥៨ | ៤១៨ | ៧៧៦ | ១២ដង |

- ការពិគ្រោះយោបល់លើគោលការណ៍ណែនាំបច្ចេកទេស ស្តីពី ការបញ្ជ្រាបកិច្ចគាំពារសង្គម នៅក្នុង ISAF ត្រូវបានអនុវត្តទទួលបានធាតុចូល និងការធ្វើបច្ចុប្បន្នភាពពីភាគីពាក់ព័ន្ធ និងរដ្ឋាភិបាល។
- Epic Arts បានអនុវត្តសកម្មភាពទាំងអស់របស់ខ្លួន ហើយអ្នកផ្តល់សេវា ដឹងអំពីតម្រូវការរបស់ ជនមានពិការភាព និងផ្តល់អាទិភាពដល់ពួកគេ។ MAPD បានបញ្ចប់ការសម្តែង ឬច្រៀងដើម្បី ស្វែងរកមតិគាំទ្រ ឬការតស៊ូមតិចំនួន ០២ នៃការសម្តែង។ អង្គការ API បានធ្វើបច្ចុប្បន្នភាព និងរចនា គោលការណ៍ណែនាំបច្ចេកទេសសម្រាប់កិច្ចការពារសង្គមក្នុងក្របខ័ណ្ឌគណនេយ្យភាពសង្គម។
- CAFs ចំនួន ១៤ នាក់ក្នុងចំណោម ២៦ នាក់បានកសាងសមត្ថភាពដើម្បីជួយសម្របសម្រួលដល់ការ ផ្សព្វផ្សាយកញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ (I4C) និងចូលរួមកិច្ចប្រជុំប្រកបដោយទំនុកចិត្ត។ អ្នកផ្តល់សេវាសង្កាត់ទាំង ០៦ បានផ្តល់សេវាជូនប្រជាពលរដ្ឋប្រកបដោយភាពរួសរាយរាក់ទាក់ ទាន់ពេលវេលា គណនេយ្យភាព និងតម្លាភាព ចាប់តាំងពីចុងឆ្នាំ២០២២ មកក្នុង រដ្ឋបាលខណ្ឌ និងសង្កាត់ទាំង ០៦។ នៅរដ្ឋបាលសង្កាត់ក្រាំងធ្នង់បានសាងសង់ផ្លូវជម្រាលសម្រាប់ ជនមានពិការភាព ដើម្បីឱ្យមានភាពងាយស្រួលក្នុងការទៅទទួលសេវាសាធារណៈនៅឆ្នាំ២០២៣។
- តាមរយៈសកម្មភាពគម្រោងស្តីពីការផ្សព្វផ្សាយសេវាសាធារណៈ និងការយល់ដឹងនៅក្នុងសង្កាត់ គោលដៅចំនួន ០៦ ជនមានពិការភាពចំនួន ២៥៩នាក់ ដែលជាសមាជិករបស់ មជ្ឈមណ្ឌលជីវិត រស់នៅដោយឯករាជ្យនៃជនពិការភ្នំពេញ (PPCIL) និងសមាគមតន្ត្រីសំនៀងជនពិការ (MAPD) បានធ្វើការតស៊ូមតិ និងទទួលបានប័ណ្ណអត្តសញ្ញាណកម្មជន មានពិការភាពពីក្រសួងសង្គមកិច្ច ក្នុងឆ្នាំ២០២៣។
- គោលការណ៍ណែនាំបច្ចេកទេសស្តីពីកិច្ចគាំពារសង្គមក្នុងក្របខណ្ឌគណនេយ្យភាពសង្គម (ISAF) ត្រូវបានព្រាងពិភាក្សាជាមួយភាគីពាក់ព័ន្ធរបស់រដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល។ អង្គការ API នឹងបន្តតស៊ូមតិជាមួយរដ្ឋាភិបាលដើម្បីគាំទ្រគោលការណ៍ណែនាំបច្ចេកទេសនេះដើម្បីប្រើប្រាស់ ដោយអង្គភាពផ្សេងៗ។

## មេរៀនដែលបានរៀន៖





ក្រុមការងារគម្រោងបានទទួលសំណួរជាច្រើនពីអ្នកចូលរួមហើយធ្វើការពិគ្រោះពិភាក្សានិងចងក្រងជាឯកសារនៅក្នុងកិច្ចប្រជុំឆ្លុះបញ្ចាំងជាមួយអាជ្ញាធរ CBOs និង ដៃគូអង្គការក្រៅរដ្ឋាភិបាល ដែលមាន សមាគមមនុស្ស វ័យចាស់ Epict Arts MAPD PPCIL។ ឧទាហរណ៍មួយចំនួន៖

១ តើស្ត្រី និងបុរស មកពីក្រុមដែលងាយរងគ្រោះអាចប្រើប្រាស់បានល្អបំផុតនូវយន្តការ ចូលរួម ក្នុងថ្នាក់ តំបន់ដូចជា ISAF សម្រាប់កិច្ចគាំពារសង្គមយ៉ាងដូចម្តេចដើម្បីសម្រេចបានលទ្ធផលវិជ្ជមាន សម្រាប់ជីវិត និងជីវភាពរស់នៅរបស់ពួកគេជាពិសេសសម្រាប់អ្នកដែលរងផលប៉ះពាល់ ជាអវិជ្ជមាន ដោយជំងឺរាតត្បាតកូវីដ-១៩? តើពួកគេត្រូវជម្នះឧបសគ្គអ្វីខ្លះ ដើម្បីធ្វើឱ្យសំឡេងរបស់ ពួកគេឮខ្លាំង នៅក្នុងយន្តការចូលរួមក្នុងតំបន់ ដូចជា ISAF សម្រាប់កិច្ចគាំពារសង្គម?

**កិច្ចប្រជុំឆ្លុះបញ្ចាំងពីការចូលរួមបានឆ្លើយតបជាមួយនឹងចំណុចខាងក្រោមសម្រាប់សកម្មភាព៖**

- អនុវត្តយុទ្ធនាការយល់ដឹងពីកញ្ចប់ព័ត៌មាន I4C យន្តការនៃវេទិកាសាធារណៈ និងសកម្មភាព បន្ថែមនៃការដាក់ពិន្ទុសហគមន៍សម្រាប់ប្រជាពលរដ្ឋតាមប្រព័ន្ធដាក់ពិន្ទុឌីជីថល តាមរយៈដោយផ្ទាល់មុខ និងធានាបានថាអ្នកដែលទទួលរងពីជំងឺធ្ងន់ធ្ងរ ឬពិការភាពធ្ងន់ធ្ងរក៏អាចចូលរួមទទួលបាន ព័ត៌មាន និងលើកឡើងអំពីបញ្ហារបស់ពួកគេ។
- ការកៀរគរ និងផ្តល់ឱកាសសម្រាប់អ្នកទទួលផលជាស្ត្រី និងបុរសដើម្បីចូលរួមក្នុងសកម្មភាព ពាក់ព័ន្ធ ដើម្បីលើកឡើងពីបញ្ហា និងតម្រូវការរបស់ពួកគេទៅក្នុងក្របខ័ណ្ឌគណនេយ្យភាពសង្គម។
- តំណាងស្ត្រី និងបុរសក្លាយជាសមាជិកនៃគណៈកម្មាធិការផែនការរួមគណនេយ្យភាពសង្គម។
- តំណាងស្ត្រី និងបុរសចូលរួមកិច្ចប្រជុំជាមួយគណៈកម្មាធិការផែនការរួមគណនេយ្យភាពសង្គម និងកិច្ចប្រជុំប្រចាំខែជាមួយរដ្ឋបាលសង្កាត់ និងខណ្ឌ។

២ តើយើងអាចគាំទ្រស្ត្រីមកពីក្រុមដែលងាយរងគ្រោះផ្សេងៗគ្នា ក្នុងការបញ្ចេញសំឡេងរបស់ពួកគេ ដោយរបៀបណា ដោយមិនដកក្រុមបុរសចេញពីក្រុមទាំងនេះ?

- ការយល់ដឹងអំពីកញ្ចប់ព័ត៌មាន I4C និងយន្តការនៃវេទិកាសាធារណៈគឺជាកន្លែងដ៏មានប្រសិទ្ធភាព សម្រាប់ស្ត្រីបង្កើនសំឡេងរបស់ពួកគេ។
- ពង្រឹងសមត្ថភាព និងផ្តល់ព័ត៌មានដល់ពួកគេដើម្បីមានទំនុកចិត្តក្នុងការលើកបញ្ហា ឬតម្រូវការ ក្នុងសកម្មភាពផ្សេងៗពីមូលដ្ឋានដល់ថ្នាក់ជាតិ។
- បង្ហឹកពួកគេឱ្យចេះប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គម ដើម្បីផ្សព្វផ្សាយបញ្ហា ឬតម្រូវការនៅលើ ប្រព័ន្ធផ្សព្វផ្សាយ ឬបណ្តាញសង្គម។

៣ តើយើងអាចសម្រេចបាននូវភាពបើកចំហ និងការឆ្លើយតបដ៏ល្អដោយអ្នកផ្តល់សេវា និងក្រុមប្រឹក្សា មូលដ្ឋានដើម្បីផ្តល់មតិកែលម្អ និងការបញ្ចេញសំឡេងកាន់តែខ្លាំងដល់ស្ត្រី និងបុរសពីក្រុមគោលដៅ ដែលងាយរងគ្រោះដោយរបៀបណា?

- សហការជាមួយ NCDD ដើម្បីផ្តល់វគ្គបណ្តុះបណ្តាលស្តីពីកិច្ចគាំពារសង្គម និងISAF ដល់អ្នក ផ្តល់សេវា។
- រៀបចំការប្រជុំឆ្លុះបញ្ចាំងប្រចាំត្រីមាសជាមួយអ្នកផ្តល់សេវា និងអ្នកទទួលសេវា។
- ដឹកនាំកិច្ចប្រជុំត្រួតពិនិត្យ និងតាមដាន JAAP នៅក្នុងកិច្ចប្រជុំប្រចាំខែរបស់រដ្ឋបាលសង្កាត់ និងខណ្ឌ។
- រៀបចំវេទិកាសាធារណៈ។
- ផ្សព្វផ្សាយព័ត៌មានអំពីយន្តការនៃការិយាល័យប្រជាពលរដ្ឋ តួនាទី និងការទទួលខុសត្រូវ។

៤ តើការផ្តល់សេវាទាក់ទងនឹងកិច្ចគាំពារសង្គមដល់ក្រុមគោលដៅរបស់យើងពិតជាមានភាព ប្រសើរឡើងតាមរយៈសំឡេងកាន់តែខ្លាំងរបស់ស្ត្រី និងបុរសដែលងាយរងគ្រោះ និងការសន្ទនាក្នុងន័យស្ថាបនានៅក្នុងយន្តការ ISAF ដែលបានធ្វើបច្ចុប្បន្នភាពដែលបានសាកល្បងដែរឬទេ? **ក).** ប្រសិន បើបាទ ឬចាស តើអ្វីដែលអាចធ្វើ បានប្រសើរជាងក្នុងគំនិតដើមរបស់យើងហើយរួមបញ្ចូលនៅក្នុងឯកសារណែនាំស្តីពីកិច្ចគាំពារសង្គម ISAF ដែលបានធ្វើបច្ចុប្បន្នភាពនៅចុងបញ្ចប់នៃគម្រោង? **ខ).** បើមិនមានហេតុអ្វី? តើមានហេតុផលអ្វីខ្លះ? តើមេរៀនអ្វីខ្លះ?

- បាទ! ការផ្តល់សេវាទាក់ទងនឹងកិច្ចគាំពារសង្គមដល់ក្រុមគោលដៅរបស់យើងពិតជាមានភាព ប្រសើរ ឡើងសម្រាប់ស្ត្រី និងបុរសដែលងាយរងគ្រោះនៅក្នុងតំបន់គោលដៅ។
- ការណែនាំអំពីកិច្ចគាំពារសង្គមរបស់ ISAF គួរតែកែលម្អលើកិច្ចសហប្រតិបត្តិការជាមួយ NCDD ដើម្បីបង្កើតគណៈកម្មាធិការកិច្ចគាំពារសង្គមថ្នាក់ក្រោមជាតិ រហូតដល់ថ្នាក់ជាតិ។ ជាងនេះ ទៅ ទៀតជំរុញឱ្យសាលារាជធានី ខណ្ឌ និងសង្កាត់ បែងចែកថវិកាដើម្បីអនុវត្ត ISAF ផងដែរ។
- គោលការណ៍ណែនាំបច្ចេកទេសស្តីពីកិច្ចគាំពារសង្គមនៅក្នុង ISAF គួរតែត្រូវបានពិគ្រោះជា មួយក្រសួងពាក់ព័ន្ធរបស់រដ្ឋាភិបាលអង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍ ដើម្បីអនុវត្តគម្រោង នេះដោយផ្អែកលើការអនុវត្តល្អនៅក្នុងតំបន់គោលដៅផ្សេងទៀត។

៥ តើយើងអាចប្រើប្រាស់ឧបករណ៍ឌីជីថល និងធនធានអនឡាញប្រកបដោយប្រសិទ្ធភាពក្នុង ការងាររបស់ យើងជាមួយក្រុមគោលដៅដែលងាយរងគ្រោះដោយរបៀបណា?

- ធានានូវមតិកែលម្អឯករាជ្យនិងសម្ងាត់ចំពោះសកម្មភាពដែលបានស្នើឡើងតាមរយៈការដាក់ពិន្ទុសហគមន៍សម្រាប់ប្រជាពលរដ្ឋតាមប្រព័ន្ធដាក់ពិន្ទុឌីជីថល និងJAAP។
- បង្កើតវីដេអូអប់រំដើម្បីបង្ហាញអំពីបទពិសោធន៍ និងករណីសិក្សា។
- បង្កើតវីដេអូអប់រំដើម្បីប្រកួតប្រជែងយករង្វាន់។
- សារអប់រំពីក្រុមល្បីៗ ឬបុគ្គលដែលមានសមត្ថភាព និងមានឥទ្ធិពលលើសាធារណជន។
- បង្កើតក្រុមគាំទ្រ។

៦ តើវិធីណានៃការអនុវត្តគណនេយ្យភាពសង្គមដែលល្អបំផុតដើម្បីកែលម្អការផ្តល់សេវាគាំពារសង្គម សម្រាប់ ប្រជាពលរដ្ឋដែលងាយរងគ្រោះក្នុងកម្រិតកាន់តែទូលំទូលាយ? ក) ការបញ្ច្រាបមតិកែលម្អ សេវា គាំពារសង្គម ទៅជាស្តង់ដារ ISAF ឬ ខ) ការធ្វើឱ្យស៊ីជម្រៅនូវសេវាកិច្ចគាំពារសង្គម ISAF ជាក់លាក់តាមវិស័យ ដែលអាច ត្រូវបានពង្រីកដល់កម្រិតខណ្ឌ នៅពេលដែលសេវាថ្មីត្រូវបានណែនាំ ហើយដែលផ្តោតលើស្ត្រី និងបុរស ពីក្រុមងាយរងគ្រោះតែប៉ុណ្ណោះ?

- ជ្រើសរើស ខ) ធ្វើឱ្យស៊ីជម្រៅនូវកិច្ចគាំពារសង្គម I-SAF ជាក់លាក់តាមវិស័យដែលអាចត្រូវបានពង្រីកទៅកម្រិតខណ្ឌ នៅពេលដែលសេវាថ្មីត្រូវបានណែនាំហើយដែលផ្តោតលើស្ត្រី និងបុរសពីក្រុមងាយរងគ្រោះតែប៉ុណ្ណោះ។

***ករណីសិក្សាទី១៖*** មើលឃើញសមត្ថភាពជាជាងពិការភាព



**ណារី** និងក្រុមការងារណែនាំខ្លួនមុនចាប់ផ្តើមធ្វើបទបង្ហាញលទ្ធផលពិភាក្សាក្រុម (នៅខាងស្តាំពាក់ម៉ាស និងអាវពណ៌ផ្ទៃមេឃ)។

កំពុងអង្គុយធ្វើជាវាគ្មិនបកស្រាយពីបញ្ហាប្រឈម និងតម្រូវការរបស់ជនមានពិការភាពនៅចំពោះមុខ ជនទាន់ជនក្នុងវេទិកាប្រជាពលរដ្ឋ។ **ណារី** អាយុ ៣៧ឆ្នាំ ជាស្ត្រីមានពិការភាពភ្នែកពីកំណើត (កំសោយគំហើញកម្រិតធ្ងន់) និងមានទីលំនៅបច្ចុប្បន្ននៅ សមាគមតន្ត្រីសំនៀងជនពិការ ក្នុងភូមិជម្រៅ សង្កាត់គោករកា ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ។ មុនពេលធ្វើជាអ្នកសម្របសម្រួល គណនេយ្យភាពសហគមន៍ "ខ្ញុំមិនដឹងទៅនិយាយប្រាប់អ្នកណាឱ្យគេយល់ពីបញ្ហា និងតម្រូវការរបស់ជនមាន ពិការភាពឡើយ។ ពិសេសមនុស្សភាគច្រើន យល់ថាជនមានពិការភាពដូចខ្ញុំធ្វើអ្វីមិនកើតទេហើយ ខ្ញុំខ្លួនឯង ក៏ហាក់ដូចជា អស់សង្ឃឹមចំពោះខ្លួនឯងផងដែរព្រោះខ្ញុំមិនដឹងថាត្រូវធ្វើអ្វីដើម្បីទទួលបានការគោរព និងការឱ្យតម្លៃ ពីសង្គម"។ **ណារី** បានបញ្ជាក់ថា "កាលពីមុនខ្ញុំមិនធ្លាប់បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពី ការអនុវត្ត កិច្ចគាំពារសង្គមក្នុងគណនេយ្យភាពសង្គមទេ ហើយក៏មិនដឹងថាវាមានអត្ថន័យដូចម្តេចដែរ។ ខ្ញុំភ័យផង អរផងពេលខ្ញុំស្ម័គ្រចិត្តធ្វើជាអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ ព្រោះខ្ញុំមិនដឹងថា ខ្ញុំត្រូវធ្វើអ្វីខ្លះ នោះទេ។ ពិសេស ខ្ញុំមិនដឹងថាការងារគណនេយ្យភាពសង្គមក្នុងកិច្ចគាំពារសង្គមនេះគេធ្វើទៅ លើអ្វីជាមួយ អ្នកណា"។ ដោយសារមានការសហការ និងការស្ម័គ្រចិត្តធ្វើជាអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ ជាមួយអង្គការវិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយតាមរយៈគម្រោងវ៉យ (Voice) ខ្ញុំត្រូវបានអញ្ជើញ ឱ្យចូលរួមវគ្គបណ្តុះបណ្តាល សិក្ខាសាលាជាមួយអង្គការជាមួយមន្ត្រីរដ្ឋាភិបាល និងកិច្ចប្រជុំផ្សេងៗ ជាច្រើន។ ជាពិសេស អង្គការ API បានកសាងសមត្ថភាពនាងខ្ញុំឱ្យយល់ដឹងពីការអនុវត្តគណនេយ្យភាពសង្គម ក្នុងកិច្ចគាំពារសង្គមសិទ្ធិប្រជាពលរដ្ឋក្នុងការទទួលបានសេវាសាធារណៈការបំពេញការងាររបស់អ្នកផ្តល់សេវា ដល់ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធផ្សេងៗក្នុងការ អនុវត្តគណនេយ្យភាពសង្គមក្នុងកិច្ចគាំពារសង្គម ពិសេស ជនមានពិការភាព និងមនុស្សចាស់។ ការចូលរួមជាមួយអង្គការវិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ ធ្វើឱ្យនាងខ្ញុំយល់ដឹងច្រើន និងអាចយកចំណេះដឹងទាំងនេះទៅផ្សព្វផ្សាយបន្ត ដល់សមាជិកសមាគមដែលមានពិការភាពនៅ សមាគមន៍តន្ត្រីសំនៀងជនពិការចំនួន ៦០នាក់ ដើម្បីឱ្យពួកគាត់បានយល់ដឹងពីសិទ្ធិ និងសេវាដែលគាត់ត្រូវទទួលបានពីរដ្ឋបាលថ្នាក់ក្រោមជាតិ ប្រកបដោយប្រសិទ្ធិភាព។ ណារី បញ្ជាក់ថា "សព្វថ្ងៃខ្ញុំរស់នៅដោយសេចក្តី សង្ឃឹមច្រើនជាងមុន ដោយសារខ្ញុំទទួលបានការគោរពការផ្តល់តម្លៃច្រើនជាងមុន និងបានចូលរួមសកម្មភាពសង្គម ដើម្បីលើកកម្ពស់សេចក្តីថ្លៃថ្នូររបស់មនុស្សទូទៅក្នុងនោះមានជនមានពិការ ភាពផងដែរ ក្នុងការទទួលបានសេវាគាំពារសង្គម"។ លោក ចាប តូ ប្រធានសមាគមន៍

សំនៀងតន្ត្រីជនពិការ បន្ថែមថា **“ណារី មានការយល់ដឹងពីគណនេយ្យភាពសង្គមកិច្ចគាំពារសង្គម និងក្លាហានច្រើនក្នុងការនិយាយសាធារណៈ និងផ្សព្វផ្សាយព័ត៌មានផ្សេងៗដល់សមាជិកសមាគម”។**



**ណារី** ធ្វើវាគ្មិននៅក្នុងកម្មវិធី វេទិការប្រជាពលរដ្ឋហើយគាត់បកស្រាយពីបញ្ហា តម្រូវ និងផ្តល់អនុសាសន៍ជូនរដ្ឋាភិបាល (នៅខាងឆ្វេងហើយកាន់ក្បាលមេក្រូ)។

នាងខ្ញុំសូមសម្តែងនូវសេចក្តីរីករាយយ៉ាងខ្លាំងដែលនាងខ្ញុំជាជនមានពិការភាពភ្នែកម្នាក់តែមានឱកាសបានចូលរួមចំណែកជួយដល់ការងារសង្គម ក៏ដូចជាការ លើកស្ទួយសិទ្ធិ និងការយល់ដឹងពីការប្រើប្រាស់សេវា សាធារណៈ ពិសេស ប្រជាពលរដ្ឋក្រីក្រ និងងាយរងគ្រោះ ដូចជាជនមានពិការភាពជាដើមឱ្យកាន់តែយល់ច្បាស់ និងហ៊ានបញ្ចេញមតិលើកជាសំណើរផ្សេងៗដែលជា តម្រូវការ របស់ពួកគាត់ដើម្បីសុំអន្តរាគមន៍ពីរដ្ឋាភិបាល ក៏ដូចជាអ្នកផ្តល់សេវានានានៅថ្នាក់មូលដ្ឋាន។

> “ **ណារី** បានបន្ថែមទៀតថា “ខ្ញុំប្តេជ្ញាថានៅតែបន្តសហការ ចូលរួមធ្វើការងារស្ម័គ្រចិត្តដើម្បីលើកកម្ពស់ជីវភាព សិទ្ធិ តម្លាភាព និងនិរន្តរភាព ក្នុងភាពថ្លៃថ្នូរដល់ប្រជាពលរដ្ឋទូទៅ ក្នុងនោះមានជនមានពិការភាព គ្រួសារក្រីក្រ មនុស្សចាស់ជរានិងជនងាយរងគ្រោះផ្សេងៗទៀត ឱ្យចូលរួមក្នុងសកម្មការងារគម្រោងកាន់តែប្រសើរឡើង តាមរយៈការអនុវត្តការងារគណនេយ្យភាពសង្គមក្នុងកិច្ចគាំពារសង្គមជាមួយអង្គការវិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ”។ ”

**ករណីសិក្សាទី២៖ រុំ សុខជា** អាយុ ២០ឆ្នាំ ជានិស្សិតផ្នែករដ្ឋបាលសាធារណៈឆ្នាំទី២ នៃសកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច (RULE)។ នាងរស់នៅភូមិសែនសុខ២ សង្កាត់ ឃ្មួញ ខណ្ឌសែនសុខ និងជាសមាជិកក្រុមយុវជន ម្នាក់ ដែលបានស្ម័គ្រចិត្តនៅក្នុងខណ្ឌ សែនសុខ។ មុនពេលនាងចូលរួមក្នុងវគ្គ បណ្តុះបណ្តាល នាងជាក្មេងស្រីដែលខ្មាសអៀន និងមិនចេះប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាពជាមួយអ្នកដទៃនោះទេ ជាពិសេសជាមួយមនុស្ស ចម្លែក ហើយនាងក៏ពុំមានទំនុកចិត្ត ក្នុងការនិយាយជាសាធារណៈ។ លើសពីនេះ នាងមិនបានយល់ ឬមានចំណេះដឹង ណាមួយអំពី ISAF ទាក់ទងនឹងកិច្ចគាំពារសង្គមដែរ។ ថ្ងៃមួយនាង បានឃើញការប្រកាសជ្រើសរើសអ្នកសម្រប សម្រួលគណនេយ្យភាពសហគមន៍ដើម្បី គាំទ្រការអនុវត្តន៍គម្រោងនៅខណ្ឌសែនសុខ។ នាងបាននិយាយថា៖ “ខ្ញុំគិតថាវាបំពេញ តាមគោលដៅរបស់ខ្ញុំក្នុងការបម្រើដល់ក្រុម ងាយរងគ្រោះក្នុង សហគមន៍របស់ខ្ញុំ”។ នៅពេលខ្ញុំក្លាយជាអ្នកសម្របសម្រួល គណនេយ្យភាពសហគមន៍ (CAF) ខ្ញុំត្រូវ បានណែនាំជាលើកដំបូង ទៅកាន់គម្រោង។ សំខាន់ខ្ញុំនិង CAFs ផ្សេងទៀតត្រូវបានបណ្តុះបណ្តាល និងបង្ហាត់បង្ហាញលើការអនុវត្តក្របខ័ណ្ឌគណនេយ្យភាពសង្គម និងកិច្ចការពារសង្គមទាំងនៅក្នុងកន្លែង បណ្តុះបណ្តាល និងតាមរយៈ ការងារអនុវត្តផ្ទាល់នៅតាមសហគមន៍។ ខ្ញុំមានឱកាសរៀនពីក្រុមការងារ និងបុគ្គលិកគម្រោងរបស់ខ្ញុំអំពីរបៀប នៃការសម្របសម្រួលកិច្ចប្រជុំផ្សព្វផ្សាយកញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ I4C និងអាជ្ញាធរមូលដ្ឋាន ជាអ្នកផ្តល់សេវា។ តាមរយៈវគ្គបណ្តុះបណ្តាលការបង្ហាត់បង្ហាញការអនុវត្តន៍ផ្ទាល់នៅសហគមន៍ និងការឆ្លុះ បញ្ចាំងជាច្រើន **រុំ សុខជា** មិនត្រឹមតែបានរៀនសូត្រច្រើន អំពីសកម្មភាពគម្រោងប៉ុណ្ណោះទេប៉ុន្តែថែមទាំងរក ឃើញការរីកចម្រើនខាងក្នុងផងដែរ។ សុខជា និយាយថា “ខ្ញុំជាអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ ដ៏រឹងមាំ ហើយខ្ញុំអាចគាំទ្រក្រុមរបស់ខ្ញុំឱ្យដំណើរការ សកម្មភាពគម្រោងដោយមានទំនុកចិត្តខ្ពស់”។





**សុខជា** បាននិយាយថាឥឡូវនេះនាង អាចជួយសម្របសម្រួលដល់ការផ្សព្វផ្សាយកញ្ចប់ I4C ការដាក់ពិន្ទុ សហគមន៍តាមប្រព័ន្ធឌីជីថលសម្របសម្រួលកិច្ចប្រជុំការ វាយតម្លៃលើការបំពេញការងារខ្លួនឯងរបស់អ្នកផ្តល់ សេវា និងចូលរួមជាមួយបុគ្គលិកគម្រោងដើម្បីជួយសម្រួលដល់កិច្ចប្រជុំរួមប្រកបដោយទំនុកចិត្ត។ នាងមាន ការយល់ដឹង និងអាចពន្យល់ និងផ្តល់សារច្បាស់លាស់ដល់អ្នកចូលរួមអំពីគោលគំនិតសំខាន់ៗនៃគោលគំនិត របស់ ISAF និងកញ្ចប់ព័ត៌មាន I4C ។ បន្ថែមលើនេះនាងបានចំណាយពេលវេលាដើម្បីគាំទ្រ CAFs ផ្សេងទៀត នៃគម្រោង

“សំឡេងពលរដ្ឋដើម្បីសេវាគាំពារសង្គមកាន់តែប្រសើរឡើងតាមរយៈការអនុវត្តផែនការគណនេយ្យ ភាពសង្គម” ដើម្បីជួយឱ្យដំណើរការនៃការអនុវត្ត ISAF ទៅដោយជោគជ័យ។ **ផូវ សោភ័ណ** មន្ត្រីគម្រោង នៃអង្គការ API បាននិយាយអំពី សុខជា ថា “នាងសកម្ម និងក្លាហាននៅពេលទំនាក់ទំនងជាមួយប្រជា ពលរដ្ឋ និងអាជ្ញាធរមូលដ្ឋាន។ ចាប់តាំងពីក្លាយជា CAF នាងមានភាពរីកចម្រើន និងមានការកើនឡើងនូវ សមត្ថភាពរបស់នាងយ៉ាងខ្លាំង ដោយនាងមានសមត្ថភាពក្នុងការសម្របសម្រួលនូវកិច្ចប្រជុំនានាប្រកបដោយ ទំនុកចិត្ត។

**រុំ សុខជា** មានបំណងប្រាថ្នាក្លាយជាអ្នកស្វែងរកមតិគាំទ្រ ឬតស៊ូមតិ និងអ្នកតំណាងរបស់ប្រជាពលរដ្ឋ ងាយរងគ្រោះ ដើម្បីនាំយកព័ត៌មាន និងយុត្តិធម៌សម្រាប់ក្រុមងាយរងគ្រោះ។ នាងចង់ឃើញសមាជិកទាំង អស់នៃសហគមន៍ក្រីក្ររបស់នាង ទទួលបានសេវាសាធារណៈប្រកបដោយគុណភាព តម្លាភាព និងគណនេយ្យភាព។

***ករណីសិក្សាទី៣៖*** ប័ណ្ណសមធម៌ជាជីវិត








លោក **គង់ ចិន្តា** អាយុ ៦៣ឆ្នាំ រស់នៅភូមិភ្នំពេញថ្មី សង្កាត់ភ្នំពេញថ្មី រាជធានីភ្នំពេញ មានភរិយា ឈ្មោះ **គឹម បុប្ផា** និងមានកូនបួននាក់ ស្រី ០៣នាក់ ប្រុស ០១នាក់។ សព្វថ្ងៃ គាត់មានមុខរបរជាមន្ត្រីប៉ូលីស ប្រពន្ធរបស់គាត់មានជំងឺប្រចាំ កាយ ហើយបានទៅសម្រាកព្យាបាលនៅមន្ទីរពេទ្យកាល់ម៉ែត្រ អស់រយៈពេល ១៧ថ្ងៃ ក្នុងមួយថ្ងៃ ត្រូវចំណាយលុយអស់ ៣៥០ ដុល្លារទៅ ៣៨០ ដុល្លារក្នុងមួយថ្ងៃ។ ក្នុងរយៈពេល ត្រឹមតែ ១៧ថ្ងៃ លោកត្រូវចំណាយលុយព្យាបាលប្រពន្ធអស់ ៤.០០០ ដុល្លារ។ បន្ទាប់មក ជំងឺប្រពន្ធរបស់គាត់ ឈានដល់ដំណាក់កាលនៃការលាងឈាមហើយត្រូវចំណាយលុយ ៩០០ ដុល្លារក្នុងមួយខែ (ចំណាយលើការលាងឈាម ៦០០ ដុល្លារ និងចំណាយទៅលើថ្លៃថ្នាំអស់ ២០០ ដុល្លារទៅ ៣០០ដុល្លារ)។ លោកបានបន្ត ជាមួយទឹកមុខស្រពោនថា គាត់អស់លទ្ធភាពទៅលើការចំណាយព្យាបាលប្រពន្ធបន្តទៀត ហើយអ្វីដែលអាច ធ្វើបាន គឺមានតែលក់ផ្ទះ និងរងចាំសេចក្តីស្លាប់តែប៉ុណ្ណោះ។ ដូច្នេះហើយគាត់ក៏សម្រេចចិត្តទៅស្នើសុំប័ណ្ណ សមធម៌ នៅសង្កាត់ ដែលគាត់កំពុងរស់នៅ ប៉ុន្តែ នៅពេលទៅដល់សង្កាត់ មន្ត្រីសង្កាត់បានប្រាប់ថា ទោះបីជា គាត់ទទួលបានប័ណ្ណសមធម៌ ក៏ពេទ្យមិនយកចិត្តទុកដាក់ក្នុងការមើលជំងឺគាត់ដែរ នេះមានន័យថាអាជ្ញាធរ មិនចង់ផ្តល់ប័ណ្ណឱ្យគាត់នោះទេ។ ប៉ុន្តែក្រោយមកខាងសមាគមមនុស្សចាស់ លោកពូ **ឈីវ ឡុញ** ដែលជាប្រធានសមាគមចាស់ជរាសង្កាត់ភ្នំពេញថ្មី ជាដៃគូរជាមួយអង្គការវិទ្យាស្ថានតស៊ូមតិ និងគោលន យោបាយ ក្រោមគម្រោង “សំឡេងពលរដ្ឋដើម្បីសេវាការពារសង្គមកាន់តែប្រសើរឡើង តាមរយៈការអនុវត្តផែនការគណនេយ្យភាពសង្គម” ដែលមានការគាំទ្រថវិកាដោយ វ៉យ តាមរយៈអង្គការអន្តរជាតិអុកស្វាមនៅកម្ពុជា និងបានចូលរួមវគ្គបណ្តុះបណ្តាលការបង្ហាត់បង្ហាញ កិច្ចប្រជុំនានារបស់អង្គការវិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ កន្លងមក លោក បានប្រើប្រាស់ចំណេះដឹង និងជំនាញរបស់លោក ក្នុងការតស៊ូមតិ និងពន្យល់ហេតុផលនានាចាប់តាំង ពីខែមិនា ដល់ខែឧសភា ឆ្នាំ២០២៣ ក្នុងកិច្ចប្រជុំប្រចាំ ខែរបស់សង្កាត់ និងជួបផ្ទាល់ដើម្បីស្នើសុំឱ្យអាជ្ញាធរ សង្កាត់ផ្តល់ប័ណ្ណសមធម៌

ជូនសមាជិករបស់គាត់ ជាលទ្ធផលខាងអាជ្ញាធរសង្កាត់ភ្នំពេញថ្មីបានផ្តល់ ប័ណ្ណសមធម៌ជូនគ្រួសារ លោកពូ **គង់ ចិន្តា** ដោយជោគជ័យ។

> “ តាំងពីពេលដែលគាត់ទទួលបានប័ណ្ណក្រីក្រនោះមក គឺគាត់ទទួលបានអត្ថប្រយោជន៍ច្រើន ដោយគាត់បានយកប្រពន្ធទៅព្យាបាលជំងឺដោយឥតគិតថ្លៃ ហើយនៅពេលដែលគាត់យកប្រពន្ធទៅព្យាបាលដោយប្រើប្រាស់ប័ណ្ណសមធម៌នោះ គឺគ្រូពេទ្យបានយកចិត្តទុកដាក់ក្នុងការថៃទាំព្យាបាលជំងឺប្រពន្ធរបស់គាត់ បានយ៉ាងល្អរាផ្ទុយស្រឡះពីអ្វីដែលមន្ត្រីសង្កាត់បានប្រាប់គាត់។ បន្ទាប់ពីគាត់មានប័ណ្ណសមធម៌មកគ្រួសារ របស់គាត់មានភាពធូរស្រាលច្រើន ដោយគាត់មិនចាំបាច់ត្រូវលក់ផ្ទះសម្បែង ដើម្បីព្យាបាលជំងឺប្រពន្ធរបស់គាត់នោះទេ ហើយថែមទាំងអាចប្រើប្រាស់ក្នុងការព្យាបាលជំងឺសមាជិកគ្រួសារផ្សេងទៀតនៅក្នុងបន្ទុកបាន ទៀតផង។ ”

លោកបានសម្តែងពីអារម្មណ៍របស់លោកថា៖ **ខ្ញុំមានអារម្មណ៍សប្បាយរីករាយត្រេកអរ និងអរគុណយ៉ាងខ្លាំងដល់សមាគមមនុស្សចាស់ និងអាជ្ញាធរសង្កាត់ភ្នំពេញថ្មីដែលបានជួយសម្របសម្រួលផ្តល់ប័ណ្ណ សមធម៌ជូនគ្រួសាររបស់គាត់ ដែលនេះមិនត្រឹមតែជួយសម្រួលក្នុងការព្យាបាលជំងឺប្រពន្ធគាត់ឱ្យបន្តជីវិតបាន នោះទេ តែថែមទាំងជួយដល់ជីវភាពគ្រួសាររបស់គាត់មួយកម្រិតធំផងដែរ។**

## គម្រោងទី១៩ កម្មវិធីពង្រឹងស្ត្រី និងយុវជនក្នុងភាពជាអ្នកដឹកនាំ

**គោលបំណងនៃគម្រោង៖** បង្កើនការចូលរួមរបស់ប្រជាពលរដ្ឋដើម្បីឱ្យមានតម្លាភាពថវិកាជាតិ និងគណនេយ្យភាពរបស់រដ្ឋាភិបាល។

**ដៃគូអនុវត្ត៖** អង្គការវិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ (API)

**ការផ្តល់មូលនិធិ៖** ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់កិច្ចអភិវឌ្ឍអន្តរជាតិ (USAID) ផ្តល់មូលនិធិតាមរយៈ អង្គការតម្លាភាពកម្ពុជា មានថវិកា ៦០,៥០០ ដុល្លារសហរដ្ឋអាមេរិក

**តំបន់គោលដៅ៖** រាជធានីភ្នំពេញ ខេត្តបាត់ដំបង និងខេត្តកំពត។





### លទ្ធផលរបស់គម្រោង៖

- ពង្រឹងការតស៊ូមតិសម្របសម្រួលលើការបង្កើតថវិកាសាធារណៈ និងការត្រួតពិនិត្យការចំណាយ។ បានចូលរួមក្នុងកិច្ចប្រជុំទៀងទាត់នៃក្រុមការងារថវិកាក្រុមការងារ សិទ្ធិទទួលព័ត៌មាន និងក្រុមការងារ អង្គការសង្គមស៊ីវិល ដើម្បីតាមដានដំណើរការថវិកាជាតិ។
- បានចូលរួមជាមួយក្រុមការងារសិទ្ធិទទួលព័ត៌មាន (A2IWG) និងភាគីពាក់ព័ន្ធដើម្បីជំរុញឱ្យមាន ការអនុម័តសេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន។ អង្គការ API ជាតំណាងក្រុមការងារ A2IWG បានដាក់លិខិតទៅក្រសួងព័ត៌មាន ដើម្បីស្នើសុំឱ្យមានការប្រជុំពិភាក្សាអំពីវឌ្ឍនភាពនៃសេចក្តីព្រាង ច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន។
- ការជជែកដេញដោលរបស់យុវជនបានរៀបចំចំនួន ពីរដង ស្តីពី សេរីភាពក្នុងការបញ្ចេញមតិ និងសារៈ សំខាន់នៃច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មានដែលមានយុវជនសរុបចំនួន ៣៧នាក់ (ស្រី ២៥នាក់)។

### សកម្មភាព៖

- អង្គការ API បានរៀបចំដឹកនាំកិច្ចប្រជុំប្រចាំខែជាមួយក្រុមការងារសិទ្ធិទទួលព័ត៌មាន និងក្រុមការងារថវិកាដើម្បីលើកកម្ពស់ការទទួលព័ត៌មាន និងធ្វើការតស៊ូមតិដើម្បីជំរុញឱ្យមានការអនុម័តច្បាប់ ស្តីពី សិទ្ធិទទួលព័ត៌មានក្នុងទិដ្ឋភាពនៃការពង្រីកលំហប្រជាធិបតេយ្យ និងការបង្កើនតម្លាភាព និងគណនេយ្យភាពនៅកម្ពុជា។ តស៊ូមតិជាមួយរដ្ឋាភិបាល កៀរគរភាគីពាក់ព័ន្ធ រៀបចំសិក្ខាសាលា ធ្វើសន្និសីទ និងលើកកម្ពស់ការយល់ដឹងអំពីសិទ្ធិទទួលព័ត៌មាន។
- ធាតុចូលរបស់អង្គការសង្គមស៊ីវិល លើសេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មានបានដាក់ជូន គណបក្សនយោបាយកំពូលទាំង ៥ ដែលចូលរួមក្នុងការបោះឆ្នោតជាតិឆ្នាំ២០២៣ ដើម្បីស្នើសុំការគាំទ្រដល់ធាតុចូលរបស់អង្គការសង្គមស៊ីវិល លើសេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មានឱ្យស្របតាមស្តង់ដារអន្តរជាតិ។
- សេចក្តីព្រាងលក្ខខណ្ឌ (TOR) របស់ក្រុមការងារសិទ្ធិទទួលព័ត៌មាន (A2IWG)៖ ដើមឡើយ A2IWG ត្រូវបានផ្តោតលើការជំរុញឱ្យមានការអនុម័តច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន ប៉ុន្តែ TOR របស់ A2IWG ចាំបាច់ត្រូវធ្វើបច្ចុប្បន្នភាពដើម្បីលើកកម្ពស់ការបង្ហាញព័ត៌មានសាធារណៈតាមវិស័យនីមួយៗដោយផ្អែកលើច្បាប់ ឬគោលនយោបាយដែលមានស្រាប់ ដែលផ្តល់ផលប្រយោជន៍ដល់ប្រជាពលរដ្ឋ និងធានានូវតម្លាភាព។ A2IWG មានបំណងដាក់បញ្ចូលអង្គការអន្តរជាតិ និងអង្គការសហគមន៍មូលដ្ឋានដោយរៀបចំកិច្ចពិភាក្សា និងប្រមូលធាតុចូលបន្ថែមពីក្រុមការងារ។

- សេចក្តីថ្លែងការណ៍ចំនួនពីរត្រូវបានរៀបចំសរសេរ និងបានផ្សព្វផ្សាយដល់សាធារណជន អំពីលទ្ធផល នៃសិក្ខាសាលាថ្នាក់ជាតិ និងស្នើសុំការប្តេជ្ញាចិត្តរបស់គណបក្សនយោបាយកំពូលទាំង ៥ ក្នុងការគាំទ្រ និងជំរុញឱ្យមានការអនុម័តច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មានឱ្យបានឆាប់រហ័ស។

- ពង្រឹងក្រុមការងារទាំង ៥ក្រុម (ក្រុមសិទ្ធិទទួលព័ត៌មានថវិកា កិច្ចការពារសង្គមឌីជីថល និងការប្រឆាំងអំពើពុករលួយ) ជាពិសេសសម្រាប់ការអនុវត្តសកម្មភាព និងយុទ្ធនាការផ្សេងៗ។

- បានសង្ខេបធាតុចូលពីសេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មានដល់គូអភិវឌ្ឍន៍ (DPs) ហើយបាន ស្នើសុំឱ្យពួកគេគាំទ្រចូលរួមសិក្ខាសាលា និងចូលរួមជាមួយរដ្ឋាភិបាលលើការអនុម័តសេចក្តីព្រាង ច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មានដែលស្របតាមស្តង់ដារអន្តរជាតិ និងការអនុវត្តល្អបំផុត។

- សមាជិក A2IWG និង CBOs បានបញ្ជូនធាតុចូលរបស់ពួកគេទៅតំណាងក្រសួងព័ត៌មាន។

- តំណាងក្រសួងព័ត៌មាន បានធ្វើបច្ចុប្បន្នភាពលើស្ថានភាពសេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន និងរៀបចំកិច្ចពិភាក្សាអំពីការផ្តល់ធាតុចូលនៅថ្នាក់ក្រសួង។

- បានរៀបចំទិវាអន្តរជាតិប្រចាំឆ្នាំស្តីពីសិទ្ធិទទួលព័ត៌មាននៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២៣។

- បានរៀបចំ និងដាក់បញ្ជូនរបាយការណ៍ UPR ស្តីពីបញ្ហាសិទ្ធិទទួលព័ត៌មាននៅកម្ពុជាទៅកាន់ អង្គការសហប្រជាជាតិ និងដៃគូអភិវឌ្ឍន៍ (សហភាពអឺរ៉ុប អង្គការសុខភាពគ្រួសារអន្តរជាតិ-360 កិច្ចសហប្រតិបត្តិការអាល្លឺម៉ង់ ស្ថានទូតអង់គ្លេស UNOCHR វិទ្យាស្ថានគ្រប់គ្រង បញ្ញើម-បូព៌ារ ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់កិច្ចអភិវឌ្ឍន៍អន្តរជាតិ) ដោយវិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ (API) និងសមាជិកក្រុមការងារសិទ្ធិទទួលព័ត៌មាន(A2IWG)។

- សមាជិក A2IWG បានទទួល ង្ខេបពីយុទ្ធសាស្ត្រ API ឆ្នាំ២០២៤ - ២០២៨ ដោយអ្នកប្រឹក្សារបស់ API លោក Ruud Corsel និងសមាជិក A2IWG និងA2IWG បានផ្តល់អនុសាសន៍មួយចំនួន សម្រាប់ផែនការយុទ្ធសាស្ត្ររបស់អង្គការ API។

- US Professional Fellows Program Visit៖ បានស្វែងយល់ពីស្ថានភាព និងការងាររបស់ក្រុមការងារ សិទ្ធិទទួលបានព័ត៌មាន។

- វេទិកាថ្នាក់ជាតិស្តីពីសេរីភាពបញ្ចេញមតិ និងសិទ្ធិទទួលព័ត៌មានដែលមានអ្នកចូលរួមសរុបចំនួន ២១៥នាក់ (ស្រី ១០៦នាក់) និងយុវជនសរុប ៧១នាក់ (ស្រី ៤៥នាក់)។ មានបទបង្ហាញអំពី ធាតុចូលរបស់អង្គការសង្គមស៊ីវិលលើសេចក្តីព្រាងច្បាប់ និងសារៈសំខាន់នៃច្បាប់ A2I លើគ្រប់វិស័យ ជាពិសេស សម្រាប់វិស័យសេដ្ឋកិច្ចសេរីភាពនៃការបញ្ចេញមតិ និងបច្ចេកវិទ្យា។ **ឯកឧត្តម គឹម គុណវឌ្ឍន៍** រដ្ឋលេខាធិការក្រសួងព័ត៌មាន និង **ឯកឧត្តម ព្រាប កុល** រដ្ឋមន្ត្រីប្រតិភូអមនាយក រដ្ឋមន្ត្រីបានប្តេជ្ញាចិត្តយ៉ាងមុតមាំ ដើម្បីជំរុញឱ្យមានការអនុម័តច្បាប់ ស្តីពី សិទ្ធិទទួលបានព័ត៌មានក្នុង ឱកាសប្រារព្ធទិវាអន្តរជាតិនៃសិទ្ធិទទួលបានព័ត៌មាននៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២៣ ។

- អង្គការ API បានរៀបចំ និងដឹកនាំការជជែកដេញដោលរបស់ក្រុមយុវជនចំនួន ពីរលើក ស្តីពីសេរីភាព បញ្ចេញមតិ និងសារៈសំខាន់នៃច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាននៅកម្ពុជាដែលមានយុវជនសរុបចំនួន ៧៦នាក់ (ស្រី ៤៩នាក់)។ ក្រុមយុវជនទីមួយៗបានសហការគ្នា និងធ្វើការ ស្រាវជ្រាយដើម្បីរកភស្តុតាងកមគាំទ្រអ្វីដែលពួកគេកំពុងជជែកដេញដោល និងដើម្បីធ្វើឱ្យគំនិតរបស់ពួកគេមានអំណះអំណាងគ្រប់គ្រាន់។ ការជជែកដេញដោលក្រុមយុវជនបានបញ្ចប់ ដោយលទ្ធផលប្រកបដោយផ្លែផ្កា ហើយក្រុមទីមួយៗមានអារម្មណ៍ពេញចិត្ត។ ពួកគេបានបង្ហាញពីស្នាមញញឹម និងអារម្មណ៍សប្បាយរីករាយហើយពួកគេចង់ឱ្យអង្គការ API នៅបន្តរៀបចំការជជែកដេញដោលសម្រាប់ក្រុមយុវជន។ ការជជែកដេញដោលរបស់យុវជនបានបង្កើនការយល់ដឹងអំពីឥទ្ធិពលវិជ្ជមានស្តីពី សិទ្ធិទទួលព័ត៌មានព្រោះជាគន្លឹះដ៏សំខាន់បំផុតមួយក្នុងការផ្តល់សិទ្ធិអំណាចដល់ស្ត្រី យុវជន ជាពិសេស ស្ត្រីវ័យក្មេងនៅ ក្នុងប្រទេសកម្ពុជា ដើម្បីរួមចំណែកប្រកបដោយប្រសិទ្ធភាពក្នុងការសន្ទនាដើម្បីកែលម្អការផ្តល់សេវាសាធារណៈ។

## មេរៀនដែលបានរៀន៖

- ការរួមបញ្ចូលគ្នាតែមួយ និងការសហការសម្រាប់កិច្ចប្រជុំក្រុមការងារអង្គការសង្គមស៊ីវិលចំនួន ៣ ជាប្រចាំខែ (ក្រុមការងារសិទ្ធិទទួលព័ត៌មាន ក្រុមការងារថវិកា និងក្រុមការងារប្រឆាំងអំពើពុករលួយ) នៅរៀងរាល់ថ្ងៃទី២២ នៃខែនីមួយៗមានការប្រជុំពិភាក្សារយៈពេល មួយម៉ោង ជាមួយដៃគូអភិវឌ្ឍន៍។
- ក្រុមការងារគ្រោងនឹងបង្កើនចំនួនការប្រជុំប្រចាំខែជាមួយក្រុមការងារសិទ្ធិទទួលព័ត៌មានតាមរយៈការចូលរួមចំណាយជាមួយអ្នកសម្របសម្រួលផ្សេងទៀតនៅក្នុងកិច្ចប្រជុំប្រចាំខែ។

## បញ្ហាប្រឈម៖

- ថវិកាមានកំណត់យើងបានដាក់កម្រិតលើការចូលរួមរបស់យុវជនក្នុងវគ្គបណ្តុះបណ្តាល និងការជជែក ពិភាក្សា។ ក្រុមការងារយុវជន និងមន្ត្រីក្រសួងមានការពិបាក ឬកាលវិភាគជាន់គ្នា។

## គម្រោងទី២០ គម្រោង សំឡេង និងសកម្មភាពរបស់ប្រជាពលរដ្ឋសម្រាប់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព នៅកម្ពុជា

**គោលបំណង៖** ដើម្បីបំពេញសិទ្ធិ និងលើកកម្ពស់សំឡេង និងសកម្មភាពរបស់ប្រជាពលរដ្ឋដើម្បីការអភិវឌ្ឍ ប្រកបដោយចីរភាពនៅកម្ពុជា។

**គាំទ្រដោយ៖** ១០៤.៧៤៧ ដុល្លារសហរដ្ឋអាមេរិក ផ្តល់មូលនិធិដោយជំនួយព្រះវិហារដាណឺម៉ាក(DCA)។

**តំបន់គោលដៅ៖** ខេត្តពោធិ៍សាត់ និងខេត្តបន្ទាយមានជ័យ។





### លទ្ធផល៖

- ពង្រឹងការចូលរួមរបស់ប្រជាពលរដ្ឋជាពិសេសស្ត្រី យុវជនជនមានពិការភាព និងប័ណ្ណសមធម៌ ក្នុងការធ្វើផែនការជាសាធារណៈ ការរៀបចំផែនការថវិកា និងជួយឱ្យអាជ្ញាធរមានភាពទទួលខុសត្រូវ លើការផ្តល់សេវា និងការអនុវត្តថវិកា។
- រដ្ឋបាលថ្នាក់ក្រោមជាតិបានឆ្លើយតបទៅនឹងបញ្ហាចម្បងរបស់សហគមន៍ដោយបានដោះស្រាយ៨៣% នៃករណីដែលលើកឡើងដោយអ្នកដឹកនាំសហគមន៍ជាស្ត្រី និងយុវជន ៣០នាក់មកពីសហគមន៍ចំនួន ១០។ ជាលទ្ធផល សកម្មភាពតស៊ូមតិរបស់សហគមន៍ ១០ ត្រូវបានអនុវត្តន៍ដើម្បីដោះស្រាយ នូវក្តីកង្វល់ និងតម្រូវការសហគមន៍របស់ពួកគេនៅក្នុងក្រុងស្រុកចំនួន ០៤។ សហគមន៍ ១០ (១០០%) បានបញ្ជាក់ថា ផែនការសកម្មភាពរបស់ពួកគេត្រូវបានអនុវត្ត និងត្រួតពិនិត្យហើយរាយការណ៍ពីលទ្ធផលរបស់ពួកគេ។
- ធ្វើឱ្យប្រសើរឡើងនូវលទ្ធភាពទទួលបាន និងការបើកចំហព័ត៌មានសាធារណៈជាពិសេសលើថវិកា សាធារណៈ និងការចំណាយលើលទ្ធកម្ម។ ប្រជាពលរដ្ឋទទួលបានព័ត៌មានសាធារណៈ ជាពិសេស លើសេវាសាធារណៈថវិកា និងការចំណាយលើលទ្ធកម្មសាធារណៈ។ ៧០% នៃប្រជាពលរដ្ឋគោលដៅ បានយល់ដឹងអំពីសិទ្ធិរបស់ពួកគេចំពោះព័ត៌មានសាធារណៈ ជាពិសេស លើសេវាសាធារណៈថវិកា និងការចំណាយលើលទ្ធកម្មសាធារណៈ។ លទ្ធផលនៃការស្ទង់មតិក្នុងចំណោមអ្នកដឹកនាំ និងគណៈកម្មាការ សមាជិកសហគមន៍ចំនួន ៥០២នាក់៖ ៧៦% ក្នុងនោះស្ត្រី ៥៨% បានយល់ដឹងពីសិទ្ធិរបស់ពួកគេក្នុងការទទួលបានព័ត៌មានថវិកា និងឃុំ សង្កាត់ ហើយអ្នកផ្តល់សេវា មានកាតព្វកិច្ចបង្ហាញសកម្មភាពលទ្ធកម្មរបស់ពួកគេជាសាធារណៈ។
- រដ្ឋបាលថ្នាក់ក្រោមជាតិបានដឹង និងទទួលស្គាល់មតិរបស់ប្រជាពលរដ្ឋដើម្បីកែលម្អសេវាសាធារណៈ និងការផ្សព្វផ្សាយព័ត៌មាន។ ប្រជាពលរដ្ឋ ១៧,២៩២នាក់ បានទទួលការការយល់ដឹងតាមរយៈ យុទ្ធនាការផ្សព្វផ្សាយក្រុមតូច និង ៣៣០,៤៥៦នាក់ តាមរយៈយុទ្ធនាការផ្សព្វផ្សាយការយល់ដឹងជា សាធារណៈតាមរយៈអនឡាញ។

### សកម្មភាព៖

- បានផ្តល់កម្មវិធីអភិវឌ្ឍន៍សមត្ថភាព (ការបណ្តុះបណ្តាល និងការបង្វឹក) ជាមួយនឹងផែនការ សកម្មភាព របស់សហគមន៍នៅក្នុងផ្នែកនៃការតស៊ូមតិអភិបាលកិច្ចថ្នាក់ក្រោមជាតិជំនាញទន់ និងការ អភិវឌ្ឍស្ថាប័ន។ ប្រធាន ឬតំណាងសហគមន៍ចំនួន ៣៣ នាក់ ស្ត្រី ១០នាក់ ត្រូវបានបណ្តុះបណ្តាល និងបង្វឹកលើការយល់ដឹងអំពីយុទ្ធសាស្ត្រតស៊ូមតិការអែអង្គាសថវិកាក្នុងស្រុកការប្រើប្រាស់ប្រព័ន្ធ ផ្សព្វផ្សាយសង្គមការទំនាក់ទំនង និងជំនាញសម្របសម្រួលដែលស្ថិតនៅក្នុង ខេត្តបន្ទាយមានជ័យ និងខេត្តពោធិ៍សាត់។

- សម្របសម្រួលផែនការសកម្មភាពរបស់សហគមន៍ លើការការតស៊ូមតិ ការចូលរួមរបស់ប្រជាពលរដ្ឋ ក្នុងអភិបាលកិច្ចថ្នាក់ក្រោមជាតិ ជំនាញទន់ដែលពាក់ព័ន្ធ ការអភិវឌ្ឍស្ថាប័ន និងការរៃអង្គាស ថវិកាក្នុងស្រុក មុខងារថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ផែនការថវិកា និងការចំណាយ និងអង្គភាព ច្រកចេញចូលតែមួយ និងការិយាល័យច្រកចេញចូលតែមួយ។ មុខងារថ្មីៗ ដែលទើបផ្ទេរ វិមជ្ឈការ ជាពិសេស មុខងារអភិវឌ្ឍន៍ស្ថាប័ន ដើម្បីកែលម្អដំណើរការ និងការអនុវត្ត។ ការអភិវឌ្ឍសមត្ថភាព និងអភិបាលកិច្ចរបស់សហគមន៍។
- បានធ្វើសកម្មភាពផ្សព្វផ្សាយការអប់រំសហគមន៍ និងប្រជាពលរដ្ឋស្តីពីសេវាច្រកចេញចូលតែមួយ និងថវិកាក្រុង ស្រុកឆ្នាំ២០២៣ ដែលមានសមាជិក និងប្រជាពលរដ្ឋចំនួន ១.៥២១នាក់ ស្រី ១.១២៩នាក់។
- ជំរុញការចូលប្រើប្រាស់របស់ប្រជាពលរដ្ឋក្នុងការប្រើប្រាស់ព័ត៌មាន និងការប្រើប្រាស់សេវាសាធារណៈរបស់ការិយាល័យច្រកចេញចូលតែមួយ និងអង្គភាពច្រកចេញចូលតែមួយតាមរយៈពិដោរ អ្នកភូមិឆ្លាត វៃ (Pidor Chatbot) និងការហៅទូរស័ព្ទក៏ដូចជាផ្ទាំងព័ត៌មានសាធារណៈតាមអ៊ីនធឺណិត និងមុខងារការិយាល័យប្រជាពលរដ្ឋសរុបចំនួន ៣០៨.៦៧៤នាក់ ស្រី ១១២.៦៨១នាក់ តាមរយៈការបង្ហោះ និងការផ្សាយផ្ទាល់លើទំព័របណ្តាញសង្គមហ្វេសប៊ុក (Facebook) ស្តីពីសិទ្ធិទទួលព័ត៌មាន។
- វេទិកាសាធារណៈប្រចាំឆ្នាំថ្នាក់ក្រុង ស្រុកដែលមានប្រជាពលរដ្ឋចំនួន ១៦០នាក់ ស្រី ៦០នាក់ស្តី ពីព័ត៌មានថវិការបស់រដ្ឋបាលឃុំ សង្កាត់ ក្រុង ស្រុក បានធ្វើឡើងចំនួន ០៣ ក្រុង ស្រុក ស្រុកមង្គលបូរី និងក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ និងក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់។ សមាជិកសហគមន៍ ទទួលបានការយល់ដឹងកាន់តែច្បាស់អំពីព័ត៌មានថវិកាឃុំ សង្កាត់ ក្រុង ស្រុក ក្នុងឆ្នាំ២០២៣។ សំខាន់ជាងនេះ សហគមន៍ទទួលបានឱកាសក្នុងការចូលរួមពិគ្រោះយោបល់ ជាសាធារណៈ ស្តីពីការរៀបចំផែនការវិនិយោគក្រុង ស្រុក។ ពួកគេបានលើកសំណួរទាក់ទងនឹងចំណូល និងចំណាយរបស់ឃុំ សង្កាត់ ក្រុង ស្រុក និងថវិកាលើកិច្ចគាំពារសង្គម សំណួរទាំងអស់ (១០០%) ត្រូវបានឆ្លើយដោយអាជ្ញាធរមូលដ្ឋាន និងដំណោះស្រាយត្រូវបានសន្យាដោះស្រាយ តម្រូវការរបស់ សហគមន៍បានលើកឡើង រួមទាំងថវិកាមិនគ្រប់គ្រាន់សម្រាប់សកម្មភាពល្បាតព្រៃសហគមន៍ និងការគាំទ្រផ្នែកហិរញ្ញវត្ថុសម្រាប់ក្រុមសន្សំប្រាក់។

## មេរៀនដែលបានរៀន៖

- ការតស៊ូមតិរបស់អង្គការសហគមន៍មូលដ្ឋានទទួលបានជោគជ័យកាន់តែល្អប្រសើរនៅពេលដែលពួកគេបង្កើតផែនការនៃការតស៊ូមតិ។

## បញ្ហាប្រឈម៖

- ថវិកាឃុំ ស្រុកមិនត្រូវបានវិភាជន៍សម្រាប់ធនធានធម្មជាតិ និងបរិស្ថាន (សហគមន៍ព្រៃឈើ)។
- សហគមន៍នៅតែត្រូវការជំនួយបច្ចេកទេសសម្រាប់ការអភិវឌ្ឍ និងដំណើរការរបស់អង្គការសហគមន៍មូលដ្ឋាន។

## ផែនការបន្ត៖

- វេទិកាថ្នាក់ជាតិ ថ្នាក់ខេត្ត និងសិក្ខាសាលាស្តីពីការចំណាយថវិកា និងលទ្ធកម្ម។
- គាំទ្រដំណើរការ ឬកិច្ចប្រជុំដល់ក្រុមការងារអង្គការសង្គមស៊ីវិលលើ សិទ្ធិទទួលបានព័ត៌មាន ថវិកាជាតិ សិទ្ធិឌីជីថល វិមជ្ឈការ និងវិសហមជ្ឈការ PRM កិច្ចគាំពារសង្គម និងក្រុមបរិស្ថាន។
- គាំទ្រដល់យុទ្ធនាការតស៊ូមតិរបស់ក្រុមការងារអង្គការសង្គមស៊ីវិល (កិច្ចពិភាក្សាគោលនយោបាយ សិក្ខាសាលា និងសកម្មភាព) លើសិទ្ធិទទួលបានព័ត៌មាន ច្បាប់ពាក់ព័ន្ធ អ្នកការពារសិទ្ធិមនុស្ស ច្បាប់វិមជ្ឈការ និងវិសហមជ្ឈការ ច្បាប់ទាក់ទងនឹងកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ច្បាប់ការពារសង្គម ក្រមបរិស្ថាន។
- ការប្រកួតប្រជែងចតវីដេអូ។
- ធ្វើការពង្រឹងសមត្ថភាពជាបន្តបន្ទាប់ (វគ្គបណ្តុះបណ្តាលរយៈពេល ០៣ថ្ងៃ និងការបង្វឹកបន្ថែម)។

- គាំទ្រដល់សហគមន៍ ជាពិសេស យុវជន ស្ត្រី ជនជាតិដើមភាគតិច ជនមានពិការភាព មនុស្សវ័យចាស់ ដើម្បីអនុវត្តផែនការតស៊ូមតិ កិច្ចសន្ទនាសង្គម ប្រជុំបណ្តាញនានា និងការចូលរួមនៅក្នុងសិក្ខាសាលា ផែនការវិនិយោគប្រចាំឆ្នាំរបស់ឃុំ សង្កាត់ ក្រុង ស្រុក ដំណើរការលទ្ធកម្មសាធារណៈ និងការត្រួតពិនិត្យការអនុវត្តគម្រោង។
- ផ្សព្វផ្សាយព័ត៌មានថវិកាសម្រាប់ប្រជាពលរដ្ឋនៅថ្នាក់ក្រោមជាតិ និងលទ្ធកម្មសាធារណៈ (ធ្វើបច្ចុប្បន្នភាពឧបករណ៍ក្នុងការវិភាគ និងបង្កើតតារាងព័ត៌មាន)។
- ធ្វើបច្ចុប្បន្នភាពឧបករណ៍វិភាគថវិការបស់ប្រជាពលរដ្ឋ។
- ការផ្សព្វផ្សាយតាមខ្នងផ្ទះ។
- គាំទ្របណ្តាញផ្សព្វផ្សាយសង្គមរបស់អង្គការ API។
- ការពង្រឹងសមត្ថភាពដល់អាជ្ញាធរ និងសកម្មភាព លើគោលបំណង ការអនុវត្តច្បាប់ទទួលព័ត៌មាន យ៉ាងហោចណាស់ផ្នែកសំខាន់មួយ (លទ្ធកម្មសាធារណៈ ឬថវិកា)។
- កិច្ចប្រជុំក្រុមការងារគណនេយ្យភាពជាមួយមន្ត្រីការិយាល័យប្រជាពលរដ្ឋលើបញ្ហាសហគមន៍ (យុវជន ស្ត្រី ជនជាតិដើមភាគតិច មនុស្សចាស់)។

***ករណីសិក្សា៖*** ក្រុមយុវជនរួមរួបសាមគ្គីដើម្បីអភិវឌ្ឍន៍សហគមន៍



**ក្រុមយុវជនរួមរួបសាមគ្គីដើម្បីអភិវឌ្ឍន៍សហគមន៍** គឺជាសហគមន៍ដែលទើបនឹងបង្កើត ឡើងថ្មីនៅ ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ជាមួយនឹងចក្ខុវិស័យ ដើម្បីឱ្យមានការចូលរួម ពីយុវជនកាន់តែច្រើន ក្នុងការអភិវឌ្ឍសហគមន៍។ ការបង្កើតក្រុមនេះបានចាប់ផ្តើមនៅក្នុង ខែឧសភា ឆ្នាំ២០២៣ ដោយគំនិត ផ្តួចផ្តើមរបស់យុវជនដែលមិនធ្លាប់ចូលរួមក្នុងសកម្មភាពក្រុមប្រឹក្សាសង្កាត់ពីមុនមក និងអ្នកដែលបានចូលរួម វគ្គបណ្តុះបណ្តាលពីការប្រើប្រាស់ពិដោរ អ្នកភូមិឆ្លាតវៃ ដោយអង្គការ **វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ (API)**។ ក្រុមយុវជននេះ ត្រូវបានជ្រើសរើសយុវជនបន្ថែមទៀត ដើម្បីចូលរួមក្នុងវគ្គបណ្តុះបណ្តាល ហើយឱ្យពួកគេសិក្សាអំពីសេវាសាធារណៈ ដែលមាននៅក្នុងការិយាល័យ ច្រកចេញចូលតែមួយ និងអង្គភាពច្រកចេញចូលតែមួយ។ ការប្រើប្រាស់ពិដោរ អ្នកភូមិឆ្លាតវៃ ត្រូវបានគេមើលឃើញថាទទួលបានជោគជ័យ យ៉ាងខ្លាំងនៅក្នុងសហគមន៍។ វាជួយឱ្យ ក្រុមយុវជនរួមរួប សាមគ្គីដើម្បីអភិវឌ្ឍន៍សហគមន៍ យល់ដឹងកាន់តែច្បាស់ពីសេវាការិយាល័យច្រកចេញចូលតែមួយ និងអង្គភាពច្រកចេញចូលតែមួយ និងតម្លៃសេវា។ ក្រុមយុវជនរួមរួបសាមគ្គីដើម្បីអភិវឌ្ឍន៍សហគមន៍បន្តអប់រំប្រជាពលរដ្ឋនៅមូលដ្ឋានក្នុងតំបន់របស់ពួកគេឱ្យប្រើប្រាស់ពិដោរ អ្នកភូមិឆ្លាតវៃ ដើម្បីសាកសួរពីសេវាការិយា ល័យច្រកចេញចូលតែមួយ និងអង្គភាពច្រកចេញចូលតែមួយ។ ប្រជាជនភាគច្រើនមិនដឹងអំពីសេវាទាំងនោះពីមុនមកទេ ប៉ុន្តែពិដោរអ្នកភូមិឆ្លាតវៃ អាចជួយពួកគាត់បានច្រើន។ ពួកគាត់ក៏អាចសិក្សាស្វែងយល់ ពីឯកសារភ្ជាប់សម្រាប់ប្រភេទនៃសេវា ដែលពួកគាត់ត្រូវការដើម្បីនាំយកមកជាមួយផងដែរ។ វាមានប្រយោជន៍ និងមានភាពងាយស្រួលណាស់។ ជាងនេះទៅទៀត ប្រជាពលរដ្ឋមួយចំនួន ធ្លាប់បានចំណាយច្រើន លើថ្លៃសេវាជាងតម្លៃជាក់ស្តែង មុនពេលដែលពួកគាត់ស្គាល់ និងយល់ពីការប្រើប្រាស់ពិដោរ អ្នកភូមិឆ្លាតវៃ។ ក្រុមយុវជនរួមរួបសាមគ្គីដើម្បីអភិវឌ្ឍន៍សហគមន៍ ម្នាក់បាននិយាយថា “ពិដោរ អ្នកភូមិឆ្លាតវៃ មានភាពងាយស្រួលសម្រាប់ប្រជាពលរដ្ឋនៅក្នុងសហគមន៍របស់ខ្ញុំដោយសារពួកគេអាចទទួលបានសេវាសាធារណៈគ្រប់ប្រភេទ បូករួមទាំងថ្លៃសេវា និងរយៈពេលនៃការទទួលសេវា”។ បន្ថែមពីលើនេះ ការប្រើប្រាស់ពិដោរ អ្នកភូមិឆ្លាតវៃ អង្គការ API បានរៀបចំវេទិកាសាធារណៈនៅក្នុងសហគមន៍ ដែលត្រូវបានគេចាត់ទុកថាមានលទ្ធផលជាផ្លែផ្កាច្រើន។ អង្គការ API បានធ្វើវេទិកាសាធារណៈ ដោយមានការចូលរួមពីប្រជាពលរដ្ឋ និងអាជ្ញាធរក្រុង។ ពួកគេបានជួយឱ្យប្រជាពលរដ្ឋយល់ដឹងអំពី សេវាសាធារណៈ និងតារាងតម្លៃសេវាដែលមានក្នុងអង្គភាពច្រកចេញចូលតែមួយ និងការិយាល័យច្រកចេញចូលតែមួយ។ ពួកគេបានស្នើសុំឱ្យអាជ្ញាធរមូលដ្ឋានបញ្ឈប់ការយកថ្លៃសេវាមិនផ្លូវការ ឬសំណូក មួយចំនួនដែលពលរដ្ឋធ្លាប់ចំណាយពីមុនមកដើម្បីទទួលបាន

សេវា។ ក្រុមយុវជនរួមរួបសាមគ្គីដើម្បីអភិវឌ្ឍន៍សហគមន៍ បានបញ្ជាក់ថា **“យើងមានឱកាសសួរសំណួរនៅក្នុងវេទិកាសាធារណៈ** ខ្ញុំបានសួរអាជ្ញាធរក្រុងអំពីតម្លៃសេវា សម្រាប់ការកែតម្រូវព័ត៌មានលើសំបុត្រកំណើត។ អាជ្ញាធរក្រុងបានឆ្លើយថាការកែតម្រូវព័ត៌មានលើសំបុត្រកំណើតគឺឥតគិតថ្លៃនោះទេ។ យើងមានការភ្ញាក់ផ្អើលយ៉ាងខ្លាំងពេលបានឮដូច្នេះ។ ខ្ញុំប្រាប់គាត់ដោយត្រង់ថា ប្រជាពលរដ្ឋមួយចំនួនធ្លាប់ចំណាយលុយរាប់រយរៀលដើម្បីទទួលបានសំបុត្រកំណើត។ ពួកយើងបានប្រមូល ព័ត៌មានបន្ថែម ពីប្រជាពលរដ្ឋហើយយើងធ្វើជាតំណាងឱ្យពួកគាត់ដើម្បីសួរសំណួរនៅក្នុងវេទិកាសាធារណៈ។ “យើងហ៊ានសួរសំណួរដែលប្រជាពលរដ្ឋយើងមិនហ៊ានសួរ”។

## លទ្ធផលទី៤ អង្គការ API កំពុងតែបង្កើនសមត្ថភាព និងនិរន្តរភាពនៃស្ថាប័នរបស់ខ្លួនតាមរយៈការរៃអង្គាសថវិកាដោយជោគជ័យ ដើម្បីសម្រេចបានគោលដៅឆ្នាំ ២០២៣

ក្នុងអំឡុងឆ្នាំទីប្រាំនៃរយៈពេលអនុវត្តផែនការយុទ្ធសាស្ត្រឆ្នាំ ២០២៣ គោលដៅសំខាន់ៗភាគច្រើនត្រូវបានសម្រេចដោយជោគជ័យ។

**R4.1** **អង្គការ API ត្រូវបានអភិបាលកិច្ចល្អ និងគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព តម្លាភាព និងប្រសិទ្ធភាព (បូករួមទាំងសវនកម្ម)។** អង្គការ API បានគ្រប់គ្រងដើម្បីរក្សាការគាំទ្រម្ចាស់ជំនួយពេញលេញសម្រាប់គម្រោងទាំង ១៣ ក្នុងឆ្នាំ ២០២៣ហើយ គម្រោងចំនួន ០៧ ត្រូវបានបញ្ចប់ដោយជោគជ័យនៅចុងឆ្នាំ។ គម្រោងថ្មី និងកំពុងបន្តចំនួន ១១ នឹងត្រូវបានអនុវត្តនៅឆ្នាំ ២០២៤ ស្របតាមផែនការយុទ្ធសាស្ត្រឆ្នាំ ២០២៤-២០២៨។

អង្គការ API បានទទួលបានវិញ្ញាបនបត្រ អភិបាលកិច្ច និងការប្រតិបត្តិប្រកបដោយវិជ្ជាជីវៈ ចំពោះការអនុវត្តបានតាម ៣ គោលការណ៍ (អភិបាលកិច្ចល្អ ការគ្រប់គ្រងធនធានល្អ និងការប្រតិបត្តិកម្មវិធីប្រកបដោយចាមវន្ត) ដែលមានសុពលភាពចាប់ឆ្នាំ២០២៣ ដល់ឆ្នាំ២០២៨ ដោយបានពិន្ទុ ១៣១/១៣៥ ហើយលទ្ធផលវាយតម្លៃគឺ ៥៦/៥៦។

**អង្គការ API បានរចនា និងបោះពុម្ពសៀវភៅ ហើយឯកសារមានដូចជា៖**

១. សំឡេងអាជីវករស្ត្រីលក់ដូរតាមដងផ្លូវក្នុងស្ថានភាពកូវីដ១៩ របាយការណ៍វាយតម្លៃ ស្តីពី ផលប៉ះពាល់នៃជំងឺកូវីដ-១៩ លើអាជីវករស្ត្រីលក់ដូរតាមដងផ្លូវ និងការធានាបានទូវសិទ្ធិសេដ្ឋកិច្ចសង្គម (អង់គ្លេស និងខ្មែរ)

២. របាយការណ៍វិភាគគោលនយោបាយ គំរូនៃការអនុវត្តគោលនយោបាយ អាជីវកម្មលើដងផ្លូវនៅប្រទេសអាស៊ាន (អង់គ្លេស និងខ្មែរ)

៣. ការសិក្សាស្រាវជ្រាវស្តីពី៖ “ការវិភាគក្របខណ្ឌគោលនយោបាយបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) និងលក្ខខណ្ឌសម្រាប់ការអនុវត្តក្របខណ្ឌគោលនយោបាយបេឡាជាតិរបបសន្តិសុខសង្គមសម្រាប់ស្ត្រីអ្នកលក់ដូរតាមដងផ្លូវនៅកម្ពុជា” (អង់គ្លេស និងខ្មែរ)

៤. របាយការណ៍ ស្តីពី ការវិភាគថវិកាឃុំ សង្កាត់ និងក្រុង ស្រុក ឆ្នាំ២០២១ - ២០២២ (អង់គ្លេស និងខ្មែរ)

៥. របាយការណ៍សិក្សាស្ថានភាពដើមគម្រោង គម្រោងសំឡេង និងសកម្មភាពរបស់ប្រជាពលរដ្ឋសម្រាប់ការអភិវឌ្ឍប្រកប ដោយនិរន្តរភាពនៅកម្ពុជា (អង់គ្លេស និងខ្មែរ)

៦. របាយការណ៍ប្រចាំឆ្នាំ២០២២ របស់អង្គការ API (អង់គ្លេស និងខ្មែរ)

៧. ទម្រង់បែបបទបណ្តឹងត្រូវបានបោះពុម្ព ហើយមាននៅការិយាល័យរបស់អង្គការ API។

| API's Projects - 2019-23 | |
|---|---|
| **Project 1** | Citizens voices and actions for sustainable development in Cambodia, 2020-2022 |
| **Project 2** | Young People Influence the Cambodian Access to Information Law, 2021-2023 |
| **Project 3** | Promoting rights, voices, choices and decisions for citizens (Pro-citizens), 2017-2019 |
| **Project 4** | Enhancing Local Democratic Governance in Cambodia, 2018-20 |
| **Project 5** | Strengthening Youth Participation in Local Planning and Budgeting, 2019-2021 |
| **Project 6** | One Window for Citizen Project, 2019-2021 |
| **Project 7** | Adopting and Adapting Change the Game Academy (CtGA) for Mobilising Support (MS) Capacity in Cambodia, 2017-23 |
| **Project 8** | People with Disabilities' Voices and Action in Social Accountability, 2019-2020. |
| **Project 9** | Covid-19 Emergency Support to Most Vulnerable Households, 2020 |
| **Project 10** | Citizens' Voices in Social Accountability, 2019-2023 |
| **Project 11** | Supporting Meaningful Civic Engagement by Leveraging Digital Technologies, 2019-2023 |
| **Project 12** | Enhancing the Institutional and Operational Capacity of the Provincial Associations of Local Councils, 2019-2021 |
| **Project 13** | Voices and Action of Young Women Leaders and Entrepreneurs, 2019-2023 |
| **Project 14** | Innovations for Social Accountability in Cambodia (ISAC), 2019-2024 |
| **Project 15** | Access for All: Promoting Access to Information in Cambodia, 2021-2023 |
| **Project 16** | Internet Monitoring and Action Project (iMAP), 2022-2024 |
| **Project 17** | Towards Public Procurement Transparency (PPT), 2022 |
| **Project 18** | Voice funded Louder Voices for Social Protection through I-SAF, 2022-2023 |
| **Project 19** | Citizen Voices and Action for Access to Information and Accountable Local Governance, 2022-2023 |
| **Project 20** | Women and Youth Empowerment in Leadership Program, 2022-2024 |

BUILDING CAPACITY FOR CHANGE

វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ
ADVOCACY AND POLICY INSTITUTE

# វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ

## អង្គការមិនមែនរដ្ឋាភិបាលឈានមុខមួយ ដែលសកម្មនៅក្នុងការតស៊ូមតិ ការជះឥទ្ធិពលលើគោលនយោបាយ ការកសាងសមត្ថភាព អភិបាលកិច្ចល្អ និងការសម្របសម្រួលកិច្ចសន្ទនារវាងប្រជាពលរដ្ឋ និងតួអង្គរបស់រដ្ឋ

វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ (API) ជាអង្គការក្រៅរដ្ឋាភិបាលមួយរបស់កម្ពុជា ដែលសកម្មក្នុងការតស៊ូមតិ ការជះឥទ្ធិពលនយោបាយ អភិបាលកិច្ចល្អ និងការចូលរួមរបស់ពលរដ្ឋ។ ការកសាងសមត្ថភាព និងការសម្របសម្រួលកិច្ចសន្ទនា គឺជាចំណុចសំខាន់នៃកិច្ចខិតខំប្រឹងប្រែងរបស់យើង ឆ្ពោះទៅរកការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ និងការអភិវឌ្ឍប្រកបដោយនិរន្តរភាព។

យើងទទួលបានការសាទរយ៉ាងទូលំទូលាយពីអង្គការក្នុងស្រុក និងអន្តរជាតិសម្រាប់ភាពដែលអាចជឿជាក់បាន ភាពពាក់ព័ន្ធ និងវិជ្ជាជីវៈរបស់យើង។ ក្នុងរយៈពេលជិតពីរទសវត្សរ៍មកនេះ API បានជួយពង្រឹងជំនាញស្ថាប័នតស៊ូមតិ និងបានខិតខំធ្វើឲ្យលទ្ធិប្រជាធិបតេយ្យមូលដ្ឋាន និងអភិបាលកិច្ចដែលមានគណនេយ្យភាព ក្លាយទៅជាការពិត។ មកទល់នឹងពេលនេះយើងបានបើក<u>វគ្គបណ្តុះបណ្តាល</u>ជាង៣០០មកហើយសម្រាប់អ្នកចូលរួមជាង១ម៉ឺននាក់ដែលមានទំនាក់ទំនងជាមួយសង្គមស៊ីវិល និងអង្គការសហគមន៍ ក្រុមប្រឹក្សា មូលដ្ឋាន ប្រព័ន្ធផ្សព្វផ្សាយ អង្គភាពសហជីព ស្ថាប័នរដ្ឋាភិបាល និងសភាកម្ពុជាផងដែរ។

API មានភាពប្លែកពីគេ នៅក្នុងសង្គមស៊ីវិលរបស់ប្រទេសកម្ពុជា ដោយបម្រើជាអ្នកភ្ជាប់ និងសម្របសម្រួល សម្រាប់ការផ្តល់សិទ្ធិអំណាចដល់ប្រជាជន ក្នុងការធ្វើអន្តរកម្មជាមួយរដ្ឋាភិបាលគ្រប់លំដាប់ថ្នាក់។ API ទទួលបានបទពិសោធន៍ដំបូង លើបញ្ហាគោលនយោបាយ ដូចជាការទទួលបានព័ត៌មាន (A2I) តាមរយៈការងារមូលដ្ឋានរបស់ខ្លួន។ ផ្អែកលើបទពិសោធន៍ដ៏ធំធេងនេះយើងស្ថិតក្នុងកន្លែងដ៏ល្អបំផុតមួយដើម្បីធ្វើឱ្យសំឡេងរបស់ពលរដ្ឋសាមញ្ញត្រូវបានរាប់បញ្ចូលក្នុងការធ្វើគោលនយោបាយនៅថ្នាក់ជាតិ។នៅទីនេះយើងបានព្យាយាមគាំទ្រដល់ស្ថាប័នរដ្ឋាភិបាលឱ្យបម្រើប្រជាពលរដ្ឋស្របតាមច្បាប់ និងចូលរួមចំណែកក្នុងបរិយាកាស ដែលអាចឲ្យពលរដ្ឋ និងសង្គមស៊ីវិលអាចបង្ហាញការព្រួយបារម្ភរបស់ពួកគេបាន។ ទីបំផុត យើងបានដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយពលរដ្ឋឲ្យយល់ពីសិទ្ធិរបស់ពួកគេ <u>ការទទួលបានព័ត៌មាន</u> និងប្រើប្រាស់ឱកាសសម្រាប់ការចូលរួម ដែលត្រូវបានផ្តល់ជូនដោយច្បាប់ផ្សេងៗ និងគោលនយោបាយរបស់រដ្ឋាភិបាល។

កម្មវិធីរបស់យើងត្រូវបានដឹកនាំដោយវិធីសាស្ត្រផ្អែកលើសិទ្ធិមនុស្ស។ API បម្រើប្រជាជនកម្ពុជាទាំងអស់ ហើយឱ្យតម្លៃទៅលើភាពខុសគ្នា ដោយមិនប្រកាន់ភេទ និន្នាការភេទ និងអត្តសញ្ញាណ ការមានសមត្ថភាព ការអសមត្ថភាព ជាតិពន្ធុ ជំនឿ និងនិន្នាការនយោបាយឡើយ។ ទន្ទឹមនឹងនេះដែរ យើងមានការប្តេជ្ញាចិត្ត ជាពិសេស ក្នុងការគាំទ្រដល់អ្នកដែលជួបការលំបាកបំផុតក្នុងការខិតខំធ្វើឱ្យសំឡេងរបស់ពួកគេត្រូវបានគេដឹងឮ។

# ទំនាក់ទំនង

អគារ ភ្នំពេញវីឡា ផ្ទះលេខ ១២៤ ផ្លូវ ៣៨៨ សង្កាត់ទួលស្វាយព្រៃទី១
ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរសព្ទ (៨៥៥-២៣) ២១៣ ៤៨៦  ទូរសារ (៨៥៥-២៣) ២១៣ ៤៨៧
www.apiinstitute.org